សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics


# សារណាបញ្ចប់ការសិក្សា

# បណ្ដឹងឧទ្ធរណ៍នឹងដីកាសម្រេចរបស់ចៅក្រមស៊ើបសួរទៅសភាស៊ើបសួរ

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ   កញ្ញា **គង់ ចុងម៊ី**

លោក **ឈី ធិត្យា**

ណែនាំដោយ

លោកគ្រូ **សៅ ស៊ីវុត្ថា**



ថ្នាក់បរិញ្ញាបត្រ  នីតិសាស្ត្រ

ជំនាន់ទី ២៤

ឆ្នាំចូលសិក្សា   ២០២០

ឆ្នាំសរសេរសារណា ២០២៤

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# បណ្តឹងឧទ្ធរណ៍នឹងដីកាសម្រេចរបស់ចៅក្រមស៊ើបសួរទៅសភាស៊ើបសួរ

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ  កញ្ញា **គង់ ចុងម៉ី**
លោក **លី ធិត្យា**

ណែនាំដោយ
លោកគ្រូ **សៅ ស៊ីវុត្ថា**

ថ្នាក់បរិញ្ញាបត្រ  នីតិសាស្ត្រ
ជំនាន់ទី ២៤

ឆ្នាំចូលសិក្សា  ២០២០
ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំ **គង់ ចុងមុី** និងខ្ញុំបាទ **លី ធិត្យា** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ជំនាញនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។ យើងខ្ញុំសូមសម្តែងនូវសេចក្តី កតញ្ញូតាធម៌ និងអំណរគុណយ៉ាងជ្រាវជ្រៅបំផុតជូនចំពោះ ៖

**លោកឪពុក អ្នកម្តាយ អ្នកអាណាព្យាបាល** ដែលលោកមានអធិគុណចំពោះរូបកូន បានផ្តល់កំណើត ចិញ្ចឹមបីបាច់ ថ្នាក់ថ្នម ថែរក្សា ប្រកបដោយព្រហ្មវិហារធម៌៤ប្រការ មេត្តា ករុណា មុទិតា ឧបេក្ខា អប់រំទូន្មាន ប្រៀនប្រដៅ និងទំនុកបម្រុងគ្រប់បែបយ៉ាងទាំងសម្ភារៈ ទាំងស្មារតី និងថវិកាឲ្យកូនបានសិក្សារៀនសូត្រចាប់ពីបឋមសិក្សា រហូតមកដល់ ឧត្តមសិក្សា ។

**ឯកឧត្តម លុយ ចណ្ណា** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានអនុញ្ញាតឲ្យយើងខ្ញុំបាទចូលសិក្សានៅសាកលវិទ្យាល័យនេះ និងបង្កលក្ខណៈងាយស្រួល ដល់ការសិក្សារបស់យើងខ្ញុំ ។

**លោកគ្រូ សៅ ស៊ីវុត្ថា** ជាលោកគ្រូណែនាំ ដែលបានចំណាយពេលវេលាដ៏មានតម្លៃ និងដ៏មមាញឹកក្នុងការបង្ហាត់បង្រៀន ព្រមទាំងផ្តល់អនុសាសន៍ និង ការណែនាំ ដើម្បីរៀបចំសារណាបញ្ចប់ការ សិក្សានេះ ។

**គណៈគ្រប់គ្រងសាកលវិទ្យាល័យ សាស្ត្រាចារ្យ ព្រមទាំងបុគ្គលិកសិក្សា** សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ ដែលបានបង្ហាត់បង្រៀន និងបង្កលក្ខណៈងាយស្រួលដល់ការសិក្សាយើងខ្ញុំ ។

សូមសម្តែងនូវសេចក្តីអំណរគុណយ៉ាងជ្រាវជ្រៅបំផុតថែមទៀត ចំពោះអ្នកនិពន្ធ និងអ្នកប្រាជ្ញព្រមទាំង ទស្សនៈវិទូល្បីៗក្នុងលោក ដែលយើងខ្ញុំបាន សិក្សាស្រាវជ្រាវពីស្នាដៃរបស់លោកក្នុងការបំពេញកិច្ចការស្រាវជ្រាវកន្លងមក។

សូមមេត្តា ទទួលនូវអំណរគុណដ៏ជ្រាវជ្រៅបំផុត និងមិនអាចបំភ្លេចបាន ចំពោះឧបការគុណដ៏ធំធេងពី យើងខ្ញុំ។ ជាទីបញ្ចប់នេះ យើងខ្ញុំសូមបួងសួង ដល់ទេវតាឱ្យប្រសិទ្ធពរជ័យជូនដល់ លោកអ្នកមានគុណឯកឧត្តម លោកជំទាវ លោក លោកស្រី និងសាស្ត្រាចារ្យទាំងអស់ សូមឱ្យបានប្រកបតែជោគជ័យគ្រប់ភារកិច្ច ការងារ និងសូមទទួលបាននូវពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ ព្រមទាំងសុភមង្គលកុំបីឃ្លៀង ឃ្លាតឡើយ ។

# អារម្ភកថា

ជាបឋម នាងខ្ញុំ **គង់ ចុងមុី** និងខ្ញុំបាទ **លី ទិត្យា** សូមគោរពសារជាថ្មីម្តងទៀតដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី សាស្ត្រាចារ្យ ព្រមទាំងស្វាគមន៍ដល់ មិត្តអ្នកអានគ្រប់រូប ជាពិសេសនិស្សិតជាទីរាប់អាន។

ក្នុងនាមយើងខ្ញុំ ជានិស្សិតដែលកំពុងសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ផ្នែកនីតិសាស្ត្រ ជំនាន់ទី ២៤ ឆ្នាំសិក្សា ២០២១-២០២៤ ក្រោយពីបានសិក្សានូវមុខវិជ្ជា នីតិវិធីព្រហ្មទណ្ឌ នៅអំឡុងពេលឆ្នាំទី៣ ឆមាសទី២ ស្របតាមកម្មវិធីសិក្សារបស់សកលវិទ្យាល័យ រួមទាំងការស្រាវជ្រាវបន្ថែមនានា។ ជាកិត្តិយសដ៏ខ្ពង់ខ្ពស់ ដែលទទួលបានឱកាសក្នុងការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ យើងខ្ញុំបានជ្រើសរើសយកនូវប្រធានបទស្តីពី " **បណ្តឹងឧទ្ធរណ៍នឹងដីកាសម្រេចរបស់ចៅក្រមស៊ើបសួរនៅសភាស៊ើបសួរ** " នេះឡើងដោយសារ យើងខ្ញុំសង្កេតឃើញថា ប្រធានបទនេះពិតជាមាននូវចំណុចសំខាន់ៗជាច្រើនដែលសុទ្ធសឹងតែជាចំណុចដែលគួរអោយចាប់អារម្មណ៍ ចាំបាច់ត្រូវតែលើកយកមកសិក្សា និងស្រាវជ្រាវ ដើម្បីឲ្យបានយល់កាន់តែច្បាស់អំពីនីតិវិធីនៃការស៊ើបសួររបស់ចៅក្រមស៊ើបសួរ ដែលការស៊ើបសួរត្រូវប្រព្រឹត្តិទៅដោយឯករាជ្យ យុត្តិធម៌ និងមិនលំអៀង ជាងនេះតទៅទៀតប្រធានបទនេះបានបង្ហាញឲ្យឃើញពីនិតិវិធីក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ទៅនឹងដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ ប្រសិនបើបុគ្គលពាក់ព័ន្ធនៅក្នុងរឿងក្តីមិនសុខចិត្តទៅនឹងប្រភេទនៃដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ ។

ម្យ៉ាងវិញទៀត ក្នុងការស្រាវជ្រាវ និងចងក្រងសារណានេះឡើងក្នុង គោលបំណងដើម្បីទុកជាឯកសារសម្រាប់បំពេញបន្ថែមនូវតម្រូវការរបស់សិស្សនិស្សិតជំនាន់ក្រោយ និង ជួយដល់លោក លោកស្រី អ្នកទាំងអស់ដែលបានសិក្សាស្រាវជ្រាវជំនាញនីតិសាស្ត្រ ហើយចង់យកទៅធ្វើការសិក្សាបន្ត ទៅនឹងអ្វីដែលទាក់ទងទៅនឹងប្រធានបទនេះ។ ជាពិសេស យើងខ្ញុំចង់ដឹង និងចង់សិក្សាឲ្យស៊ីជម្រៅច្បាស់លាស់បន្ថែមទៀតទៅលើខ្លឹមសារ និងអត្ថន័យនៃក្រមនីតិវិធីព្រហ្មទណ្ឌទាំងមូល ជាពិសេសជុំវិញប្រធានបទស្តីពី " **បណ្តឹងឧទ្ធរណ៍នឹងដីកាសម្រេចរបស់ចៅក្រមស៊ើបសួរនៅសភាស៊ើបសួរ** " ។

យើងខ្ញុំសូមខន្តីសូមអភ័យទោសផងដែរ នូវរាល់កង្វះខាតទាំងឡាយដែលមាននៅ ក្នុងសារណានេះ យើងខ្ញុំរង់ចាំទទួលការរិះគន់ដើម្បីកែលម្អពីសំណាក់ ឯកឧត្តម លោកជំទាវ លោក លោកស្រី សាស្ត្រាចារ្យ និងមិត្តអ្នកអានទាំងអស់គ្នា ។

ជាចុងក្រោយនេះ សូមជូនពរដល់អ្នកអានគ្រប់រូបឲ្យជួបប្រទះតែនឹងភាពសុខដុមរមនា ថ្កុំថ្កើង និង មានសុភមង្គលជានិរន្តន៍កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

ទំព័រ


**សេចក្តីផ្តើម** ........................................................ ១

## ជំពូកទី១
## ចៅក្រមស៊ើបសួរ

**ផ្នែកទី១៖ សញ្ញាណទូទៅនៃចៅក្រមស៊ើបសួរ** ........................................ ៤

កថាខណ្ឌទី១៖ គោលការណ៍នៃការស៊ើបសួរ ........................................ ៤

១.១.ការសម្ងាត់នៃការស៊ើបសួរ ........................................ ៤

១.២.ការស៊ើបសួរដាក់បន្ទុក និងដោះបន្ទុក ........................................ ៤

កថាខណ្ឌទី២៖ សមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ ........................................ ៥

២.១.សមត្ថកិច្ចដែនដី ........................................ ៥

២.២.សមត្ថកិច្ចតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ........................................ ៥

កថាខណ្ឌទី៣៖ វិធានការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ ........................................ ៧

៣.១.ការដាក់ជនត្រូវចោទឲ្យស្ថិតក្រោមការត្រួតពិនិត្យ ........................................ ៧

៣.២.ការសួរចម្លើយជនត្រូវចោទ ........................................ ៨

៣.៣.ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី ........................................ ៩

៣.៤.ការឆែកឆេរ និងការចាប់យកវត្ថុតាង ........................................ ១០

៣.៥.កោសលវិច័យ ........................................ ១១

៣.៦.ការស្តាប់ទូរស័ព្ទ ........................................ ១៣

៣.៧.ការចាត់ឲ្យស៊ើបសួរជំនួស ........................................ ១៤

៣.៨.វិធានការនិរន្តរាយ ........................................ ១៥

៣.៨.១.ដីកាបង្គាប់ឲ្យចូលខ្លួន ........................................ ១៥

៣.៨.២.ដីកាបង្គាប់ឲ្យនាំខ្លួន ........................................ ១៥

៣.៨.៣.ដីកាបង្គាប់ឲ្យចាប់ខ្លួន ........................................ ១៦

៣.៨.៤.ដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្ន ........................................ ១៦

៣.៨.៤.១.មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន ........................................ ១៦

៣.៨.៤.២.ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ........................................ ១៧

៣.៨.៥.ការដាក់ជនត្រូវចោទឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ........................................ ១៨

**ផ្នែកទី២៖ ការបិទបញ្ចប់នីតិវិធីស៊ើបសួរ** ........................................ ១៩

កថាខណ្ឌទី១៖ ដំណើរការនៃការបិទបញ្ចប់នីតិវិធីស៊ើបសួរ ........................................ ១៩

១.១.លិខិតជូនដំណឹងស្តីពីការបិទការស៊ើបសួរ ........................................ ១៩

១.២.ដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា ....................................................................២០
១.៣.ដីកាដំណោះស្រាយ ....................................................................................................២០
១.៣.១.ប្រភេទនៃដីកាដំណោះស្រាយ.........................................................................២១
១.៣.១.១.ដីកាលើកលែងចោទប្រកាន់ ....................................................................២១
១.៣.១.២.ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ.........................................................២១
១.៣.១.៣.អានុភាពនៃដីកាដំណោះស្រាយ................................................................២១

# ជំពូកទី២

# បណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ

**ផ្នែកទី១៖ សញ្ញាណទូទៅនៃបណ្តឹងឧទ្ធរណ៍** ........................................................................២៤
កថាខណ្ឌទី១៖ សញ្ញាណទូទៅ...........................................................................................២៤
១.១.និយមន័យនៃបណ្តឹងឧទ្ធរណ៍ ...................................................................................២៤
១.២.ទម្រង់នៃបណ្តឹងឧទ្ធរណ៍..........................................................................................២៤
**ផ្នែកទី២៖ នីតិវិធីបណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ** ..............................២៥
កថាខណ្ឌទី១៖ ភាគីដែលមានសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍ ...............................................................២៥
១.១.បណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍និងព្រះរាជអាជ្ញា ..........................................................................................................................................២៦
១.២.បណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយជនត្រូវចោទ ..................................................................២៦
១.៣.បណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី ................................................... ២៧
កថាខណ្ឌទី២៖ ប្រភេទដីកាដែលអាចធ្វើបណ្តឹងឧទ្ធរណ៍............................................................ ២៧
២.១.បណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងព្រះរាជអាជ្ញា ................................................................................................................២៨
២.២.បណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរដោយជនត្រូវចោទ...................២៨
២.២.១. ដីកាសម្រេចបដិសេធពាក្យសុំធ្វើកិច្ចស៊ើបសួរ .........................................................២៨
២.២.២.ដីកាសម្រេចមិនព្រមប្រគល់វត្ថុដែលចាប់ឲ្យទៅម្ចាស់ដើមវិញ..........................២៨
២.២.៣.ដីកាសម្រេចបដិសេធពាក្យសុំឲ្យធ្វើកោសលវិច័យ................................................២៩
២.២.៤.ដីកាសម្រេចបដិសេធសុំឲ្យធ្វើកោលសវិច័យបន្ថែម ឬពាក្យសុំឲ្យធ្វើប្រតិកោសលវិច័យ ..........................................................................................................................................២៩
២.២.៥.ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន និងការត្រួតពិនិត្យតាមផ្លូវតុលាការ...............៣០
២.៣.បណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរដោយដើមបណ្តឹងរដ្ឋប្បវេណី.......៣០
២.៣.១.ដីកាសម្រេចបដិសេធពាក្យសុំឲ្យធ្វើកិច្ចស៊ើបសួរ ...............................................៣០
២.៣.២.ដីកាសម្រេចកំណត់ចំនួនប្រាក់កក់ .........................................................................៣១
២.៣.៣.ដីកាសម្រេចប្រកាសមិនទទួលពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ..............................................................................................................៣១
២.៣.៤.ដីកាសម្រេចផ្តន្ទាទោសដើមបណ្តឹងរដ្ឋប្បវេណី...............................................៣១

២.៣.៥.ដីកាសម្រេចមិនព្រមប្រគល់សងវត្ថុដែលចាប់យកឲ្យទៅម្ចាស់ដើមវិញ...............៣១
២.៣.៦.ដីកាសម្រេចបដិសេធពាក្យសុំឲ្យធ្វើកោសលវិច័យ........................................ ៣២
២.៣.៧.ដីកាសម្រេចបដិសេធសុំឲ្យធ្វើកោលសវិច័យបន្ថែម ឬ ពាក្យសុំធធ្វើប្រតិកោសលវិច័យ
........................................................................................................................ ៣២
២.៣.៨.ដីកាដំណោះស្រាយ ........................................................................... ៣២
កថាខណ្ឌទី៣៖ លំហូរនៃការធ្វើពាក្យបណ្ដឹងឧទ្ធរណ៍ទៅសភាស៊ើបសួរ ......................... ៣៣
៣.១.ការដាក់ពាក្យបណ្ដឹង ................................................................................ ៣៣
៣.២.រយៈពេលនៃបណ្ដឹងឧទ្ធរណ៍ ....................................................................... ៣៣
៣.៣.អានុភាពនៃបណ្ដឹងឧទ្ធរណ៍ ....................................................................... ៣៣

## ជំពូកទី៣

## សភាស៊ើបសួរនៃសាលាឧទ្ធរណ៍

**ផ្នែកទី១៖ សញ្ញាណទូទៅនៃសភាស៊ើបសួរ**.....................................................................៣៦
កថាខណ្ឌទី១៖ សមត្ថកិច្ចរបស់សភាស៊ើបសួរ.......................................................................៣៦
១.១.ការត្រួតពិនិត្យនិយ័តភាពនៃកិច្ចស៊ើបសួររបស់មន្ទីរស៊ើបសួរ ......................................៣៦
១.២.កិច្ចស៊ើបសួរបន្ថែម......................................................................................................៣៦
១.៣.ការពន្លាតការចោទប្រកាន់ទៅលើបទល្មើសផ្សេងទៀត ............................................ ៣៧
១.៤.ការពិនិត្យមោឃភាពកិច្ចស៊ើបសួរ ........................................................................... ៣៧
១.៤.១.មោឃភាពកិច្ចនីតិវិធីដោយការមិនគោរពវិធាន ..............................................៣៨
១.៤.២.មោឃភាពកិច្ចនីតិវិធីដោយការប្ដឹងទៅសភាស៊ើបសួរ........................................៣៩
កថាខណ្ឌទី២៖ អំណាចផ្ទាល់ខ្លួនរបស់ប្រធានសភាស៊ើបសួរ ...............................................៣៩
២.១.ការធានានូវរដ្ឋបាលយុត្តិធម៌ល្អនៃមន្ទីរស៊ើបសួរ .........................................................៣៩
២.២.អធិការកិច្ចមន្ទីស៊ើបសួរ...............................................................................................៣៩
២.៣.ការធ្វើអធិបញ្ញាឲ្យសម្រេចលើបណ្ដឹងសុំបិទសំណុំរឿង.................................................៤០
**ផ្នែកទី២៖ ដំណើរការសវនការរបស់សភាស៊ើបសួរ**...................................................................... ៤០
កថាខណ្ឌទី១៖ នីតិវិធីមុនពេលសវនាការ ..........................................................................៤០
១.១.ការទទួល និងពិនិត្យសំណុំរឿង.....................................................................................៤០
១.២.ការកំណត់កាលបរិច្ឆេទសវនាការ ...................................................................................៤០
១.៣.ការពិគ្រោះសំណុំរឿង និងពិនិត្យសារណា........................................................................៤១
កថាខណ្ឌទី២៖ នីតិវិធីពេលសវនាការ..................................................................................៤១
២.១.កិច្ចពិភាក្សាដេញដោល ............................................................................................ ៤១
២.២.ការប្រកាសសាលដីកា....................................................................................................៤១

កថាខណ្ឌទី៣៖ នីតិវិធីក្រោយពេលសវនាការ........................................................................៤២
៣.១.សាលដីកាសម្រេចតម្កល់ដីការបស់ចៅក្រមស៊ើបសួរ................................................ ៤២
៣.២.សាលដីកាសម្រេចបដិសេធដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ...................................៤២
៣.៣.សាលដីកាសម្រេចអំពីភាពមិនអាចទទួលបាននៃពាក្យសុំមោឃភាព............................៤៣
**សេចក្តីសន្និដ្ឋាន** ...................................................................................................................៤៤
**អនុសាសន៍** ...........................................................................................................................៤៧
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ប្រទេសកម្ពុជាគឺ ជាប្រទេសមួយដែលទើបតែរួចផុតពីសង្គ្រាមស៊ីវិល ដែលជាមូលហេតុធ្វើឲ្យកម្ពុជាមានការអភិវឌ្ឍន៍យឺតជាប្រទេសដទៃ។ កម្ពុជាបានឆ្លងកាត់នូវរបបកម្ពុជាប្រជាធិប្បតេយ្យ ឬប៉ុលពត ។ របបនេះជារបបដែលឃោរឃៅយង់ខ្នង់ បានសម្លាប់ប្រជាជនខ្មែរប្រមាណ ១ លាន ៧ សែននាក់ ព្រមទាំងបានបំផ្លិចបំផ្លាញខ្ទេចខ្ទីនូវសេដ្ឋកិច្ច នយោបាយ ហេដ្ឋារចនាសម្ព័ន្ធ គមនាគមន៍ ហើយនឹងបានកម្ទេច រចនាសម្ព័ន្ធនីត្យានុកូល តុលាការគ្មានការជុំនំជម្រះក្តីអ្វីទាំងអស់។ បន្ទាប់ពីរបបកម្ពុជាប្រជាធិប្បតេយ្យដួលរលំ កម្ពុជាបានរងនូវការខូចខាតយ៉ាងធ្ងន់ធ្ងរ បាត់បង់នូវឯកសារច្បាប់ ធនធានមនុស្ស ប្រពន្ធ័យុត្តិធម៌ ដែលជាកត្តានាំឲ្យប្រទេសជាតិក្លាយទៅជាអសន្តិសុខ គ្មានសណ្តាប់ធ្នាប់ សីលធម៌សង្គមធ្លាក់ចុះ ការកើនឡើងនៃអំពើអនីត្យានុកូល។ បើទោះបីជារបបនេះបានបញ្ចប់ក្តី ហើយមានរបបថ្មីមកជំនួសក៏ដោយកម្ពុជានៅតែពុំទាន់មានភាពប្រសើរឡើងនូវគ្រប់វិស័យជាពិសេសរចនាសម្ព័នច្បាប់ និងប្រព័ន្ធតុលាការ ដើម្បីបម្រើដល់សង្គមជាតិនៅឡើយទេ។ រហូតមកដល់ឆ្នាំ ១៩៩៣ ជាឆ្នាំដែលកម្ពុជាមានការបោះឆ្នោតជាលើកដំបូង ក្រោមការរៀបចំរបស់អាជ្ញាធរជាបណ្តោះអាសន្ន ឬអ៊ុនតាក់ ត្រូវបានបង្កើតឡើងដោយអង្គការសហប្រជាជាតិ ស្របតាមមាត្រា ៦ នៃកិច្ចព្រមព្រៀងស្តីពីនយោបាយរួមនៃជម្លោះកម្ពុជា។ ក្រោយពីការរៀបចំការបោះឆ្នោតដោយអ៊ុនតាក់មកកម្ពុជាបានបង្កើតឲ្យមានការរស់រាននូវរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញតាមរយៈរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣។ ដើម្បីធ្វើឲ្យប្រទេសកម្ពុជា វិលត្រឡប់មករកសន្តិសុខ ទប់ស្កាត់អំពើអនីត្យានុកូលនានា និងពង្រឹងប្រព័ន្ធយុត្តិធម៌ឲ្យមានប្រសិទ្ធភាព។ អ៊ុនតាក់ បានបង្កើតបទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ សម្រាប់អនុវត្តក្នុងសម័យការអន្តរការណ៍ ឬហៅកាត់ថា ច្បាប់ព្រហ្មទណ្ឌអន្តរកាល។

ក្នុងឆ្នាំ ១៩៩៤ ក្រសួងយុត្តិធ៌មបានចាប់ផ្តើមរៀបចំកែសម្រួលក្រមនីតិវិធីព្រហ្មទណ្ឌឡើងវិញ។ ដោយការខិតខំប្រឹងប្រែង យ៉ាងមុតមាំ រហូតបានសម្រេចនូវសមិទ្ធផលដែលជាក្រមនីតិវិធីព្រហ្មទណ្ឌបានប្រកាសឲ្យប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។ ក្រមនីតិវិធីព្រហ្មទណ្ឌជាឧបករណ៍ដ៏សំខាន់របស់តុលាការផ្នែកព្រហទណ្ឌក្នុងគោលបំណងស្វែងរកការពិត ដើម្បីធានាថាការវិនិច្ឆ័យសម្រេចសេចក្តីប្រកបដោយយុត្តិធម៌ ហើយជាអត្ថបទច្បាប់មួយមានភាពច្បាស់លាស់ ដោយបានប្រកាន់ភ្ជាប់នូវគោលការណ៍ នៃច្បាប់ព្រហទណ្ឌអន្តរកាលឆ្នាំ ១៩៩៣ ព្រមទាំងគោរពសេរីភាពបុគ្គលស្របតាម សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និង រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាជាមូលដ្ឋាននៃការកសាងនីតិរដ្ឋនៅកម្ពុជាផងដែរ។

ក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តិដំណើរនីតិវិធីសំខាន់ៗដូចជា ដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ដំណាក់កាលអយ្យការ ដំណាក់កាលចៅក្រមស៊ើបសួរ ដំណាក់កាលចៅក្រមជំនុំជម្រះ។ ម្យ៉ាងវិញទៀតក្រមនេះក៏បានកំណត់នូវសិទ្ធិ និងកាតព្វកិច្ចរបស់ភាគី ឬបុគ្គលដែលពាក់ព័ន្ធ ក្នុងសុំណុំរឿងដោយផ្តល់សិទ្ធិ ប្តឹងតវ៉ា ផ្សេងៗ។ ការប្តឹងតវ៉ានេះអាចធ្វើឡើងក្នុងដំណាក់កាលស៊ើបអង្កេត និងដំណាក់កាលស៊ើបសួរ បណ្តឹងតវ៉ានេះគឺ បណ្តឹងតវ៉ា

ចំពោះសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរ ដែលស្តែងចេញតាមរយៈដីកាសម្រេច ។ ចៅក្រមស៊ើបសួរ មានតួនាទីភារកិច្ចក្នុងការស៊ើបសួរដើម្បីស្វែងរកការពិត និងស្រាវជ្រាវស្វែងរកភស្តុតាងក្នុងការដាក់បន្ទុក ឬដោះបន្ទុក។ នៅដំណាក់ការនេះផងដែរប្រសិនបើភាគី ឬបុគ្គលដែលពាក់ព័ន្ធ ក្នុងសុំណុំរឿងហើយភាគីទាំងនោះរួមមាន ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងព្រះរាជអាជ្ញា មិនសុខចិត្ត ឬយល់ឃើញថានីតិវិធីនៃកិច្ចស៊ើបសួរមានភាពមិនប្រក្រតី អនុវត្តខុសនឹងអ្វីដែលក្រមនីតិវិធីបានកំណត់ អាចធ្វើបណ្តឹងតវ៉ាទៅសភាស៊ើបសួរសាលាឧទ្ធរណ៍បាន ដែលហៅថា " **បណ្តឹងឧទ្ធរណ៍នឹងដីកាសម្រេចរបស់ចៅក្រមស៊ើបសួរទៅសភាស៊ើបសួរ** " ។

# ជំពូកទី១
# ចៅក្រមស៊ើបសួរ

# ជំពូកទី១
# ចៅក្រមស៊ើបសួរ

## ផ្នែកទី១៖ សញ្ញាណទូទៅនៃចៅក្រមស៊ើបសួរ

### កថាខណ្ឌទី១៖ គោលការណ៍នៃការស៊ើបសួរ

#### ១.១. ការសម្ងាត់នៃការស៊ើបសួរ

ការស៊ើបសួរត្រូវតែធ្វើឡើងជាសម្ងាត់។ បុគ្គលទាំងឡាយណាដែលចូលរួមក្នុងការស៊ើបសួរ ជាពិសេស ចៅក្រម មេធាវី ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ មន្ត្រីរាជការ អ្នកជំនាញ អ្នកបកប្រែ គ្រូពេទ្យ និងបុគ្គលដែលមានសមត្ថកិច្ច ត្រូវរក្សាការសម្ងាត់នៃវិជ្ជាជីវៈ។ ប៉ុន្តែការគោរពនូវការសម្ងាត់វិជ្ជាជីវៈមិនអាចជាឧបសគ្គដល់ការប្រើសិទ្ធិនៃការការពារខ្លួនឡើយ។ ម្យ៉ាងទៀតព្រះរាជអាជ្ញាធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈកាលណាខ្លួនយល់ឃើញថា ព័ត៌មានដែលបានផ្សព្វផ្សាយពីរឿងណាមួយនោះ ជាព័ត៌មានមិនពិត ការបំពានលើការសម្ងាត់នៃការស៊ើបសួរគឺជាបទល្មើសដែលត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន។[1] ការបើកការស៊ើបសួរមានត្រូវតែធ្វើដោយខាន មិនបានចំពោះបទឧក្រិដ្ឋ។[2] ចំពោះបទមជ្ឈិម ការបើកការស៊ើបសួរ អាចធ្វើទៅបានក្នុងករណីសំណុំរឿងនោះមានលក្ខណៈស្មុគស្មាញ មានភាពលំបាក ដែលនាំឲ្យដំណើរការនៃការស្រាវជ្រាវប្រព្រឹត្តិទៅយូរជាងបទល្មើសដែលមានភស្តុតាងគ្រប់គ្រាន់អាចបញ្ជូនទៅជំនុំជម្រះផ្ទាល់។

#### ១.២. ការស៊ើបសួរដាក់បន្ទុក និងដោះបន្ទុក

ចៅក្រមស៊ើបសួរបំពេញកិច្ចស៊ើបសួរទាំងអស់ដែលខ្លួនយល់ឃើញថា មានប្រយោជន៍សម្រាប់បង្ហាញឲ្យឃើញការពិតដោយអនុលោមតាមច្បាប់។ ចៅក្រមស៊ើបសួរមានករណីកិច្ចស៊ើបសួរដាក់បន្ទុក និងដោះបន្ទុក។ ការបើកការស៊ើបសួរត្រូវស្វែងរកទាំងភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក ។[3] ជាទូទៅជនដែលត្រូវបាននគរបាលយុត្តិធម៌ធ្វើការឃាត់ខ្លួន និងកសាងសំណុំរឿងបញ្ជូនទៅស្ថាប័នអយ្យការ ហើយត្រូវបានព្រះរាជអាជ្ញាសម្រេចចោទប្រកាន់ ពីបទល្មើសព្រហ្មទណ្ឌណាមួយនោះ លុះត្រាតែមានភស្តុតាងដាក់បន្ទុកចំពោះជនដែលត្រូវបានឃាត់ខ្លួននោះ ប្រសិនបើគ្មានភស្តុតាងណាមួយដើម្បីដាក់បន្ទុក ឬភស្តុតាងណាមួយបញ្ជាក់ថាជននោះបានប្រព្រឹត្តបទល្មើសទេ គឺតំណាងអយ្យការ មិនអាចធ្វើការចោទប្រកាន់បានឡើយ ព្រោះថានៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ មាត្រា៣៨ បានការពារនូវកត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ។[4] ដោយឡែកចំពោះការស៊ើបសួរដោះបន្ទុក គឺធ្វើឡើងដើម្បីជួយដោះបន្ទុកចំពោះជនដែលត្រូវរងនូវការចោទប្រកាន់ពីស្ថាប័នអយ្យការ (ជនត្រូវចោទ) ។ ក្នុងន័យនេះ ប្រសិនបើចៅក្រមស៊ើបសួរបានធ្វើការស៊ើបសួរទៅរកឃើញថា អំពើដែលជននោះ

[1] មាត្រា១២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[2] មាត្រា១២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[3] មាត្រា១២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[4] មាត្រា៣៩ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

(ជនត្រូវចោទ) បានប្រព្រឹត្តមិនមែនជាបទល្មើសព្រហ្មទណ្ឌ ឬគ្មានភស្តុតាងគ្រប់គ្រាន់នោះទេ ជនត្រូវចោទនឹងបាន រួចផុតពីការចោទប្រកាន់តាមរយៈដីកាលើកលែងចោទប្រកាន់ ។

## កថាខណ្ឌទី២៖ សមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ

### ២.១. សមត្ថកិច្ចដែនដី

មន្ទីរស៊ើបសួរនៃសាលាដំបូង គឺជាផ្នែកមួយនៃតុលាការព្រហ្មទណ្ឌ និងមានសមត្ថកិច្ចស៊ើបសួរ រឿងក្ដីព្រហ្មទណ្ឌ ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីព្រហ្មទណ្ឌ ។ ប្រធានសាលាដំបូងត្រូវចាត់តាំង ចៅក្រមយ៉ាងតិច ០២ (ពីរ) រូប តាមដីកាសម្រេចឲ្យបំពេញតួនាទីជា ចៅក្រមស៊ើបសួរនៅមន្ទីរស៊ើបសួរនៃតុលាការព្រហ្មទណ្ឌនៃសាលាដំបូង ។ ដីកាសម្រេចនេះ ត្រូវកំណត់ផងដែរអំពីលំដាប់លេខរៀង សម្រាប់ការទទួលបំពេញការងារ ។ ក្នុងករណីពុំមានចៅក្រមស៊ើបសួរ ឬខ្វះចៅក្រមស៊ើបសួរ ប្រធានសាលាដំបូងអាចចាត់តាំងចៅក្រមនៃតុលាការជំនាញផ្សេង ដើម្បីបំពេញមុខងារស៊ើបសួរបាន ។[5]

ចៅក្រមដែលមានសមត្ថកិច្ចគឺ ចៅក្រមស៊ើបសួរទីកន្លែងបទល្មើស។ ចៅក្រមស៊ើបសួរនាទីលំនៅឋាន ឬទីសំណាក់របស់បុគ្គលដែលបានសង្ស័យថាបានប្រព្រឹត្តបទល្មើស។ ចៅក្រមស៊ើបសួរនាទីកន្លែងចាប់ខ្លួនបុគ្គលដែលបានសង្ស័យថាបានប្រព្រឹត្តបទល្មើស។ ប្រសិនបើមានទំនាស់រវាងចៅក្រមស៊ើបសួរច្រើនរូបនៅសាលាដំបូងខុសៗគ្នា ហើយទទួលបណ្ដឹងទាំងអស់គ្នាអំពីរឿងព្រហ្មទណ្ឌតែមួយ ទំនាស់នេះត្រូវបញ្ជូនទៅប្រធានសភាស៊ើបសួរដើម្បីសម្រេច។ វិវាទសមត្ថកិច្ចដែនដីរវាងសភាស៊ើបសួរ ច្រើនរូបត្រូវសម្រេចដោយប្រធានតុលាការកំពូលការសម្រេចនេះបិទផ្លូវតវ៉ា។[6]

### ២.២. សមត្ថកិច្ចតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

ការស៊ើបសួរត្រូវបើកតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដែលត្រូវប្ដឹងទៅចៅក្រមស៊ើបសួរ។ ការស៊ើបសួរអាចធ្វើទៅបានលុះត្រាតែទទួលបានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរពីព្រះរាជអាជ្ញា ប្រសិនបើគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរពីព្រះរាជអាជ្ញានោះទេ ចៅក្រមស៊ើបសួរមិនអាចបំពេញកិច្ចស៊ើបសួរណាមួយបានឡើយ។[7] ការបើកការស៊ើបសួរអាចបើកប្រឆាំងនឹងបុគ្គលម្នាក់ ឬច្រើននាក់ ដោយមានការចង្អុលបង្ហាញប្រាប់ឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬប្រឆាំងនឹងអញ្ញាតជន។[8] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររួមមាន៖

-សេចក្តីសង្ខេបនៃអង្គហេតុ

-ការកំណត់ឈ្មោះបទល្មើស

-ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស និង

[5] មាត្រា២០ កថាខណ្ឌទី៣ នៃច្បាប់ស្តីការរៀបចំអង្គការតុលាការ ឆ្នាំ ២០១៤

[6] មាត្រា១២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[7] មាត្រា១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[8] មាត្រា៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

-ឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរ ប្រសិនបើអាចកំណត់បាន។

ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខា។ ទម្រង់នេះមានលក្ខណៈដាច់ខាតត្រូវតែគោរព បើពុំដូច្នេះទេ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនោះត្រូវចាត់ទុកជាមោឃៈ។

ក្នុងច្បាប់ប្រសិនបើមានការប្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចៅក្រមស៊ើបសួរអាចអនុលោមតាមនីតិវិធីពិសេស គឺជនរងគ្រោះអាចធ្វើបណ្ដឹងចំនួនពីរប្រភេទ បណ្ដឹងដែលមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីតាមផ្លូវអន្ដរាគមន៍ និងបណ្ដឹងដែលមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។ កាលបើចៅក្រមស៊ើបសួរ ទទួលបណ្ដឹងដែលមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីតាមផ្លូវអន្ដរាគមន៍ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងអំពីការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីតាមផ្លូវអន្ដរាគមន៍នេះដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។ បណ្ដឹងដែលមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីតាមផ្លូវអន្ដរាគមន៍អាចធ្វើដោយផ្ទាល់មាត់ ឬអាចធ្វើជាលាយលក្ខណ៍អក្សរ ប្រសិនបើធ្វើដោយផ្ទាល់មាត់ ចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុ បើធ្វើជាលិខិតលាយលក្ខណ៍អក្សរ លិខិតជាលាយលក្ខណ៍អក្សរនេះត្រូវដាក់ទុកនៅក្នុងសំណុំរឿង។

បើចៅក្រមស៊ើបសួរទទួលបណ្ដឹងដែលមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចៅក្រមស៊ើបសួរត្រូវបញ្ជូនបណ្ដឹងនេះទៅព្រះរាជអាជ្ញា ។ ក្រោយពីព្រះរាជអាជ្ញាបានទទួលពាក្យបណ្ដឹងនេះរួចហើយ ព្រះរាជអាជ្ញាត្រូវប្ដឹងទៅចៅក្រមស៊ើបសួរតាមរយៈដីកាសិន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថាអំពើនេះជាបទល្មើស និងមិនទាន់ផុតរលត់នូវអាជ្ញាយុកាលដើម្បីចោទប្រកាន់ទៅលើបុគ្គលម្នាក់ ឬច្រើននាក់។ ប៉ុន្តែប្រសិនបើក្នុងករណីដែលព្រះរាជអាជ្ញាយល់ឃើញថាអំពើនេះមិនមែនជាបទល្មើសទេ និងផុតអាជ្ញាយុកាលហើយ ព្រះរាជអាជ្ញាអាចសុំឲ្យចៅក្រមស៊ើបសួរកុំឲ្យបើកការស៊ើបសួរ។

ក្រោយពីឆ្លងកាត់នីតិវិធីរួចហើយ បើចៅក្រមស៊ើបសួរសម្រេចសម្រេចមិនស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុ ហើយត្រូវជូនដំណឹងជាបន្ទាន់ទៅព្រះរាជអាជ្ញា ។ ប៉ុន្តែប្រសិនបើចៅក្រមស៊ើបសួរនៅតែសម្រេចស៊ើបសួរ ចៅក្រមនេះត្រូវជូនដំណឹងជាបន្ទាន់ទៅកាន់ព្រះរាជអាជ្ញា។ គួរកត់សម្គាល់ថាបណ្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ជាបណ្ដឹងមួយថ្មីដែលទើបតែបញ្ចូលក្នុងក្រមព្រហ្មទណ្ឌថ្មីនេះឯង ហើយដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបង់នូវប្រាក់តម្កល់ទុកតាមការកំណត់របស់ចៅក្រមស៊ើបសួរ តាមដីកាសម្រេចដោយផ្អែកលើធនធាននៃដើមបណ្ដឹងរដ្ឋប្បវេណី និងទៅលើការលំបាកនៃរឿងក្ដីដែលអាចមើលឃើញជាមុន តែចៅក្រមស៊ើបសួរក៏អាចលើកលែងមិនឲ្យបង់ប្រាក់នេះបានដែរ ។ ប្រសិនបើចៅក្រមស៊ើបសួរ តម្រូវឲ្យបង់ប្រាក់តម្កល់ទុកតែដើមបណ្ដឹងរដ្ឋប្បវេណី ពុំព្រមបង់ប្រាក់ក្នុងរយៈពេលកំណត់ដោយចៅក្រមទេ ចៅក្រមស៊ើបសួរត្រូវប្រកាសថាមិនអាចទទួលពាក្យប្ដឹងនេះបាន។ ការតម្រូវឲ្យបង់ប្រាក់តម្កល់ទុក គឺដើម្បីធានាការបង់ប្រាក់ពិន័យរដ្ឋប្បវេណី ប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថា នីតិវិធីធ្វើឡើងដោយរំលោភ ឬដោយអូសបន្លាយ ពេលវេលាដែលចៅក្រមស៊ើបសួរចេញដីកាសម្រេចឲ្យបង់ប្រាក់ពិន័យរដ្ឋប្បវេណី តាមមាត្រា១៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ តែប្រាក់

ពិន័យនេះពុំអាចលើសចំនួនទឹកប្រាក់តម្កល់ទុកបានឡើយ។ ផ្ទុយទៅវិញ ប្រសិនបើពុំត្រូវបង់ប្រាក់ពិន័យរដ្ឋប្បវេណីទេ ប្រាក់តម្កល់ទុកនេះ ត្រូវបង្វិលទៅឲ្យសាមីខ្លួនវិញនៅពេលបញ្ចប់នីតិវិធី ។[9] ម្យ៉ាងវិញទៀត ដោយយោងទៅលើសមត្ថកិច្ចចងដោយដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរពុំអាចស៊ើបសួរទៅលើអង្គហេតុ ដែលពុំមាននៅក្នុងដីកាសន្និដ្ឋាននេះឡើយ។ មាត្រា១២៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថា ចៅក្រមស៊ើបសួរទទួលបណ្តឹងអំពីអង្គហេតុ ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។ ចៅក្រមស៊ើបសួរត្រូវស៊ើបសួរតែអំពីអង្គហេតុនោះប៉ុណ្ណោះ ។[10]

## កថាខណ្ឌ៣៖ វិធានការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ

### ៣.១. ការដាក់ជនត្រូវចោទឲ្យស្ថិតក្រោមការត្រួតពិនិត្យ

បុគ្គលដែលបានចង្អុលប្រាប់ឈ្មោះ នៅក្នុងដីកាសន្និដ្ឋានបញ្ជូលរឿងឲស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវតែដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យ។ មានតែចៅក្រមស៊ើបសួរប៉ុណ្ណោះមានអំណាចដាក់ឲស្ថិតនៅក្រោមការត្រួតពិនិត្យនូវបុគ្គលគ្រប់រូប ដែលតម្រុយច្បាស់លាស់ ហើយស៊ីចង្វាក់គ្នាយ៉ាងខ្លាំងថា បានចូលរួមប្រព្រឹត្តបទល្មើសទោះបីជាគ្មានការចង្អុលប្រាប់ឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូលរឿងឲ្យស៊ើបសួរក៏ដោយ។ ចៅក្រមស៊ើបសួរអាចដាក់បុគ្គលនោះឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យក្នុងឋានៈជាចារី ជាអ្នកផ្តើមគំនិត ឬជាអ្នកសមគំនិត ។ [11] នៅពេលចូលបង្ហាញខ្លួនលើកដំបូង ចៅក្រមស៊ើបសួរពិនិត្យអត្តសញ្ញាណជនត្រូវចោទ ប្រាប់ជននេះឲ្យបានដឹងរឿងរ៉ាវដែលចោទប្រកាន់ និងប្រាប់អំពីឈ្មោះបទល្មើសដែលកំណត់ដោយច្បាប់ ។ ចៅក្រមស៊ើបសួរប្រាប់ជនត្រូវចោទថា ខ្លួនអាចឆ្លើយ ឬមិនឆ្លើយបានដោយសេរី។ និទ្ទេសស្តីពីការប្រាប់នេះត្រូវចុះនៅក្នុងកំណត់ហេតុ នៅពេលចូលបង្ហាញខ្លួនលើកដំបូង។ ប្រសិនបើជនត្រូវចោទចង់ឆ្លើយនោះ ចៅក្រមស៊ើបសួរត្រូវទទួលចម្លើយនោះភ្លាម ។ ចៅក្រមស៊ើបសួរ ប្រាប់ជនត្រូវចោទឲ្យបានដឹងអំពីសិទ្ធិរបស់ខ្លួនក្នុងការជ្រើសរើសមេធាវី ឬក្នុងការសុំឱ្យចាត់តាំងមេធាវីឲ្យខ្លួន ដោយអនុវត្តតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ។ ជនត្រូវចោទជាអនីតិជនត្រូវតែមានមេធាវីអមជានិច្ច ។ បើគ្មានការជ្រើសរើសដោយជនត្រូវចោទទេ មេធាវីត្រូវបានចាត់តាំងនៅក្នុងលក្ខខណ្ឌដែលចែងដោយច្បាប់ស្តីអំពីលក្ខន្តិកៈមេធាវី។ ក្រោយពីការចូលបង្ហាញខ្លួនលើកទីមួយ ជនត្រូវចោទដែលនៅក្រៅឃុំ ត្រូវប្រកាសប្រាប់ដល់ចៅក្រមស៊ើបសួរអំពីអាសយដ្ឋានរបស់ខ្លួន ។ ជនត្រូវចោទនេះត្រូវបានទទួលដំណឹងថា :

-ខ្លួនត្រូវតែជូនព័ត៌មាន ដល់ចៅក្រមស៊ើបសួរ នៅពេលណាដែលខ្លួនផ្លាស់ប្តូរអាសយដ្ឋាន

-គ្រប់ការឲ្យដំណឹងដែលបានធ្វើឡើងតាមអាសយដ្ឋានចុងក្រោយ ដែលប្រកាសឡើងដោយជនត្រូវចោទនោះត្រូវចាត់ទុកថាបានធ្វើឡើងដល់សាមីខ្លួនផ្ទាល់ ។

[9] មាត្រា១៤០ កថាខណ្ឌទី៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[10] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មេរៀនចៅក្រមស៊ើបសួរ បង្រៀនដោយ លោក សាស្ត្រាចារ្យ មីន សំអុល

[11] មាត្រា១២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

ការឲ្យដំណឹងព្រមទាំងការប្រកាសស្តីអំពីការផ្លាស់ប្តូរអាសយដ្ឋាននោះ ត្រូវចុះក្នុងកំណត់ហេតុនៅពេលចូលបង្ហាញខ្លួនលើកដំបូង ។[12]

ក្នុងករណីចាំបាច់ចៅក្រមស៊ើបសួរត្រូវហៅរកអ្នកបកប្រែ ។ អ្នកបកប្រែត្រូវស្បថស្របតាមសាសនា ឬជំនឿរបស់ខ្លួនថានឹងជួយដល់តុលាការ នឹងបកប្រែឲ្យបានត្រឹមត្រូវតាមចម្លើយទាំងឡាយ ។ ក្នុងករណីណាក៏ដោយ អ្នកបកប្រែមិនអាចត្រូវជ្រើសរើសក្នុងចំណោមចៅក្រម ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ ភាគី ឬ សាក្សីទេ។[13]

### ៣.២. ការសួរចម្លើយជនត្រូវចោទ

កាលណាជនត្រូវចោទមានមេធាវីអម ចៅក្រមស៊ើបសួរ ត្រូវកោះហៅមេធាវីយ៉ាងតិចបំផុត ៥ (ប្រាំ) ថ្ងៃ មុនការសួរចម្លើយ។ ក្នុងចិរវេលានេះ មេធាវីអាចពិនិត្យមើលសំណុំរឿងនៃនីតិវិធី។ ជនត្រូវចោទអាចត្រូវសួរចម្លើយបានតែនៅចំពោះមុខមេធាវីរបស់ខ្លួនតែប៉ុណ្ណោះ។ ប៉ុន្តែ ប្រសិនបើមេធាវីដែលត្រូវបានកោះហៅយ៉ាងត្រឹមត្រូវហើយ មិនចូលបង្ហាញខ្លួននៅថ្ងៃ និងម៉ោងកំណត់ទេ ចៅក្រមស៊ើបសួរអាចសួរចម្លើយជនត្រូវចោទ ដោយគ្មានវត្តមានរបស់មេធាវី។ បើជនត្រូវចោទជាអនីតិជន ចាំបាច់ត្រូវតែមានមេធាវីអមជាដាច់ខាត។ និទ្ទេសស្តីអំពី អវត្តមាននេះត្រូវចុះនៅក្នុងកំណត់ហេតុសួរចម្លើយជនត្រូវចោទ។ ក្នុងករណីពិសេស ចៅក្រមស៊ើបសួរ អាចសួរចម្លើយជនត្រូវចោទដោយមិនបាច់កោះហៅមេធាវី ប្រសិនបើជនត្រូវចោទបោះបង់ ចោលយ៉ាងជាក់លាក់នូវវត្តមានរបស់មេធាវីខ្លួន។ ការបោះបង់ចោលនេះ ត្រូវចុះនៅក្នុងកំណត់ហេតុផ្សេងពីកំណត់ហេតុសួរចម្លើយ និងត្រូវចុះហត្ថលេខាដោយជនត្រូវចោទ។ ក្នុងករណីបន្ទាន់ ចៅក្រមស៊ើបសួរក៏អាចធ្វើការសួរចម្លើយដោយមិនបាច់កោះហៅមេធាវីបានដែរ។ ភាពបន្ទាន់ នេះត្រូវតែបណ្តាលមកពីគ្រោះថ្នាក់ដល់ស្លាប់ ឬបណ្តាលមកពីការភ័យខ្លាចបាត់បង់តម្រុយនៃភស្តុតាង។[14] ប្រភេទនៃភាពបន្ទាន់ ត្រូវតែចុះនិទ្ទេសនៅក្នុងកំណត់ហេតុ។ ចៅក្រមស៊ើបសួរអាចហៅ រកអ្នកបកប្រែបាន ដូចដែលមានចែងក្នុងមាត្រា១៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

នៅពេលសួរចម្លើយជនត្រូវចោទ ព្រះរាជអាជ្ញា និងមេធាវីក៏អាចលើកសំណួរបានដែរ ដោយមានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។ ក្នុងករណីមិនអនុញ្ញាត ករណីនេះត្រូវចុះនិទ្ទេសនៅ ក្នុងកំណត់ហេតុ។[15]

កាលណាចិរវេលា ៤ (បួន) ខែ បានកន្លងផុតទៅ ចាប់ពីពេលសួរចម្លើយនៅពេលបង្ហាញ ខ្លួនលើកដំបូង ជនត្រូវចោទមិនត្រូវបានសួរចម្លើយ ឬសួរតទល់ទេ ចៅក្រមស៊ើបសួរត្រូវតែទទួលចម្លើយ ប្រសិនបើជនត្រូវចោទបានស្នើសុំ។ បើចៅក្រមស៊ើបសួរមិនព្រមកោះហៅជនត្រូវចោទក្នុង ចិរវេលា ១ (មួយ) ខែ បន្ទាប់ពីការសុំទេ

[12] មាត្រា១៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[13] មាត្រា១៤៤នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[14] មាត្រា១៤៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[15] មាត្រា១៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

នោះជនត្រូវចោទ អាចប្តឹងផ្ទាល់ទៅសភាស៊ើបសួរដែល ទទួលចម្លើយនេះដោយខ្លួនឯង។ បន្ទាប់មកកំណត់ហេតុត្រូវបញ្ជូនទៅចៅក្រមស៊ើបសួរ។[16]

មេធាវីរបស់ជនត្រូវចោទដែលជាប់ឃុំ អាចប្រាស្រ័យទាក់ទងដោយសេរីជាមួយកូនក្តីរបស់ ខ្លួននៅក្នុងពន្ធនាគារ ឬនៅក្នុងមណ្ឌលឃុំខ្លួន។ ការសន្ទនារវាងមេធាវី និងជនត្រូវចោទមិនអាច ត្រូវបានគេស្តាប់ ឬ ថតបានទេ។ មេធាវីអាចអានលិខិតនៃសំណុំរឿងឱ្យកូនក្តីខ្លួនស្តាប់។ ផ្ទុយទៅវិញ មេធាវីមិនអាចឲ្យចម្លងលិខិតថតចម្លងពីលិខិតនៃសំណុំរឿងដល់កូនក្តីរបស់ខ្លួនបានឡើយ។[17] ការពិភាក្សាដេញដោល ឬការសួរតទល់ ការសួរតទល់គ្នា គឺជាការសួរចម្លើយ ឬការស្តាប់ចម្លើយបុគ្គលជាច្រើនព្រមគ្នាក្នុងគោលដៅធ្វើឲ្យស្តែងចេញនូវធាតុនៃការពិត តាមរយៈយោបល់ រួមទាំងចម្លើយ និងជំហាររបស់បុគ្គលម្នាក់ៗ ដែលចៅក្រមដាក់តទល់គ្នានោះ ។ បទបញ្ញត្តិនៃមាត្រា ១៤៥( វត្តមានមេធាវីក្នុងពេលសួរចម្លើយ) និង មាត្រា ១៤៦ (សំណួរដោយមានការអនុញ្ញាតពីចៅក្រមស៊ើបសួរ ) នៃក្រមនីតិវិធីព្រហ្មទណ្ឌយកមកអនុវត្ត។ [18]

### ៣.៣. ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី

ដើមបណ្តឹងរដ្ឋប្បវេណី មានសិទ្ធិទទួលបានការការពារខ្លួនដោយអាចមានមេធាវីអម ចៅក្រមស៊ើបសួរត្រូវកោះហៅមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីយ៉ាងតិចបំផុត៥ ( ប្រាំ ) ថ្ងៃ មុនថ្ងៃស្តាប់ចម្លើយ ហើយក្នុងចិរវេលានេះ មេធាវីអាចពិនិត្យសំណុំរឿងនៃនីតិវិធីបាន។ ការស្តាប់ចម្លើយត្រូវធ្វើនៅចំពោះមុខមេធាវី ប៉ុន្តែប្រសិនបើមេធាវីមិនបានចូលបង្ហាញខ្លួនតាមការកោះហៅនៅថ្ងៃ និងម៉ោងតាមកំណត់ទេ ចៅក្រមស៊ើបសួរអាចស្តាប់ចម្លើយដោយគ្មានវត្តមានរបស់មេធាវី ។ ម្យ៉ាងវិញទៀត ក្នុងករណីពិសេសចៅក្រមស៊ើបសួរ អាចស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីបានដោយមិនបាច់កោះហៅមេធាវី ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីបោះបង់ចោលយ៉ាងជាក់លាក់នូវវត្តមានមេធាវីខ្លួន។ ការសួរចម្លើយដោយមាន ឬគ្មានវត្តមានមេធាវីត្រូវធ្វើការចុះនិទ្ទេសនៅក្នុងកំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងចុះហត្ថលេខាដោយដើមបណ្តឹងរដ្ឋប្បវេណី។ ចៅក្រមស៊ើបសួរ អាចសួរចម្លើយដើមបណ្តឹងរដ្ឋប្បវេណីដោយមិនចាំបាច់កោះហៅមេធាវី ប្រសិនកាលៈទេសៈតម្រូវ ដោយមានភាពបន្ទាន់ ត្រូវបណ្តាលមកពីគ្រោះថ្នាក់ដល់ស្លាប់ ឬ បណ្តាលមកពីភ័យខ្លាចបាត់បង់តម្រុយ ឬភស្តុតាង។ ប្រភេទនៃភាពបន្ទាន់នេះត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុ។[19] ដោយឡែកចំពោះបុគ្គលដែលបានស្ថិតក្នុងហេតុការណ៍ ឬបុគ្គលដែលចៅក្រមស៊ើបសួរអាចមានប្រយោជន៍ក្នុងការសំដែងការពិត និងទទួលបានតម្រុយបន្ថែមដល់សំណុំរឿង នោះចៅក្រមស៊ើបសួរអាចស្តាប់ចម្លើយបុគ្គលទាំងនោះក្នុងនាមជាសាក្សី។ បុគ្គលគ្រប់រូបដែលត្រូវបានចៅក្រមស៊ើបសួរកោះហៅក្នុងនាមជា

[16] មាត្រា១៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[17] មាត្រា១៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[18] មាត្រា១៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[19] មាត្រា១៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

សាក្សី ត្រូវតែបង្ហាញខ្លួន ប្រសិនរឹងទទឹងមិនបង្ហាញខ្លួន ចៅក្រមស៊ើបសួរអាចសុំឲ្យកងកម្លាំងសាធារណៈបង្ខំសាក្សីឲ្យចូលខ្លួន។ ចៅក្រមស៊ើបសួរចេញបញ្ជា ហើយបញ្ជានោះត្រូវមានអត្តសញ្ញាណសាក្សី ដោយត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ ព្រមទាំងបោះត្រាផង។[20] សាក្សីមានកាតព្វកិច្ច ៣ យ៉ាងៈ ចូលមកបង្ហាញខ្លួន ធ្វើពាក្យសម្បថ ត្រូវរួចផុតពីសម្បថបុគ្គល ដែលជិតស្និតជាមួយជនត្រូវចោទ ដូចជាបុព្វញាតិ បច្ឆាញាតិ បងប្អូន សហព័ទ្ធ និងកូនដែលមានអាយុ ចាប់ពី ១៦ ឡើងទៅ និងផ្តល់ចម្លើយ។[21] ក្នុងករណីចាំបាច់ចៅក្រមស៊ើបសួរ អាចកោះហៅអ្នកបកប្រែដើម្បីស្តាប់ចម្លើយសាក្សី។ បើសាក្សីមានជំងឺ ឬមិនអាចធ្វើដំណើរមកបាន ចៅក្រមស៊ើបសួរ និងក្រឡាបញ្ជីអាចទៅកាន់ផ្ទះ របស់សាក្សី ឬកន្លែងដែលសាក្សីនោះនៅដើម្បីទទួលយកចម្លើយ ។[22] សាក្សីមិនមែនជាភាគីនៃការស៊ើបសួរ គាត់មិនទទួលបាននូវសិទ្ធិការពារខ្លួន ដូច្នេះសាក្សីត្រូវបានស្តាប់ចម្លើយតែម្នាក់ឯងដោយចៅក្រមស៊ើបសួរ។[23] ប៉ុន្តែគាត់អាចជាកម្មវត្ថុនៃការសួរតទល់គ្នាជាមួយ និងភាគីក្នុងសំណុំរឿង។[24] ដើម្បីគោរពសិទ្ធិការពារខ្លួន ចៅក្រមស៊ើបសួរមិនអាចស្តាប់ចម្លើយ ក្នុងឋានៈជាសាក្សីនូវបុគ្គលណាមួយដែលមានតម្រុយពិរុទ្ធភាពថាបានប្រព្រឹត្តបទល្មើសនោះទេ ក្នុងករណីនេះចៅក្រមស៊ើបសួរត្រូវយកនីតិវិធីនៃមាត្រា១៥៣ (ការជូនដំណឹងអំពីការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ ) នៃក្រមនីតិវិធីព្រហ្មទណ្ឌមកអនុវត្ត។ [25]

### ៣.៤. ការឆែកឆេរ និងការចាប់យកវត្ថុតាង

នៅក្នុងក្របខណ្ឌស៊ើបសួរក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តិអំពីសិទ្ធិអំណាចរបស់ចៅក្រមស៊ើបសួរ ដែលអាចធ្វើការឆែកឆេរបាន ។ ចៅក្រមស៊ើបសួរ ត្រូវឆែកឆេរនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទីកន្លែងទេ ត្រូវធ្វើនៅចំពោះមុខសាក្សី ២ (ពីរ) នាក់ ដែលខ្លួនបានចាត់តាំង ។ សាក្សីមិនអាចជានគរបាល ឬកងរាជអាវុធហត្ថ ដែលជាកងកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះបានឡើយ ។

ជាគោលការណ៍មិនថានៅក្នុងក្របខណ្ឌស៊ើបសួរ ឬក្របខណ្ឌស៊ើបអង្កេតនោះទេ មិនអាចធ្វើការឆែកឆេរមុនម៉ោង ៦ ( ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ ( ដប់ប្រាំបី) ល្ងាចបានទេ លើកលែងតែ :

- ក្នុងករណីឆែកឆេរនៅទីកន្លែងដែលបើកចំហដល់សាធារណៈជន
- ក្នុងករណីឆែកឆេរនៅគ្រប់ទីកន្លែងដែលផលិត រក្សាទុក ជួញដូរ ចែកចាយ ឬ ប្រើប្រាស់គ្រឿងញៀន។

ការឆែកឆេរនៅក្នុងការិយាល័យមេធាវី ត្រូវធ្វើនៅចំពោះមុខប្រធានគណៈមេធាវី ឬប្រតិភូរបស់ប្រធានគណៈមេធាវីនោះ ។ ចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុ ស្តីពីការឆែកឆេរដោយមានចុះហត្ថលេខារបស់ខ្លួន និង

[20] មាត្រា១៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[21] មាត្រា១៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[22] មាត្រា១៥៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[23] មេរៀននីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយ លោកស្រី ឌី លីឡានិងលោក ខាន់ សុខា

[24] មេរៀននីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយ លោកស្រី ឌី លីឡា និង លោក ខាន់ សុខា

[25] មាត្រា១៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

ក្រឡាបញ្ជីរួមជាមួយអ្នកកាន់កាប់ទីកន្លែង ឬសាក្សីពីរនាក់ កំណត់ហេតុត្រូវចុះនិទ្ទេស អំពីអត្តសញ្ញាណរបស់អ្នកកាន់កាប់ទីកន្លែង ឬសាក្សីនីមួយៗ។ ការបង្កើតការឆែកឆេរ ប្រព្រឹត្តទៅនៅក្នុងការិយាល័យមេធាវី កំណត់ហេតុត្រូវចុះនិទ្ទេសអំពីវត្តមានរបស់ប្រធានគណៈមេធាវី ឬរបស់ប្រតិភូនៃប្រធានគណៈមេធាវីនេះ។[26] ក្រៅពីនេះចៅក្រមស៊ើបសួរអាចចាប់យកវត្ថុតាងបាន តែត្រូវ បិទសាលាបោះត្រា លើវត្ថុតាងនោះ។ ក្រោយពីបានបង្ហាញវត្ថុតាងដែលចាប់បានដល់អ្នកកាន់កាប់ទីកន្លែង ឬដល់សាក្សី ២ ( ពីរ) នាក់រួចមក ចៅក្រមស៊ើបសួរធ្វើកំណត់ហេតុស្ដីពីការចាប់ ដែលរួមមានបញ្ជី សារពើភណ្ឌ នៃវត្ថុដែលចាប់យក។ កំណត់ហេតុស្ដីពីការចាប់នេះត្រូវចុះហត្ថលេខារបស់ចៅក្រមស៊ើបសួរ និង ក្រឡាបញ្ជី រួមជាមួយអ្នកកាន់កាប់ទីកន្លែង ឬ សាក្សី ២ ( ពីរ) នាក់ ។ កំណត់ហេតុត្រូវមានចុះនិទ្ទេសពី អត្តសញ្ញាណនៃអ្នកកាន់កាប់ទីកន្លែង ឬសាក្សីនីមួយៗ ។[27] នៅពេលដែលមិនទាន់ចេញដីកាដំណោះស្រាយរឿងនៅឡើយទេ ចៅក្រមស៊ើបសួរមានសមត្ថកិច្ចប្រគល់សងទៅម្ចាស់ដើមវិញ នូវវត្ថុដែលចាប់បានកាលណា វត្ថុទាំងនោះពុំមានប្រយោជន៍ដល់សំណុំរឿង ឬកម្មសិទ្ធិនេះគ្មានការជំទាស់អ្វីប្រាកដប្រជាទេ។ ចៅក្រមស៊ើបសួរសម្រេចដីកាដែលមានសំអាងហេតុ ក្រោយពីបានទទួលមតិពីព្រះរាជអាជ្ញា។ ដីកាសម្រេចត្រូវឲ្យដំណឹងជាបន្ទាន់ដល់អ្នកប្ដឹង និងមេធាវីនៃអ្នកប្ដឹងប្រសិនបើមាន។ ចៅក្រមស៊ើបសួរ អាចបដិសេធមិនប្រគល់វត្ថុចាប់យក ទៅឲ្យអ្នកប្ដឹងសុំទេ កាលណាវិធានការនេះអាចបង្កជាឧបសគ្គដល់ការសម្ដែងឲ្យឃើញការពិត វត្ថុដែលមានគ្រោះថ្នាក់ដល់បុគ្គលដទៃ ឬ ទ្រព្យសម្បត្តិដូចជាអាវុធ ឬជាតិផ្ទុះ ព្រមទាំងវត្ថុដែលការកាន់កាប់មិនស្របច្បាប់ មិនអាចត្រូវប្រគល់សងឲ្យទៅសាមីខ្លួនបានទេ វត្ថុទាំងនេះត្រូវរឹបអូសជាកម្មសិទ្ធិរបស់រដ្ឋ។[28]

### ៣.៥. កោសលវិច័យ

ក្នុងករណីដែលមានបញ្ហាបច្ចេកទេសចោទឡើង ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យធ្វើកោសលវិច័យដោយឯកឯង ឬតាមពាក្យសុំរបស់ព្រះរាជអាជ្ញា របស់ជនត្រូវចោទ ឬដើមបណ្ដឹងរដ្ឋប្បវេណី។ កាលណាចៅក្រមស៊ើបសួរ បដិសេធមិនព្រមធ្វើតាមពាក្យសុំធ្វើកោសលវិច័យទេ ចៅក្រមស៊ើបសួរត្រូវសម្រេចតាមដីកាដោយមានសំអាងហេតុ ។ ដីកាត្រូវសម្រេចក្នុងរយៈពេល ៥ ( ប្រាំ ) ថ្ងៃប្រសិនបើពាក្យសុំនោះចេញមកពីព្រះរាជអាជ្ញា និង ១ (មួយ) ខែ ប្រសិនបើពាក្យសុំនោះចេញពីជនត្រូវចោទ ឬដើមបណ្ដឹងរដ្ឋប្បវេណី។ ដីកាសម្រេចនេះត្រូវជូនដំណឹងឲ្យដល់អ្នកប្ដឹងសុំជាបន្ទាន់។[29]

អ្នកជំនាញធ្វើកោសលវិច័យ គឺត្រូវជ្រើសរើសចេញពីបញ្ជីថ្នាក់ជាតិនៃអ្នកជំនាញ ដែលបញ្ជីថ្នាក់ជាតិនៃអ្នកជំនាញនេះដែលត្រូវរៀបចំឡើងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ បែបបទនៃការចុះឈ្មោះ ឬលុបឈ្មោះចេញពីបញ្ជី

[26] មាត្រា១៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[27] មាត្រា១៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[28] មាត្រា១៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[29] មាត្រា១៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

ត្រូវកំណត់ដោយប្រកាស។ អ្នកជំនាញដែលត្រូវបានចុះឈ្មោះនៅក្នុងបញ្ជីថ្នាក់ជាតិ ត្រូវស្បថនៅមុខសាលាឧទ្ធរណ៍ភ្នំពេញ ស្របតាមសាសនា ឬ ជំនឿរបស់ខ្លួនថានឹងផ្តល់ជំនួយដោយភាពស្មោះត្រង់ ដល់ការស្វែងរកយុត្តិធម៌ អ្នកជំនាញដែលត្រូវបានចុះឈ្មោះក្នុងបញ្ជីមិនចាំបាច់ស្បថសាជាថ្មីទៀតទេ នៅពេលណាដែលខ្លួនត្រូវបានគេចាត់តាំងឲ្យធ្វើកោសលវិច័យ។[30] តាមធម្មតាចៅក្រមស៊ើបសួរត្រូវជ្រើសរើសអ្នកជំនាញ ដែលត្រូវបានចុះឈ្មោះនៅក្នុងបញ្ជីថ្នាក់ជាតិនៃអ្នកជំនាញ។ ចៅក្រមស៊ើបសួរតាមដីកាដោយមានសំអាងហេតុជាពិសេស អាចចាត់តាំងអ្នកជំនាញដែលគ្មានឈ្មោះនៅក្នុងបញ្ជីថ្នាក់ជាតិបាន។ ក្នុងករណីនេះអ្នកជំនាញត្រូវស្បថតាមសាសនា ឬជំនឿរបស់ខ្លួនថាខ្លួននឹងផ្តល់ជំនួយដោយស្មោះត្រង់ដល់ការស្វែងរកយុត្តិធម៌។[31] ចំពោះដីកាចាត់តាំងអ្នកជំនាញនេះផងដែរ ចៅក្រមស៊ើបសួរត្រូវបញ្ជាក់អំពីបេសកកម្មរបស់អ្នកជំនាញព្រមទាំងរយៈពេលដែលត្រូវបានបំពេញបេសកកម្មនេះ។ បេសកកម្មអាចទាក់ទងទៅនឹងបញ្ហាដែលមានលក្ខណៈបច្ចេកទេសតែប៉ុណ្ណោះ។ ប្រសិនបើជាការគួរចៅក្រមស៊ើបសួរត្រូវប្រគល់វត្ថុដែលចាប់បានមួយផ្នែក ឬទាំងអស់នោះជូនអ្នកជំនាញ។ ចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុស្តីពីការប្រគល់វត្ថុដែលចាប់បាន។ អ្នកជំនាញត្រូវជូនព័ត៌មានដល់ចៅក្រមស៊ើបសួរ និងសុំការអនុញ្ញាតពីចៅក្រមនេះមុននឹងផ្តើមប្រតិបត្តិការរបស់ខ្លួន ក្នុងករណីត្រូវបំបែកស្លាកដែលបិទដើម្បីធ្វើកោសលវិច័យ និងប្រសិនបើកោសលវិច័យនេះអាចធ្វើឲ្យខូចខាត ឬវិនាសដល់វត្ថុដែលបានចាប់បាននោះ។[32] ចៅក្រមស៊ើបសួរគឺជាអ្នកត្រួតពិនិត្យទៅលើការបំពេញបេសកកម្មរបស់អ្នកជំនាញ។ អ្នកជំនាញត្រូវជូនព័ត៌មានដល់ ចៅក្រមស៊ើបសួរអំពីការប្រព្រឹត្តទៅនៃបេសកកម្មរបស់ខ្លួនជាអាទិ៍ ក៏ដូចការលំបាកដែលខ្លួនអាចនឹងជួបប្រទះ។ ចៅក្រមស៊ើបសួរអាចចាប់អ្នកជំនាញផ្សេងទៀតជំនួសអ្នកជំនាញនោះ ប្រសិនបើអ្នកជំនាញមិនគោរពរយៈពេលដែលកំណត់ដោយចៅក្រមស៊ើបសួរទេ ប៉ុន្តែក្នុងករណីដែលកាលៈទេសៈតម្រូវនោះចៅក្រមស៊ើបសួរអាចអនុញ្ញាតតាមរយៈដីកាសម្រេចឲ្យធ្វើការពន្យារពេលបាន។[33] ដើម្បីបំពេញបេសកកម្មរបស់ខ្លួន អ្នកជំនាញអាចស្តាប់ចម្លើយបុគ្គលគ្រប់រូបក្រៅពីជនត្រូវចោទ ។ អ្នកជំនាញអាចស្តាប់ចម្លើយពីជនត្រូវចោទបានប្រសិនយល់ឃើញថាចាំបាច់ ប៉ុន្តែត្រូវសុំការអនុញ្ញាតពីចៅក្រមស៊ើបសួរ។ ចម្លើយដែលអ្នកជំនាញបានទទួលនោះមានតម្លៃត្រឹមតែជាព័ត៌មានធម្មតា។ បុគ្គលដែលអ្នកជំនាញស្តាប់ចម្លើយនោះមិនចាំបាច់ស្បថទេ។ ជនត្រូវចោទអាចសុំឲ្យអ្នកជំនាញស្តាប់ចម្លើយរបស់ខ្លួននៅចំពោះមុខមេធាវី ។ ប៉ុន្តែកាលណាចៅក្រមស៊ើបសួរចាត់តាំងគ្រូពេទ្យ ឬអ្នកចិត្តសាស្ត្រដើម្បីពិនិត្យជនត្រូវចោទនោះការពិនិត្យវេជ្ជសាស្ត្រ ឬចិត្តសាស្ត្រត្រូវធ្វើដោយគ្មានវត្តមានមេធាវី ។ [34]

[30] មាត្រា១៦៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[31] មាត្រា១៦៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[32] មាត្រា១៦៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[33] មាត្រា១៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[34] មាត្រា១៦៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

អ្នកជំនាញកោសលវិច័យ ត្រូវធ្វើរបាយការណ៍នៅពេលដែលប្រតិបត្តិការកោសលវិច័យបានបញ្ចប់ ក្នុងនោះត្រូវពិពណ៌នាយ៉ាងច្បាស់លាស់អំពីប្រតិបត្តិការ ព្រមទាំងបញ្ជាក់ថាបានធ្វើដោយផ្ទាល់នូវប្រតិបត្តិការនេះ និងធ្វើសេចក្តីសន្និដ្ឋាន។ របាយការណ៍ត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខា។ ចំពោះការបំបែកស្លាក ដើម្បីពិនិត្យវត្ថុដែលចាប់យក អ្នកជំនាញត្រូវចុះនិទ្ទេសអំពីបញ្ហានេះនៅក្នុងរបាយការណ៍ផងដែរ។ អ្នកជំនាញត្រូវប្រគល់របាយការណ៍របស់ខ្លួននោះ និងប្រគល់នូវវត្ថុដែលចាប់យកឲ្យចៅក្រមស៊ើបសួរវិញ ហើយចៅក្រមស៊ើបសួរត្រូវបិទស្លាកជាថ្មីទៅលើវត្ថុដែលអ្នកជំនាញបានបំបែកស្លាកនោះ។ ការប្រគល់សងនូវវត្ថុ និងជាយថាហេតុ ការបិទស្លាកជាថ្មីលើវត្ថុនោះត្រូវតែធ្វើកំណត់ហេតុតែធ្វើឡើងវិញ។ កាលណាកោសលវិច័យធ្វើឲ្យខូចខាត ឬ វិនាសនូវវត្ថុដែលចាប់យក អ្នកជំនាញត្រូវចុះនិទ្ទេសនៅក្នុងរបាយការណ៍របស់ខ្លួនអំពីការអនុញ្ញាតរបស់ចៅក្រមស៊ើបសួរ ដូចមានចែងនៅក្នុងវាក្យខ័ណ្ឌទី ៣ កថាខណ្ឌទី ៣ មាត្រា ១៦៥ ( ដីកាចាត់តាំងអ្នកជំនាញ ) នៃក្រមនេះ។ [35]

ប្រសិនបើកាលៈទេសៈតម្រូវ ចៅក្រមស៊ើបសួរអាចចាត់តាំងអ្នកជំនាញច្រើននាក់។ នៅក្នុងករណីនេះប្រសិនបើអ្នកជំនាញនេះមានយោបល់ខុសគ្នានោះ ម្នាក់ៗត្រូវសរសេរអំពីយោបល់របស់ខ្លួនផ្ទាល់ ឬការមិនយល់ព្រមរបស់ខ្លួន។[36]

កាលណារបាយការណ៍កោសលវិច័យ ត្រូវបានធ្វើរួចហើយ ចៅក្រមស៊ើបសួរត្រូវតែជូនព័ត៌មានដល់ព្រះរាជអាជ្ញា។ របាយការណ៍កោសលវិច័យត្រូវ ដាក់ចូលក្នុងសំណុំរឿងស៊ើបសួរ។ ចៅក្រមស៊ើបសួរកោះហៅជនត្រូវចោទ និងមេធាវីរបស់ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីផងដែរ ដើម្បីប្រាប់ឲ្យដឹងពីសេចក្តីសន្និដ្ឋាននៃកោសលវិច័យ។ ចៅក្រមស៊ើបសួរកំណត់រយៈពេលដែលអនុញ្ញាតឲ្យព្រះរាជអាជ្ញា ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីដាក់ពាក្យសុំធ្វើកោសលវិច័យបន្ថែម ឬ ប្រតិកោលសវិច័យ ។ រយៈពេលនេះមិនអាចតិចជាង ១០ ( ដប់ ) ថ្ងៃទេ។ ក្នុងរយៈពេលនេះ សំណុំរឿងដែលរួមមាន ការកោសលវិច័យអាចត្រូវបានពិនិត្យមើលដោយមេធាវី។

គ្រប់ពាក្យសុំធ្វើកោសលវិច័យបន្ថែម ឬប្រតិកោសលវិច័យត្រូវតែមានសំអាងហេតុ និងធ្វើឡើងជាលាយលក្ខណ៍អក្សរ។

### ៣.៦. ការស្តាប់ទូរស័ព្ទ

ចៅក្រមស៊ើបសួរមានអំណាចអាចបង្គាប់ឲ្យស្តាប់ និងថតការសន្ទនាតាមទូរស័ព្ទ ដែលជាតម្រូវការចាំបាច់ដើម្បីសម្តែងឲ្យឃើញនូវការពិត។ ចៅក្រមស៊ើបសួរក៏អាចបង្គាប់ឲ្យចាប់ និងថតគ្រប់ការឆ្លើយឆ្លងគ្នា តាមមធ្យោបាយទូរគមនាគមន៍ផងដែរដូចជា សារតាមទូរសារ ឬសារតាមអ៊ីនធឺណេត។

---

[35] មាត្រា១៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[36] មាត្រា១៦៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

ចៅក្រមស៊ើបសួរអាចសុំឲ្យគ្រប់អង្គភាពសាធារណៈ ឬគ្រប់មន្ត្រីរាជការជំនាញតាំងឧបករណ៍បច្ចេកទេសនិង ធ្វើការថត។ ចៅក្រមស៊ើបសួរបញ្ជាក់ នៅក្នុងដីកាសម្រេចរបស់ខ្លួនអំពីប្រភេទនៃទំនាក់ទំនងដែលត្រូវចាប់ ព្រមទាំង អំពីរយៈពេលនៃបេសកកម្ម។

អង្គភាពសាធារណៈ មន្ត្រីរាជការដែលចាត់តាំង ត្រូវបំពេញតាមពាក្យសុំរបស់ចៅក្រមស៊ើបសួរ។ នៅក្នុង ពេលអនុវត្តបេសកកម្ម អង្គភាពសាធារណៈ ឬ គ្រប់មន្ត្រីរាជការដែលចាត់តាំងត្រូវជូនព័ត៌មានដល់ចៅក្រមស៊ើបសួរ អំពីការប្រព្រឹត្តិទៅនៃបេសកកម្ម ជាអាទិ៍ អំពីការលំបាកជាយថាហេតុ។ កាលណាបេសកកម្មត្រូវបានបំពេញ រួចហើយ អង្គភាពសាធារណៈ ឬ គ្រប់មន្ត្រីរាជការនោះត្រូវចម្លងជាលាយលក្ខណ៍អក្សរនូវសំលេងដែលថតបាន ហើយត្រូវប្រគល់ជូនចៅក្រមស៊ើបសួរ និងបិទស្លាក។ ចៅក្រមស៊ើបសួរអាចចុះទៅកាន់ទីកន្លែងដែលធ្វើការចាប់ ថតនោះ ។ ការចូលទៅក្នុងទីកន្លែងទាំងនេះ មិនអាចត្រូវបានហាមឃាត់ដល់ចៅក្រមស៊ើបសួរដោយមានសំអាង ហេតុលើមូលហេតុអ្វីទេ ទោះបីជាកន្លែងយោធាក៏ដោយ។[37]

### ៣.៧. ការចាត់ឲ្យស៊ើបសួរជំនួស

នៅក្នុងពេលបំពេញកិច្ចស៊ើបសួរ ប្រសិនបើចៅក្រមស៊ើបសួរមិនអាចបំពេញភារកិច្ចរបស់ខ្លួន ដោយសារ មូលហេតុផ្ទាល់ខ្លួន ឬជួបប្រទះនូវបញ្ហាណាមួយដែលមិនអាចស៊ើបសួរដោយខ្លួនឯងបាន ចៅក្រមស៊ើបសួរអាច ប្រគល់សិទ្ធិទៅឲ្យអ្នកផ្សេងបំពេញកិច្ចស៊ើបសួរជំនួសខ្លួន។

ចៅក្រមស៊ើបសួរប្រគល់សិទ្ធិឲ្យចៅក្រមនៃតុលាការរបស់ខ្លួន ឬតុលាការផ្សេងទៀត មន្ត្រីនគរបាយុត្តិធម៌ ឬដល់អង្គភាពនគរបាលយុត្តិធម៌ ដើម្បីបំពេញកិច្ចស៊ើបសួរជំនួស។[38] ដីកាចាត់ឲ្យស៊ើបសួរជំនួសត្រូវតែមានបញ្ជាក់ ពីកិច្ចដែលត្រូវធ្វើកិច្ចនោះត្រូវមានទំនាក់ទំនងដោយផ្ទាល់ជាមួយបទល្មើសដែលត្រូវបានចោទប្រកាន់ ពោលគឺមិន ត្រូវប្រគល់សិទ្ធិមានលក្ខណៈជាទូទៅទេ ចៅក្រមស៊ើបសួរត្រូវតែណែនាំឲ្យបានច្បាស់លាស់ពីកិច្ចដែលត្រូវស៊ើបសួរ ជំនួសនេះ ។ ដីកាចាត់ឲ្យស៊ើបសួរជំនួស ចៅក្រមស៊ើបសួរត្រូវកំណត់ថេរវេលានៅក្នុងនោះផង។ ចៅក្រមស៊ើបសួរ អាចដកហូតដីកាចាត់ឲ្យស៊ើបសួរជំនួសបានគ្រប់ពេលវេលា។[39]

ចៅក្រមស៊ើបសួរនៅពេលចេញដីកាចាត់ឲ្យស៊ើបសួរជំនួស ត្រូវកម្រិតសិទ្ធិខ្លះដែលប្រគល់ឲ្យមន្ត្រីនគរបាល យុត្តិធម៌ ។ ចៅក្រមស៊ើបសួរមិនអាចប្រគល់ឲ្យមន្ត្រីនគរបាលយុត្តិធម៌ធ្វើការស៊ើបសួរជំនួសខ្លួនទាក់ទងទៅនឹង៖

-ការសួរចម្លើយជនត្រូវចោទ និង

-ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ។

---

[37] មាត្រា១៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[38] មាត្រា១៧៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[39] មាត្រា១៧៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

នៅក្នុងការបំពេញកិច្ចស៊ើបសួរជំនួសចៅក្រមស៊ើបសួរ មន្ត្រីនគរបាលយុត្តិធម៌ដែលទទួលភារកិច្ចពីចៅក្រមស៊ើបសួរដោយអំណាចដីកាចាត់ឲ្យស៊ើបសួរជំនួស មន្ត្រីនគរបាលយុត្តិធម៌ នៅពេលដែលស្តាប់ចម្លើយសាក្សី ត្រូវឲ្យសាក្សីនោះធ្វើសម្បថជាមុនសិន មុននឹងស្តាប់ចម្លើយ។

### ៣.៨. វិធានការនិរន្តរាយ

វិធានការនិរន្តរាយដែលចៅក្រមស៊ើបសួរចេញមានដូចជា៖

#### ៣.៨.១. ដីកាបង្គាប់ឲ្យចូលខ្លួន

ដីកាបង្គាប់ឲ្យចូលខ្លួន គឺជាប្រភេទដីកាដែលចេញដើម្បីបញ្ជាឲ្យបុគ្គលណាម្នាក់ចូលទៅបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ។ ដីកាចេញទៅលើជនត្រូវចោទ ឬទៅលើបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាពប៉ុណ្ណោះ ។[40] ដីកាបញ្ជាឲ្យចូលខ្លួន ត្រូវឲ្យដំណឹងដល់បុគ្គលដែលពាក់ព័ន្ធ ដោយមន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ ដោយអាជ្ញាសាលា ។[41]

#### ៣.៨.២. ដីកាបង្គាប់ឲ្យនាំខ្លួន

ដីកាបង្គាប់ឲ្យនាំខ្លួន គឺបញ្ជារបស់ចៅក្រមស៊ើបសួរទៅកងកម្លាំងសាធារណៈឲ្យចាប់ខ្លួន និងនាំខ្លួនបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព ពីបទល្មើសណាមួយដែលត្រូវបានចោទប្រកាន់ទៅបង្ហាញខ្លួនចំពោះមុខចៅក្រមស៊ើបសួរ។[42] ដីកានេះត្រូវអនុវត្តដោយមន្ត្រីនគរបាលយុត្តិធម៌ ប្រសិនបើក្នុងករណីបន្ទាន់ដោយមិនអាចត្រូវរងចាំទេ ការអនុវត្តដីកាបញ្ជាឲ្យនាំខ្លួនត្រូវផ្សព្វផ្សាយដល់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថតាមគ្រប់មធ្យោបាយ។ [43]

មន្ត្រីនគរបាលយុត្តិធម៌ដែលមានភារកិច្ចតាមការចាត់តាំងនោះត្រូវចាប់ខ្លួន ឬនាំខ្លួនជនដែលតុលាការបង្គាប់ឲ្យនាំខ្លួននោះ ទៅចំពោះមុខចៅក្រមស៊ើបសួរភ្លាម។ ប្រសិនបើមិនទាន់អាចយកទៅបង្ហាញនៅចំពោះមុខចៅក្រមបានភ្លាមនោះទេ ត្រូវនាំជននោះទៅរក្សាទុកនៅអង្គភាពនគរបាល ឬកងរាជអាវុធហត្ថក្នុងមណ្ឌលឃុំខ្លួន ឬទៅពន្ធនាគារ ហើយត្រូវនាំជននោះទៅបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរយ៉ាងយូរបំផុតនៅថ្ងៃបន្ទាប់ ប្រសិនបើមិនបាននាំជននោះទៅបង្ហាញនៅចំពោះមុខចៅក្រមស៊ើបសួរនៅថ្ងៃបន្ទាប់នោះទេ ជននោះនឹងត្រូវបានដោះលែងឲ្យមានសេរីភាពឡើងវិញ។[44] កាលណាបុគ្គលណាម្នាក់ ដែលត្រូវបានចាប់ខ្លួន ដោយអនុវត្តតាមដីកា

---

[40] មាត្រា១៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[41] មាត្រា១៨៨ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[42] មាត្រា១៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[43] មាត្រា១៩២ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[44] មាត្រា១៩៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

បង្គាប់ឲ្យនាំខ្លួន ហើយត្រូវឃុំខ្លួននោះ ថិរវេលានៃការឃុំខ្លួននេះត្រូវបញ្ចូលទៅក្នុងថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន។[45]

ដីកាបង្គាប់ឲ្យនាំខ្លួនអនុញ្ញាត ឲ្យមន្ត្រីនគរបាលយុត្តិធម៌ចូលទៅក្នុងលំនៅដ្ឋានរបស់ជននោះបាន ប៉ុន្តែមន្ត្រីនគរបាលយុត្តិធម៌មិនអាចចូលទៅលំនៅដ្ឋានរបស់ជនដែលត្រូវនាំខ្លួននៅមុនម៉ោង៦ ព្រឹក និងក្រោយម៉ោង ១៨ បានឡើយ។[46]

### ៣.៨.៣. ដីកាបង្គាប់ឲ្យចាប់ខ្លួន

ដីកាបង្គាប់ឲ្យចាប់ខ្លួន អាចចេញទៅលើជនត្រូវចោទ ឬបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព ។ ដីកាបង្គាប់ឲ្យចាប់ខ្លួន គឺជាបញ្ជាដល់កងកម្លាំងសាធារណៈ ឲ្យស្រាវជ្រាវរកចាប់ និងនាំខ្លួនបុគ្គលនោះ ទៅក្នុងពន្ធនាគារ ឬមណ្ឌលឃុំខ្លួន និងបង្គាប់ឲ្យប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនទទួល និងឃុំខ្លួនបុគ្គលនោះ។[47]

ចៅក្រមស៊ើបសួរ អាចចេញដីកាបង្គាប់ឲ្យចាប់ខ្លួនបាន លុះត្រាតែ បទល្មើសដែលត្រូវបានចោទប្រកាន់ជាបទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ និងបុគ្គលដែលពាក់ព័ន្ធ បានគេចខ្លួនមិនដឹងស្ថិតនៅទីកន្លែងណា ឬស្ថិតនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា។[48] ជាទូទៅចំពោះការអនុវត្តដីកាបង្គាប់ឲ្យចាប់ខ្លួននេះ ចៅក្រមស៊ើបសួរមិនអាចចេញដោយឯកឯងនោះទេ ចៅក្រមស៊ើបសួរត្រូវទទួលយោបល់ពីព្រះរាជអាជ្ញាជាមុនសិន។ ក្នុងករណីចាំបាច់ ប្រសិនបើជននោះស្ថិតនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដីកាបង្គាប់ឲ្យចាប់ខ្លួនអាចផ្សព្វផ្សាយជាអន្តរជាតិតាមរយៈក្រសួងយុត្តិធម៌។[49]

### ៣.៨.៤. ដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្ន

#### ៣.៨.៤.១. មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន

ការឃុំខ្លួនបណ្តោះអាសន្នអាចត្រូវបានបង្គាប់កាលណាការឃុំខ្លួនបណ្តោះអាសន្នជាការចាំបាច់ ៖

១-ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតឡើងជាថ្មី។

២-ដើម្បីរារាំងកុំឲ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឲ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត។

៣-ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ។

៤-ដើម្បីធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី។

៥-ដើម្បីការពារសុវត្ថិភាពឲ្យជនត្រូវចោទ។

---

[45] មាត្រា១៩៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[46] មាត្រា១៩២ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[47] មាត្រា១៩៦ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[48] មាត្រា១៩៦ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[49] មាត្រា២០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

៦-ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈ កុំឲ្យមានការច្របូកច្របល់ដែលបណ្តាលមកពីបទល្មើស។[50]

### ៣.៨.៤.២. ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន

ជាគោលការណ៍ ជនត្រូវចោទត្រូវតែមានសេរីភាព ។ ប៉ុន្តែក្នុងករណីពិសេស ជនត្រូវចោទ អាចត្រូវបានឃុំខ្លួនបណ្តោះអាសន្ន។[51] ការឃុំខ្លួនបណ្តោះអាសន្នអាចអនុវត្តទៅបានតែក្នុងករណីដែលជនត្រូវចោទនោះបានរងការចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលច្បាប់កំណត់ផ្តន្ទាទោសដាក់ពន្ធនាគារស្មើរ ឬលើសពី១ (មួយ) ឆ្នាំ។[52]

- **ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចំពោះបទឧក្រិដ្ឋ**

ការឃុំខ្លួនបណ្តោះអាសន្នក្នុងបទឧក្រិដ្ឋដែលអនុវត្តលើជនត្រូវចោទជានីតិជនមានរយៈពេលមិនអាចលើសពី ០៦ (ប្រាំមួយ) ខែ និងអាចពន្យារពេលបាន២ ដង ម្តងចំនួន ០៦ ខែ។[53] និងក្នុងករណីដែលមានការចោទប្រកាន់ពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ បទឧក្រិដ្ឋប្រឆាំងពូជសាសន៍ ឬបទឧក្រិដ្ឋសង្គ្រាម ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ១ ( មួយ ) ឆ្នាំ បានទេ អាចពន្យារការឃុំខ្លួនបណ្តោះអាសន្នបាន ១ ( មួយ ) ឆ្នាំដោយដីកាមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យពន្យារពេលការឃុំខ្លួនបណ្តោះអាសន្នបានតែ ២ ពីរដងប៉ុណ្ណោះ។ [54]

បើជនត្រូវចោទជាអនីតិជនដែលមានអាយុចាប់ពី ១៦ ឆ្នាំ ដល់ ក្រោម ១៨ឆ្នាំ ការឃុំខ្លួនបណ្តោះអាសន្នមានរយៈពេលមិនអាចលើសពី ០៦ (ប្រាំមួយ) ខែបានឡើយ និងមិនអាចពន្យាពេលទេ។[55] ចំណែកជនត្រូវចោទជាអនីតិជនដែលមានអាយុចាប់ពី ១៤ ដល់ ក្រោយ១៦ ឆ្នាំ ការឃុំខ្លួនបណ្តោះអាសន្នមានរយៈពេលមិនអាចលើសពី ០៤ (បួន) ខែ បានឡើយ និងមិនអាចពន្យារពេលបាននោះទេ ។[56]

- **ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចំពោះបទមជ្ឈឹម**

ការឃុំខ្លួនបណ្តោះអាសន្ន ក្នុងបទមជ្ឈឹមដែលអនុវត្តលើជនត្រូវចោទជានីតិជន មានរយៈពេលមិនអាចលើសពី ០៤ (បួន) ខែ និងអាចពន្យារពេលបាន១ ដង ម្តងចំនួន ០២ (ពីរ) ខែ។[57]

បើជនត្រូវចោទជាអនីតិជនដែលមានអាយុចាប់ពី ១៦ ឆ្នាំ ដល់ ក្រោយ១៨ឆ្នាំ ការឃុំខ្លួនបណ្តោះអាសន្នមានរយៈពេលមិនអាចលើសពី ០៤ (បួន) ខែបានឡើយ និងមិនអាចពន្យាពេលទេ។[58] ចំណែកជនត្រូវជាអនីតិជន

[50] មាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧
[51] មាត្រា២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧
[52] មាត្រា២០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧
[53] មាត្រា២០៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧
[54] មាត្រា២១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧
[55] មាត្រា២១៣ កថាខណ្ឌទី២ ចំណុចទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧
[56] មាត្រា២១៣ កថាខណ្ឌទី២ ចំណុចទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧
[57] មាត្រា២០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧
[58] មាត្រា២១៤ កថាខណ្ឌទី២ ចំណុចទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

ដែលមានអាយុចាប់ពី ១៤ ដល់ ក្រោយ១៦ ឆ្នាំ មានរយៈពេលមិនអាចលើសពី ០២ (ពីរ) ខែ បានឡើយ និងមិនអាចពន្យារពេលបាននោះទេ។[59] ជនត្រូវចោទដែលជាអនីតិជនមានអាយុក្រោម ១៤ ឆ្នាំមិនអាចមានការឃុំខ្លួនបណ្តោះអាសន្នឡើយ។[60]

### ៣.៨.៥. ការដាក់ជនត្រូវចោទឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យដាក់ជនត្រូវចោទឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា ប្រសិនបើជននោះត្រូវបានចោទប្រកាន់អំពីបទល្មើស ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ ។

ការត្រួតពិនិត្យតាមផ្លូវតុលាការ ជាផ្នែកមួយនៃវិធានការនិរន្តរាយដែលមានលក្ខណៈស្រដៀងនឹងការឃុំខ្លួនបណ្តោះអាសន្នគ្រាន់តែការឃុំខ្លួនបណ្តោះអាសន្ន ជនត្រូវចោទត្រូវរឹតត្បិតសេរីភាពដោយត្រូវបញ្ជូនទៅដាក់ពន្ធនាគារ ហើយថិរវេលាឃុំខ្លួនបណ្តោះអាសន្ននោះបានកំណត់ទៅតាមប្រភេទនៃបទល្មើស ។ ការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ មានលក្ខណៈស្រាលជាងការឃុំខ្លួនបណ្តោះអាសន្ន ដោយជនត្រូវចោទអាចមានសេរីភាពប៉ុន្តែស្ថិតក្រោមការឃ្លាំងមើលពីសំណាក់តុលាការ។ ជនត្រូវចោទមានកាតព្វកិច្ច ឬ ការមហាឃាត់មួយចំនួនដែលកំណត់ដោយច្បាប់។ ជនត្រូវចោទដែលចៅក្រមស៊ើបសួរចេញដីកាសម្រេចឲនៅក្រៅឃុំត្រូវគោរពកាតព្វកិច្ចមួយ ឬច្រើនដូចតទៅនេះ ៖

១-មិនត្រូវចេញក្រៅព្រំប្រទល់ដែនដីកំណត់ដោយចៅក្រមស៊ើបសួរ

២-មិនត្រូវផ្លាស់ប្តូរលំនៅឋានដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ

៣-មិនត្រូវទៅកាន់ទីកន្លែងខ្លះបានកំណត់ដោយចៅក្រមស៊ើបសួរ

៤-ត្រូវចូលបង្ហាញខ្លួនតាមការកំណត់នៅអង្គភាពនគរបាល ឬកងរាជអាវុធហត្ថដែលចាត់តាំងដោយចៅក្រមស៊ើបសួរ

៥-ត្រូវឆ្លើយតបនឹងការកោះហៅពីគ្រប់បុគ្គលដែលចាត់តាំងដោយចៅក្រមស៊ើបសួរ

៦-ប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជីគ្រប់ឯកសារបញ្ជាក់អំពីអត្តសញ្ញាណ

៧-មិនត្រូវបើកបររថយន្ត

៨-មិនត្រូវទទួលឬ ជួបបុគ្គលមួយចំនួន ដើរចង្អុលបង្ហាញដោយចៅក្រមស៊ើបសួរ

៩-ដាក់ប្រាក់ធានា តែចំនួនប្រាក់ធានានិងថិរវេលាបង់ប្រាក់នេះត្រូវបានកំណត់ដោយចៅក្រមស៊ើបសួរដោយផ្អែកទៅលើធនធានរបស់ជនត្រូវចោទ

១០-មិនត្រូវកាន់កាប់ ឬ យកតាមខ្លួននូវអាវុធ ត្រូវប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជីអាវុធដែលជនត្រូវចោទកាន់កាប់

[59] មាត្រា២១៤ កថាខណ្ឌទី២ ចំណុចទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[60] មាត្រា២១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

១១-ត្រូវប្រគល់ខ្លួនឲ្យពេទ្យពិនិត្យព្យាបាល និងដាយថាហេតុ ដាក់ឲ្យស្ថិតនៅក្រោមរបបព្យាបាលរោគក្នុងមន្ទីរពេទ្យ

១២-មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈខ្លះ ចៅក្រមស៊ើបសួរមិនអាចហាមឃាត់ការអនុវត្តនៅអាណត្តិបោះឆ្នោត ឬសកម្មភាពខាងសហជីពបានទេ។[61]

ចំពោះការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការអាចធ្វើការកែប្រែ ឬលុបចោលខ្លឹមសារនៃកាតព្វកិច្ច និងបញ្ចូលកាតព្វកិច្ចថ្មីតាមបីលក្ខខណ្ឌគឺ ការប្រែប្រួលព្រោះការត្រួតពិនិត្យតាមផ្លូវតុលាការដោយឯកឯងដោយចៅក្រមស៊ើបសួរ បណ្តឹងសុំកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដែលព្រះរាជអាជ្ញា តាមរយៈបណ្តឹងសុំកែប្រែត្រួតពិនិត្យតាមផ្លូវតុលាការដូចជនត្រូវចោទ។ ប្រសិនបើជនត្រូវចោទគេចវេចដោយចេតនាពីកាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការចៅក្រមស៊ើបសួរអាចសម្រេចឲ្យឃុំខ្លួនជនត្រូវចោទនោះបណ្តោះអាសន្នបានទោះបីទោសជាប់ពន្ធនាគារដែលត្រូវរងនោះមានថិរវេលាប៉ុន្មានក៏ដោយ។[62]

## ផ្នែកទី២៖ ការបិទបញ្ចប់នីតិវិធីស៊ើបសួរ

### កថាខណ្ឌទី១៖ ដំណើរការនៃការបិទបញ្ចប់នីតិវិធីស៊ើបសួរ

#### ១.១. លិខិតជូនដំណឹងស្តីពីការបិទការស៊ើបសួរ

ក្រមនីតិវិធីព្រហ្មទណ្ឌមិនបានចែងអំពីថិរវេលានៃការស៊ើបសួរទេ។ ប៉ុន្តែដើម្បីចៀសវាងមានការអូសបន្លាយរយៈពេលយូរហួសហេតុដែលជាហេតុធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់ភាគី ក្រមនីតិវិធីព្រហ្មទណ្ឌបានប្រគល់សមត្ថកិច្ចជូនសភាស៊ើបសួរក្នុងការធានារ៉ាប់រងឲ្យការស៊ើបសួរនេះ ធ្វើឡើងក្នុងរយៈពេលសមរម្យមួយ។ កាលណាចៅក្រមស៊ើបសួរយល់ឃើញថា ការស៊ើបសួរបានបញ្ចប់ ចៅក្រមស៊ើបសួរជូនព័ត៌មានដល់ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និង មេធាវី។[63] ការជូនព័ត៌មាននេះ ចៅក្រមស៊ើបត្រូវធ្វើឡើងតាមរយៈដីកាបញ្ចូលលិខិតដោយគ្រប់ដីការបស់ចៅក្រមស៊ើបសួរ ត្រូវមានចុះសេចក្តីដូចតទៅ ៖

- ឈ្មោះចៅក្រមស៊ើបសួរ
- ឈ្មោះក្រឡាបញ្ជី
- លេខ ថ្ងៃ ខែ ឆ្នាំ សំណុំរឿង
- កាលបរិច្ឆេទនៃដីកាសន្និដ្ឋានបញ្ជូលរឿងឲ្យស៊ើបសួរ
- ប្រភេទនៃបទល្មើស ដែលចង្អុលនៅក្នុងដីកាសន្និដ្ឋានបញ្ជូលរឿងឲ្យស៊ើបសួរ

[61] មាត្រា២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[62] មាត្រា២៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[63] មាត្រា២៤៦ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

- អត្តសញ្ញាណនៃជនត្រូវចោទ ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត លំនៅឋានរបស់ជនត្រូវចោទ ប្រសិនបើពិរុទ្ធកម្មត្រូវបានប្រកាស។
- លេខ និងកាលបរិច្ឆេទនៃការធ្វើដីកា។

ទំព័រនីមួយៗនៃដីកា ត្រូវតែចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងក្រឡាបញ្ជី ។

ដីកាមិនត្រូវឲ្យមានការចុះបន្ទាត់ឡើយ។ ការឆូត ឬ ការយោង ត្រូវតែមានបញ្ជាក់ដោយហត្ថលេខារបស់ចៅក្រមស៊ើបសួរ និងក្រឡាបញ្ជី នៅលើរឹមទំព័រ។[64]

### ១.២. ដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា

ចៅក្រមស៊ើបសួរត្រូវបញ្ជូលសុំណុំរឿងឲ្យព្រះរាជាអាជ្ញាពិនិត្យតាមរយៈ ដីកាបញ្ជូលលិខិត ក្នុងរយៈពេល ២ (ពីរ ) ថ្ងៃ ក្រោយពីបញ្ចប់ការស៊ើបសួរ ។ ប្រសិនបើព្រះរាជាអាជ្ញាយល់ឃើញថាចាំបាច់ត្រូវធ្វើកិច្ចស៊ើបសួរថ្មីទៀតនោះ ព្រះរាជអាជ្ញាត្រូវធ្វើតាមមាត្រា ១៣២ ( ការស្នើសុំឲ្យបំពេញកិច្ចដោយព្រះរាជអាជ្ញា ) នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ចៅក្រមស៊ើបសួរត្រូវបញ្ជូលសុំណុំរឿង ក្នុងរយៈពេល ១៥ ( ដប់ប្រាំ ) ឲ្យជនត្រូវចោទដែលត្រូវឃុំខ្លួន និង ១ ( មួយ ) ខែ ក្នុងករណីដែលជនត្រូវចោទនៅក្រៅឃុំ ព្រះរាជអាជ្ញាបង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរដោយមានដីកាសន្និដ្ឋានស្ថាពរភ្ជាប់ជាមួយផង។ ចិរវេលានេះត្រូវគិតពីថ្ងៃ ដែលព្រះរាជអាជ្ញាបានទទួលសំណុំរឿង។

ជនត្រូវចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី មានសិទ្ធិស្នើសុំឲ្យចៅក្រមស៊ើបសួរបំពេញកិច្ចណាមួយដែលជាផលប្រយោជន៍ដល់ខ្លួន ស្របតាមមាត្រា១៣៣ និងមាត្រា១៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ប្រសិនបើ ព្រះរាជអាជ្ញាយល់ឃើញដូចចៅក្រមស៊ើបសួរដែរថាការស៊ើបសួរត្រូវបានបញ្ចប់នោះព្រះរាជអាជ្ញាធ្វើដីកាសន្និដ្ឋានស្ថាពរជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ។ ព្រះរាជអាជ្ញា អាចប្ដឹងសុំឲ្យចៅក្រមស៊ើបសួរសម្រេចបញ្ជូនខ្លួនជនត្រូវចោទទៅកាន់តុលាការជំនុំជម្រះ ឬ ក៏លើកលែងចោទប្រកាន់។ [65]

### ១.៣. ដីកាដំណោះស្រាយ

ដីកាដំណោះស្រាយ សំដៅទៅលើដីកាចុងក្រោយដែលជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរធ្វើឡើងនៅពេលបញ្ចប់ដំណើរការស៊ើបសួរដែលអាចជាដីកាបញ្ជូនទៅជំនុំជម្រះ ឬ ដីកាលើកលែងការចោទប្រកាន់។[66]

#### ១.៣.១. ប្រភេទនៃដីកាដំណោះស្រាយ

##### ១.៣.១.១. ដីកាលើកលែងការចោទប្រកាន់

ចៅក្រមស៊ើបសួរចេញដីកាលើកលែងចោទប្រកាន់ក្នុងករណី អំពើប្រព្រឹត្ត មិនមែនជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ឬជនដែលត្រូវក្រុមប្រព្រឹត្តអំពើនោះនៅតែគេមិនស្គាល់ ឬគ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ ឬបណ្ដឹងអាជ្ញារលត់ ។

[64] មាត្រា២៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[65] មាត្រា២៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[66] មាត្រា២៤៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

ដីកាដំណោះស្រាយជានិច្ចកាលត្រូវតែមានសំអាងហេតុ។ ចៅក្រមស៊ើបសួរមិនត្រូវជាប់កាតព្វកិច្ចគោរពតាមដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញាទេ។ ដីកាដំណោះស្រាយត្រូវជូនដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុតដល់ព្រះរាជអាជ្ញា ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។[67] ប្រសិនបើចៅក្រមស៊ើបសួរសម្រេចលើកលែងចោទប្រកាន់ចូលជាស្ថាពរ បុគ្គលដែលអះអាងថាជាម្ចាស់វត្ថុចាប់យកអាចដាក់ពាក្យសុំ ទៅព្រះរាជអាជ្ញាឲ្យប្រគល់វត្ថុនោះមកខ្លួនវិញបាន។[68] ក្នុងករណីដែលជាដីកាលើកលែងចោទប្រកាន់ ដីកាដំណោះស្រាយនាំសេចក្តីសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្ន ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការត្រូវបានបញ្ចប់។

### ១.៣.១.២. ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ

កាលណាចៅក្រមស៊ើបសួរយល់ឃើញថា អំពើនោះ ជាបទឧក្រិដ្ឋ បទមជ្ឈិម បទលហុ ចៅក្រមស៊ើបសួរសម្រេចបញ្ជូនជនត្រូវចោទទៅមុខតុលាជំនុំជម្រះ ។ ដីកាបញ្ជូនត្រូវរៀបរាប់អំពើដែលត្រូវចោទប្រកាន់ ឈ្មោះបទល្មើសតាមច្បាប់។ ដីកាអាចជាដីកាបញ្ជូនទៅតុលាការជំនុំជម្រះចំពោះអំពើមួយចំនួន និងជាដីកាលើកលែងចោទប្រកាន់ចំពោះអំពើដទៃទៀត។[69]

### ១.៣.១.៣. អានុភាពនៃដីកាដំណោះស្រាយ

ដីកាដំណោះស្រាយចៅក្រមស៊ើបសួរសម្រេចអំពីការប្រគល់សងទៅឲ្យម្ចាស់ដើមវិញនូវវត្ថុដែលចាប់យក។ កាលណាចៅក្រមស៊ើបសួរសម្រេចសេចក្តីនៃដីកាដំណោះស្រាយ នោះត្រូវបញ្ចប់ការឃុំខ្លួនបណ្តោះអាសន្ន និងការត្រួតពិនិត្យតាមផ្លូវតាមតុលាការ។ ការបញ្ចប់ការឃុំខ្លួនបណ្តោះអាសន្ន ត្រូវយកមាត្រា ២៧៦ ( ការដោះលែងជនត្រូវចោទដែលជាប់ឃុំឲ្យមានសេរីភាព ) នៃក្រមនីតិវិធីព្រហ្មទណ្ឌមកអនុវត្ត។ ប៉ុន្តែតាមសេចក្តីសម្រេចដោយឡែកនៃដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរអាចរក្សាជនត្រូវចោទឲ្យនៅជាប់ឃុំបណ្តោះអាសន្ន រហូតដល់ពេលចូលបង្ហាញខ្លួននៅមុខតុលាការ។ នៅក្នុងដីកានេះ ចៅក្រមស៊ើបសួរត្រូវយោងតាមលក្ខខណ្ឌនៃ មាត្រា២០៥ ( មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន ) នៃនីតិវិធីព្រហ្មទណ្ឌ។

សេចក្តីសម្រេចរក្សាទុកជនត្រូវចោទក្នុងឃុំជាបណ្តោះអាសន្នលែងមានអនុភាពក្នុងរយៈពេល ៤ ( បួន ) ខែ។ ប្រសិនបើជនត្រូវចោទមិនបានចូលទៅបង្ហាញខ្លួននៅមុខតុលាការក្នុងរយៈពេល ៤ ( បួន) ខែនោះទេជនត្រូវចោទត្រូវបានដោះលែងឲ្យនៅក្រៅឃុំបណ្តោះអាសន្នដោយឯកឯង។ ដោយឡែកចំពោះការបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការ ចៅក្រមស៊ើបសួរអាចដាក់កំហិតដល់ជនត្រូវចោទឲ្យបង់ប្រាក់ធានាឲ្យប្រគល់ឯកសារបញ្ជាក់អំពីអត្តសញ្ញាណ ឬ ឲ្យប្រគល់អាវុធដែលមិនទាក់ទងនឹងបទល្មើសប្រាក់ធានាឯកសារបញ្ជាក់អំពីអត្តសញ្ញាណ ឬ អាវុធនោះត្រូវប្រគល់សងសាមីខ្លួនវិញ ដោយក្រឡាបញ្ជីដោយមានបង្កាន់ដៃទទួល ដែលចុះហត្ថលេខាដោយជនត្រូវចោទទុកជាសម្គាល់។

---

[67] មាត្រា២៤៧ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[68] មាត្រា១៩៩ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[69] មាត្រា២៤៧ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

ប៉ុន្តែតាមសេចក្តីសម្រេចដោយឡែកនៃដីកាដំណោះស្រាយចៅក្រមស៊ើបសួរអាចរក្សាទុកជនត្រូវចោទឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការរហូតដល់ពេលចូលបង្ហាញខ្លួននៅចំពោះមុខតុលាការ។[70]

ក្រោយពេលដែលដីកាលើកលែងចោទប្រកាន់របស់ចៅក្រមស៊ើបសួរ ឬ សាលដីកាលើកលែងចោទប្រកាន់របស់សភាស៊ើបសួរចូលជាស្ថាពរ ប្រសិនបើមានលិចឡើងបន្ទុកថ្មីការស៊ើបសួរអាចបើកឡើងវិញតាមការផ្តើមគំនិតរបស់ព្រះរាជអាជ្ញា មានន័យថាដីកាលើកលែងចោទប្រកាន់ ពុំមានអានុភាពអាជ្ញាអស់ជំនុំទេ។[71]

ប្រសិនបើចៅក្រមស៊ើបសួរសម្រេចចេញដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះចៅក្រមស៊ើបសួរបញ្ជូនសំណុំរឿងជាបន្ទាន់ទៅប្រធានតុលាការ ដើម្បីកំណត់ពេលសវនាការជំនុំជម្រះ។[72]

កាលណាដីកាដំណោះស្រាយចូលជាស្ថាពរនាំឲ្យលុបលាងមោឃភាពនៃនីតិវិធីមុន ប្រសិនបើមាន។ គ្មានមោឃភាពណាមួយ នៃនីតិវិធីមុនអាចត្រូវបានលើកឡើង នៅចំពោះមុខតុលាការជំនុំជម្រះបានទៀតឡើយ។[73]

[70] មាត្រា២៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[71] មាត្រា២៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[72] មាត្រា២៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[73] មាត្រា២៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

# ជំពូកទី២

# បណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ

# ជំពូកទី២

# បណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ

## ផ្នែកទី១៖ សញ្ញាណទូទៅនៃបណ្តឹងឧទ្ធរណ៍

### កថាខណ្ឌទី១៖ សញ្ញាណទូទៅ

សាលាឧទ្ធរណ៍ គឺជាសាលាជម្រះក្តីថ្នាក់ទីពីរ។ សាលាឧទ្ធរណ៍រួមមានសាលាឧទ្ធរណ៍ភ្នំពេញ និងសាលាឧទ្ធរណ៍តំបន់។ ការដាក់ដំណើរការសាលាឧទ្ធរណ៍តំបន់នីមួយៗ និងការកំណត់សមត្ថកិច្ចដែនដីនៃសាលាឧទ្ធរណ៍តំបន់នីមួយៗនេះត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ។[74] សាលាឧទ្ធរណ៍មានសមត្ថកិច្ចជំនុំជម្រះរឿងក្តីដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន លើកលែងតែរឿងក្តីទាំងឡាយណាដែលច្បាប់ប្រគល់សមត្ថកិច្ចទៅតុលាការផ្សេងទៀត។ [75] សមាសភាពសាលាឧទ្ធរណ៍ រួមមានប្រធាន អនុប្រធានចៅក្រម ក្រឡាបញ្ជី មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀត ដែលបម្រើការនៅសាលាឧទ្ធរណ៍។[76]

#### ១.១. និយមន័យនៃបណ្តឹងឧទ្ធរណ៍

បណ្តឹងឧទ្ធរណ៍ គឺជាការប្តឹងតវ៉ា ឬ ការប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេចផ្សេងៗរបស់ចៅក្រមស៊ើបសួរ ឬតុលាការជាន់ទាប។ គូភាគីអាចប្តឹងតវ៉ាចំពោះដីកា ឬសាលក្រមដែលខ្លួន មិនសុខចិត្តដោយយល់ឃើញថាសេចក្តីសម្រេច ឬ សាលក្រមនោះធ្វើឲ្យប៉ះពាល់ប្រយោជន៍របស់ខ្លួន។ ក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់យ៉ាងច្បាស់លាស់អំពីគោលការណ៍នៃសិទ្ធិក្នុងការធ្វើបណ្តឹងតវ៉ា ឬបណ្តឹងឧទ្ធណ៍។ បណ្តឹងតវ៉ានេះអាចបែងចែកជាពីរគឺការធ្វើបណ្តឹងតវ៉ាក្នុងកិច្ចនីតិវិធីនៃការស៊ើបសួរ។ បណ្តឹងតវ៉ាទីពីរគឺការប្តឹងតវ៉ាប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់តុលាការជាន់ទាប។ ការប្តឹងតវ៉ាចំពោះសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរ គឺស្តែងចេញតាមរយៈដីកា ហៅថាបណ្តឹងឧទ្ធណ៍លើដីកាសម្រេច និងការប្តឹងតវ៉ាវចំពោះសេចក្តីសម្រេចរបស់របស់តុលាការជាន់ទាបស្តែងចេញតាមរយៈសាលក្រម ហៅថាបណ្តឹងឧទ្ធណ៍លើសាលក្រម ។ ការបើកឲ្យមានសិទ្ធិប្តឹងតវ៉ា ឬការបើកសិទ្ធិឲ្យធ្វើបណ្តឹងឧទ្ធរណ៍នេះជាការបើកនូវផ្លូវមួយ ឬនូវឱកាសមួយសម្រាប់មានការពិភាក្សាដេញដោលដើម្បីឲ្យការស្វែងរកការពិតកាន់តែមានភាពសុក្រឹត និងយុត្តិធម៌។

#### ១.២. ទម្រង់នៃបណ្តឹងឧទ្ធរណ៍

ទម្រង់នៃបណ្តឹងឧទ្ធរណ៍ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ហើយបណ្តឹងឧទ្ធរណ៍អាចធ្វើឡើងដោយព្រះរាជអាជ្ញា ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ត្រូវធ្វើនៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម ឬដីកា ។

[74] មាត្រា៣៥ នៃច្បាប់ស្តីពីការរៀបចំអង្គតុលាការព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៤

[75] មាត្រា៤១ នៃច្បាប់ស្តីពីការរៀបចំអង្គតុលាការព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៤

[76] មាត្រា៣៨ នៃច្បាប់ស្តីពីការរៀបចំអង្គតុលាកាព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៤

ពិរុទ្ធជនអាចត្រូវបានតំណាងមេធាវី។ មេធាវីត្រូវតែមានលិខិតប្រគល់សិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍។ ក្នុងករណីពិរុទ្ធជនជាអនីតិជន ត្រូវតំណាងដោយ ឪពុក ម្តាយ ឬអាណាព្យាបាល ហើយអ្នកតំណាងមិនចាំបាច់មានលិខិតប្រគល់សិទ្ធិទេ។

ដើមបណ្តឹងរដ្ឋប្បវេណីអាចត្រូវបានតំណាងមេធាវី ឬញាតិលោហិតផ្ទាល់។ អ្នកតំណាងត្រូវតែមានលិខិតប្រគល់សិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍។

អ្នកទទួលខុសត្រូវរដ្ឋប្បវេណីអាចត្រូវបានតំណាងមេធាវី ឬញាតិលោហិតផ្ទាល់។ អ្នកតំណាងត្រូវតែមានលិខិតប្រគល់សិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍។

ក្រឡាបញ្ជីចុះបណ្តឹងឧទ្ធណ៍នៅលើបញ្ជីពិសេសដែលរក្សាទុកនៅក្នុងបញ្ជីតុលាការ ។ លិខិតបណ្តឹងឧទ្ធរណ៍ត្រូវមានចុះហត្ថលេខាដោយក្រឡាបញ្ជី និងអ្នកប្តឹងឧទ្ធរណ៍ ឬអ្នកតំណាង ។ លិខិតប្រគល់សិទ្ធិត្រូវភ្ជាប់ជាមួយនឹងលិខិតប្តឹងឧទ្ធរណ៍ ។[77]

## ផ្នែកទី២៖ នីតិវិធីបណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ

### កថាខណ្ឌទី១៖ ភាគីដែលមានសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍

នៅក្នុងរឿងក្តីព្រហ្មទណ្ឌគឺខុសពីរឿងក្តីរដ្ឋប្បវេណីដោយសាររឿងរដ្ឋប្បវេណី ជាទូទៅគេតែងឃើញថាភាគីមានតែពីរប៉ុណ្ណោះ ដើមចោទ និងចុងចម្លើយ។ ប៉ុន្តែនៅក្នុងរឿងព្រហ្មទណ្ឌវិញគឺយើងសង្កេតឃើញថា ភាគីគឺមានបីរួមមាន ភាគីជនល្មើស ភាគីខាងជនរងគ្រោះ និងភាគីអយ្យការ។ ភាគីខាងជនល្មើស និងភាគីខាងជនរងគ្រោះយើងអាចហៅម្យ៉ាងទៀតថាជាភាគីឯកជន រីឯភាគីមួយទៀតគឺអាយ្យការជាអ្នកដែលតំណាងឲសង្គម ឬប្រជាពលរដ្ឋធានាការពារនូវប្រយោជន៍ទូទៅ គឺជាភាគីសង្គម។ ដោយឡែកក្នុងករណីខ្លះ ភាគីមានតែពីរប៉ុណ្ណោះបើទោះបីជារឿងក្តីព្រហ្មទណ្ឌក៏ដោយ ជាក់ស្តែងនៅពេលមានបទល្មើសគ្រឿងញៀនមួយកើតឡើងជនម្នាក់ ជាអ្នកបង្កឲ្យមានបទល្មើសគឺជាភាគីជនល្មើស ដូច្នេះមិនមានភាគីជនរងគ្រោះទេ មានតែភាគីខាងជនល្មើស និងអយ្យការដែលតំណាងសង្គមអន្តរាគមន៍ដើម្បីការពារសណ្តាប់ធ្នាប់សាធារណៈ។ ក្រមនីតិវិធីព្រហ្មទណ្ឌបានដាក់ចេញនូវវិធានមួយចំនួនដែលជាសិទ្ធិរបស់ភាគី ឬបុគ្គលដែលអាចធ្វើបណ្តឹងឧទ្ធរណ៍បានរួមមាន ព្រះរាជអាជ្ញានៃតុលាការជាន់ដំបូង អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី ( ចំពោះផលប្រយោជន៍ផ្នែករដ្ឋប្បវេណី ) និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ( ចំពោះផលប្រយោជន៍ផ្នែករដ្ឋប្បវេណី )។[78]

[77] មាត្រា៣៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[78] មាត្រា៣៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

### ១.១. បណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងព្រះរាជអាជ្ញា

បណ្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងព្រះរាជអាជ្ញាត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរនៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម និងដីកា។ បន្ទាប់មកក្រឡាបញ្ជីនឹងចុះបណ្តឹងឧទ្ធរណ៍នៅលើបញ្ជីពិសេសដែលរក្សាទុកនៅក្នុងបញ្ជីនៃតុលាការ ហើយលិខិតប្តឹងឧទ្ធរណ៍ដែលបានដាក់ត្រូវចុះហត្ថលេខាដោយក្រឡាបញ្ជី និងអ្នកប្តឹងឧទ្ធរណ៍ ។

### ១.២. បណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយជនត្រូវចោទ

ជនត្រូវចោទ មានសិទ្ធិនៅក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចមួយចំនួនរបស់ចៅក្រមស៊ើបសួរដូចខាងក្រោម ៖

- ដីកាសម្រេចបដិសេធពាក្យសុំឲ្យធ្វើកិច្ចស៊ើបសួរ។
- ដីកាសម្រេចមិនព្រមប្រគល់វត្ថុដែលចាប់ឲ្យទៅម្ចាស់ដើម
- ដីកាសម្រេចបដិសេធពាក្យសុំឲ្យធ្វើកោសលវិច័យ
- ដីកាសម្រេចបដិសេធសុំឲ្យធ្វើកោសលវិច័យបន្ថែម ឬពាក្យសុំឲ្យធ្វើប្រតិកោសលវិច័យ។
- ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន និងការត្រួតពិនិត្យតាមផ្លូវតុលាការ។

បណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ ត្រូវធ្វើតាមប្រកាសប្តឹងនៅក្រឡាបញ្ជីនៃតុលាការជាន់ដំបូង។ បណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ បណ្តឹងឧទ្ធរណ៍ត្រូវចុះក្នុងបញ្ជីនៃបណ្តឹងឧទ្ធរណ៍របស់តុលាការ។[79] បណ្តឹងឧទ្ធរណ៍ អាចត្រូវធ្វើដោយមេធាវីរបស់ជនត្រូវចោទ ។ មេធាវីត្រូវតែមានលិខិតប្រគល់សិទ្ធិឲ្យធ្វើបណ្តឹងឧទ្ធរណ៍។ ក្នុងករណីជនត្រូវចោទ ជាអនីតិជន ត្រូវតំណាងដោយ ឪពុក ម្តាយ ឬអាណាព្យាបាល ហើយអ្នកតំណាងមិនចាំបាច់មានលិខិតប្រគល់សិទ្ធិទេ ។[80] បណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទដែលត្រូវបានឃុំខ្លួនត្រូវធ្វើ តាមការប្រកាសប្តឹងនៅមុខប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន។ ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនត្រូវប្រគល់ភ្លាមនូវ លិខិតប្តឹងឧទ្ធរណ៍មួយច្បាប់ជូនទៅក្រឡាបញ្ជីជាន់ដំបូង លិខិតនេះត្រូវបញ្ចូលទៅក្នុងបញ្ជីបណ្តឹងឧទ្ធរណ៍ ។[81]

កាលណាបានទទួលបណ្តឹងឧទ្ធរណ៍ ក្រឡាបញ្ជីនៅតុលាការជាន់ដំបូង ជូនដំណឹងភ្លាមដល់ចៅក្រមស៊ើបសួរ។ ក្រឡាបញ្ជីនៃចៅក្រមស៊ើបសួររៀបចំ និងបញ្ជូនសំណុំរឿងទៅសភាស៊ើបសួរដោយមានសេចក្តីចំលងនៃលិខិតប្តឹងឧទ្ធរណ៍ភ្ជាប់ជាមួយផង។ សេចក្តីចំលងនេះត្រូវធ្វើឡើងដោយក្រឡាបញ្ជីនៅតុលាការជាន់ដំបូង ក្រោយ

[79] មាត្រា២៧២ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[80] មាត្រា៣៧៦ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[81] មាត្រា២៧២ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

ពីបានឃើញ និងទោសដែលចុះក្នុងបញ្ជី បណ្តឹងឧទ្ធរណ៍។ សំណុំរឿងនេះត្រូវបញ្ជូនទៅការិយាល័យកឡាបញ្ជីនៃសភាស៊ើបសួរ។[82]

### ១.៣. បណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី

ដើមបណ្តឹងរដ្ឋប្បវេណី មានសិទ្ធិនៅក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចមួយចំនួនរបស់ចៅក្រមស៊ើបសួរដូចខាងក្រោម ៖

- ដីកាសម្រេចបដិសេធពាក្យសុំឲ្យធ្វើកិច្ចស៊ើបសួរ
- ដីកាសម្រេចកំណត់ចំនួនប្រាក់កក់
- ដីកាសម្រេចប្រកាសមិនទទួលពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី
- ដីកាសម្រេចផ្តន្ទាទោសដើមបណ្តឹងរដ្ឋប្បវេណី
- ដីកាសម្រេចមិនព្រមប្រគល់សងវត្ថុដែលចាប់យកឱ្យទៅម្ចាស់ដើមវិញ
- ដីកាសម្រេចបដិសេដពាក្យសុំឲ្យធ្វើកោសលវិច័យ
- ដីកាសម្រេចបដិសេដពាក្យសុំឱ្យធ្វើកោសលវិច័យបន្ថែម ឬពាក្យសុំឱ្យធ្វើប្រតិកោសលវិច័យ
- ដីកាដំណោះស្រាយ។

ដើមបណ្តឹងរដ្ឋប្បវេណីអាចត្រូវបានតំណាងមេធាវី ឬញាតិលោហិតផ្ទាល់ ។ អ្នកតំណាងត្រូវតែមានលិខិតប្រគល់សិទ្ធិឲ្យធ្វើបណ្តឹងឧទ្ធរណ៍។[83] បណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ នៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាក្រម និង ដីកា។ បន្ទាប់មកក្រឡាបញ្ជីនឹងចុះបណ្តឹងឧទ្ធរណ៍នៅលើបញ្ជីពិសេសដែលរក្សាទុកនៅក្នុងបញ្ជីនៃតុលាការ ហើយលិខិតប្តឹងឧទ្ធរណ៍ដែលបានដាក់ត្រូវចុះហត្ថលេខាដោយក្រឡាបញ្ជី និងអ្នកប្តឹងឧទ្ធរណ៍ ឬ អ្នកតំណាង ។[84]

### កថាខណ្ឌទី២៖ ប្រភេទដីកាដែលអាចធ្វើបណ្តឹងឧទ្ធរណ៍

បណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ រួមមាន បណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរធ្វើឡើងដោយ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ព្រះរាជអាជ្ញា បណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរធ្វើឡើងដោយជនត្រូវចោទ បណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរធ្វើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី ។

---

[82] មាត្រា២៧៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[83] មាត្រា៣៧៦ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[84] មាត្រា៣៧៦ កថាខណ្ឌទី៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

## ២.១. បណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និង ព្រះរាជាអាជ្ញា

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងព្រះរាជាអាជ្ញាអាចប្តឹងឧទ្ធរណ៍ចំពោះគ្រប់ដីកាសម្រេចទាំងអស់របស់ចៅក្របស៊ើបសួរ។[85] ក្នុងករណីដែលចៅក្រមស៊ើបសួរ ចេញដីកាបដិសេធមិនព្រមប្រគល់សងទេនោះ គ្រប់បុគ្គលដែលនៅក្រៅនីតិវិធីស៊ើបសួរ អាចដាក់ពាក្យប្តឹងឧទ្ធរណ៍ចំពោះដីកាបដិសេធមិនព្រមប្រគល់សងទៅឲ្យម្ចាស់ដើមវិញនូវវត្ថុដែលចាប់យក។[86]

## ២.២.បណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរដោយជនត្រូវចោទ

### ២.២.១. ដីកាបដិសេធពាក្យសុំអោយធ្វើកិច្ចស៊ើបសួរ

នៅគ្រប់ពេលវេលានៃការស៊ើបសួរ ជនត្រូវចោទអាចសុំឲ្យចៅក្រមស៊ើបសួរ ធ្វើការសួរចម្លើយខ្លួន ស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឬ សាក្សីសួរតទល់គ្នាឬចុះទៅទីកន្លែង។ ពាក្យសុំត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវមានសំអាងហេតុ។ ប្រសិនបើចៅក្រមស៊ើបសួរមិនព្រមធ្វើតាមពាក្យសុំនេះទេចៅក្រមរូបនេះត្រូវចេញដីកាបដិសេធនៅក្នុងថរិវេលា ១ ( មួយ ) ខែ បន្ទាប់ពីពេលទទួលពាក្យសុំដីកានេះត្រូវមានសំអាងហេតុ និងត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងចិរវេលា ១ ( មួយ ) ខែទេ ជនត្រូវចោទអាចប្តឹងដោយផ្ទាល់ តាមរយៈពាក្យសុំដល់សភាស៊ើបសួរដើម្បីសម្រេចជំនួសចៅក្រមស៊ើបសួរ។

### ២.២.២. ដីកាសម្រេចមិនព្រមប្រគល់វត្ថុដែលចាប់ឲ្យទៅម្ចាស់ដើមវិញ

នៅពេលដែលមិនទាន់ចេញដីកាដំណោះស្រាយរឿងនៅឡើយទេ ចៅក្រមស៊ើបសួរមានសមត្ថកិច្ចប្រគល់សងទៅម្ចាស់ដើមវិញនូវវត្ថុដែលចាប់បាន កាលណាកម្មសិទ្ធិនេះគ្មានការជំទាស់អ្វីប្រាកដប្រជាទេ។ ចៅក្រមស៊ើបសួរសម្រេចតាមដីកាដែលមានសំអាងហេតុ ក្រោយពីបានរួមមតិពីព្រះរាជអាជ្ញា។ ដីកាសម្រេច ត្រូវឲ្យដំណឹងជាបន្ទាន់ដល់អ្នកប្តឹង និងមេធាវីនៃអ្នកប្តឹងប្រសិនបើមាន។ ដោយឡែកចំពោះវត្ថុ ដែលមានគ្រោះថ្នាក់ដល់បុគ្គល ឬទ្រព្យសម្បត្តិដូចជាអាវុធ ឬជាតិផ្ទុះ ព្រមទាំងវត្ថុដែលធ្វើការកាន់កាប់មិនស្របច្បាប់ មិនអាចប្រគល់ជូនវិញបានទេ។ វត្ថុទាំងនេះត្រូវរឹបអូសជារបស់រដ្ឋ។ម្យ៉ាងទៀតមិនគួរប្រគល់ឲអ្នកប្តឹងវិញទេ កាលណាវិធាននេះ អាចបង្កជាឧបសគ្គដល់ការស្វែងរកការពិត។[87] នៅក្នុងដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរសម្រេចអំពីការប្រគល់សងទៅម្ចាស់ដើមវិញនូវវត្ថុដែលចាប់យក។

---

[85] មាត្រា២៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[86] មាត្រា២៦៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[87] មាត្រា១៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

### ២.២.៣. ដីកាសម្រេចបដិសេធពាក្យសុំឲ្យធ្វើកោសលវិច័យ

ព្រះរាជអាជ្ញារបស់ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី អាចស្នើសុំឲ្យចៅក្រមស៊ើបធ្វើកោសលវិច័យតាមពាក្យសុំ នៅក្នុងករណីដែលមានបញ្ហាចោទសួរកើតឡើង។ កាលណាចៅក្រមស៊ើបសួរបដិសេធមិនព្រមធ្វើតាមពាក្យសុំកោសលវិច័យ ចៅក្រមស៊ើបសួរ ត្រូវសម្រេចតាមដីកាដែលមានសំអាងហេតុ។ ដីកាត្រូវសម្រេចក្នុងរយៈពេល៥ ( ប្រាំ) ថ្ងៃ ប្រសិនបើពាក្យសុំចេញមកពីព្រះរាជអាជ្ញា និង ១ ( មួយ) ខែ ប្រសិនបើពាក្យសុំចេញពីជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី។ ដីកាសម្រេចនេះត្រូវជូនដំណឹងដល់អ្នកប្តឹងសុំជាបន្ទាន់។[88]

សោហ៊ុយក្នុងការធ្វើកោសលវិច័យជាបន្ទុករបស់អ្នកស្នើ។ កាលណាចៅក្រមស៊ើបសួរ ព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ ស្នើសុំឲ្យធ្វើកោសលវិច័យ កោសលវិច័យបន្ថែម ឬធ្វើប្រតិកោសល្យវិច័យ សោហ៊ុយទាំងនេះជាបន្ទុករបស់រដ្ឋ។[89]

### ២.២.៤. ដីកាសម្រេចបដិសេធសុំឲ្យធ្វើកោសលវិច័យបន្ថែម ឬពាក្យសុំឲ្យធ្វើប្រតិកោសលវិច័យ

កាលណាចៅក្រមស៊ើបសួរមិនព្រមធ្វើតាមពាក្យសុំធ្វើកោសលវិច័យបន្ថែម ឬប្រតិកោសលវិច័យទេ ចៅក្រមស៊ើបសួរត្រូវសម្រេចតាមដីកាដោយមានសំអាងហេតុ។ ដីកាត្រូវសម្រេចក្នុងរយៈពេល ៥ ( ប្រាំ ) ថ្ងៃប្រសិនបើពាក្យសុំចេញមកពីព្រះរាជអាជ្ញា និង ១ ( មួយ ) ខែ ប្រសិនបើពាក្យនេះចេញ ត្រូវចោទឬដើមបណ្តឹងរដ្ឋប្បវេណី ដីកាត្រូវឲ្យដំណឹងជាបន្ទាន់ដល់អ្នកប្តឹងសុំ។[90] គ្រប់ពាក្យសុំធ្វើកោសលវិច័យបន្ថែម ឬប្រតិកោសលវិច័យដែលធ្វើឡើងក្រោយពីផុតរយៈពេលដែលកំណត់ដោយចៅក្រមស៊ើបសួរ ត្រូវដាក់បញ្ចូលក្នុងសំណុំរឿង។[91]ប្រសិនបើចៅក្រមស៊ើបសួរដែលបានទទួលពាក្យសុំឲ្យធ្វើកោសលវិច័យ ធ្វើកោសលវិច័យបន្ថែម ឬប្រតិកោសលវិច័យ មិនព្រមសម្រេចក្នុងរយៈពេលដែលបានចែងក្នុងកថាខណ្ឌទី២ នៃមាត្រា១៦២ (ភាពចាំបាច់នៃការធ្វើកោសលវិច័យ) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឬចែងក្នុងមាត្រា១៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ អ្នកសុំអាចធ្វើពាក្យបណ្តឹងដោយផ្ទាល់តាមរយៈពាក្យសុំទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។[92]សោហ៊ុយក្នុងការធ្វើកោសលវិច័យជាបន្ទុករបស់អ្នកស្នើសុំ។ កាលណាចៅក្រមស៊ើបសួរ ព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ ស្នើសុំឲ្យធ្វើកោសលវិច័យ និងកោសលវិច័យបន្ថែម ឬធ្វើប្រតិកោសលវិច័យ សោហ៊ុយទាំងនេះជាបន្ទុករបស់រដ្ឋ។[93]

---

[88] មាត្រា១៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[89] មាត្រា១៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[90] មាត្រា១៧០ កថាខណ្ឌទី៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[91] មាត្រា១៧០ កថាខណ្ឌទី៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[92] មាត្រា១៧០ កថាខណ្ឌទី៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[93] មាត្រា១៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

#### ២.២.៥. ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន និងការត្រួតពិនិត្យតាមផ្លូវតុលាការ

ជនត្រូវចោទអាចដាក់ពាក្យសុំឲ្យដោះលែងនៅក្រៅឃុំ និងសុំឲ្យលើកលែង ឬកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា។ ចៅក្រមស៊ើបសួរបញ្ជូនពាក្យសុំនេះភ្លាមទៅព្រះរាជអាជ្ញា ដើម្បីសុំយោបល់និងបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីពិនិត្យ។ ចៅក្រមស៊ើបសួរសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល៥ ( ប្រាំ ) ថ្ងៃ គិតចាប់ពីថ្ងៃបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។ ដីកាសម្រេចនេះត្រូវជូនដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។ កាលណាពាក្យសុំឲ្យដោះលែងនៅក្រៅឃុំ និងពាក្យសុំឲ្យលើកលែង ឬកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការបានធ្វើជាថ្មី មុនពេលចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរសម្រេចលើពាក្យសុំពីមុននោះ រយៈពេល ៥ ( ប្រាំ ) ថ្ងៃនេះ ត្រូវចាប់ផ្តើមគិតពីពេលចេញដីកាសម្រេចលើពាក្យសុំមុន។ ដីកាដែលសម្រេច មិនព្រមធ្វើតាមពាក្យសុំត្រូវតែមានសំអាងហេតុ។ ប្រសិនបើចៅក្រមស៊ើបសួរមិនសម្រេចក្នុងរយៈពេល ៥ ( ប្រាំ ) ថ្ងៃនេះទេ ជនត្រូវចោទអាចធ្វើពាក្យបណ្តឹងទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។[94]

### ២.៣. បណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចចៅក្រមស៊ើបសួរដោយដើមបណ្តឹងរដ្ឋប្បវេណី

#### ២.៣.១. ដីកាសម្រេចបដិសេធពាក្យសុំឲ្យធ្វើកិច្ចស៊ើបសួរ

បុគ្គលគ្រប់រូបដែលបានប្រកាសថាខ្លួនជាជនរងគ្រោះអាចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរបាន។[95] ក្នុងករណីដែលចៅក្រមស៊ើបសួរសម្រេចមិនស៊ើបសួរចៅក្រមស៊ើបសួររូបនេះត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុ ដែលត្រូវជូនដំណឹងបន្ទាន់ដល់ដើមបណ្តឹងរដ្ឋប្បវេណី។[96]

នៅគ្រប់ពេលវេលានៃការស៊ើបសួរ ដើមបណ្តឹងរដ្ឋប្បវេណីអាចសុំដល់ចៅក្រមស៊ើបសួរឲ្យស្តាប់ចម្លើយខ្លួន ស្តាប់ចម្លើយសាក្សី សួរចម្លើយជនត្រូវចោទ សួរតទល់គ្នា ឬចុះទៅដល់ទីកន្លែង។ ពាក្យសុំត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ។ ប្រសិនបើចៅក្រមស៊ើបសួរមិនព្រមធ្វើតាមពាក្យសុំនេះ ចៅក្រមរូបនេះ ត្រូវចេញដីកាបដិសេធក្នុងថេរៈវេលា១ (មួយ) ខែ ក្រោយពេលទទួលពាក្យសុំ។ ដីកានេះត្រូវមានសំអាងហេតុហើយត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា និងដល់ដើមបណ្តឹងរដ្ឋប្បវេណី។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងថិរវេលា ១ ( មួយ ) ខែ ដើមបណ្តឹងរដ្ឋប្បវេណីអាចប្តឹងដោយផ្ទាល់តាមរយៈពាក្យសុំដល់សភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។[97]

---

[94] មាត្រា២១៧ និង២២៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[95] មាត្រា១៣៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[96] មាត្រា១៣៩ កថាខណ្ឌទី៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[97] មាត្រា១៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

### ២.៣.២. ដីកាសម្រេចកំណត់ចំនួនប្រាក់កក់

ដោយផ្អែកទៅលើធនធាន នៃដើមបណ្តឹងរដ្ឋប្បវេណីនិងទៅលើការលំបាកនៃរឿងដែលអាចមើលឃើចំនួន ចៅក្រមស៊ើបសួរ កំណត់តាមដីកាសម្រេចនូវចំនួនទឹកប្រាក់ ដែលដើមបណ្តឹងរដ្ឋប្បវេណីត្រូវបង់ព្រមទាំងរយៈពេល ដែលត្រូវបង់ប្រាក់នេះផង។[98]

### ២.៣.៣. ដីកាសម្រេចប្រកាសមិនទទួលពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

ប្រសិនបើប្រាក់តម្កល់ មិនត្រូវបានបង់ក្នុងរយៈពេល ដែលបានកំណត់ដោយចៅក្រមស៊ើបសួរទេ ពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានប្រកាសថាមិនអាចទទួលបានដោយចៅក្រមស៊ើបសួរ។[99] ដើមបណ្តឹងរដ្ឋប្បវេណី អាចប្តឹងផ្ទាល់ទៅសភាស៊ើបសួរ ក្នុងរយៈពេល ៥ ( ប្រាំ ) ថ្ងៃ បន្ទាប់ពីបានទទួលដំណឹងអំពីការច្រាលចោលពាក្យបណ្តឹងដោយចៅក្រមស៊ើបសួរ។

### ២.៣.៤. ដីកាសម្រេចផ្តន្ទាទោសដើមបណ្តឹងរដ្ឋប្បវេណី

ប្រសិនបើការស៊ើបសួរដែលបានបើកបន្ទាប់ពីមានពាក្យប្តឹង ដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានបិទតាមដីកាលើកលែងចោទប្រកាន់ ហើយប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថានីតិវិធីធ្វើឡើងដោយ រំលោភ ឬ ដែលអូសបន្លាយពេលវេលា នោះចៅក្រមស៊ើបសួរអាចសម្រេចតាមដីកាសម្រេចឲ្យដើមបណ្តឹងរដ្ឋប្បវេណីបង់ប្រាក់ពិន័យរដ្ឋប្បវេណី។ ចំនួនទឹកប្រាក់ពិន័យមិនអាចលើសពីទឹកប្រាក់តម្កល់ទុកឡើយ។ ដីកាសម្រេចឲ្យបង់ប្រាក់ពិន័យនេះត្រូវឲ្យដំណឹងដល់សាមីខ្លួនជាបន្ទាន់។[100]

### ២.៣.៥. ដីកាសម្រេចមិនព្រមប្រគល់សងវត្ថុដែលចាប់យកឲ្យទៅម្ចាស់ដើមវិញ

នៅពេលដែលមិនទាន់ចេញដីកាដំណោះស្រាយរឿងនៅឡើយទេ ចៅក្រមស៊ើបសួរមានសមត្ថកិច្ចប្រគល់សងទៅម្ចាស់ដើមវិញនូវវត្ថុដែលចាប់បាន កាលណាកម្មសិទ្ធិនោះគ្មានការជំទាស់អ្វីប្រាកដប្រជាទេ។ ចៅក្រមស៊ើបសួរសម្រេចតាមដីកាដែលមានសំអាងហេតុក្រោយពីបានទទួលមតិពីព្រះរាជអាជ្ញា។ ដីកាសម្រេចត្រូវឲ្យដំណឹងជាបន្ទាន់ដល់អ្នកប្តឹង និងមេធាវីនៃអ្នកតំណាងប្រសិនបើមាន។ មិនត្រូវប្រគល់សងទៅឲ្យអ្នកប្តឹងទេ កាលណាវិធានការនេះអាចបង្កឲ្យជាឧបសគ្គដល់ការសម្តែងឲ្យឃើញការពិត។ អាចប្រគល់ឲ្យបានតែវត្ថុណាដែលមិននាំគ្រោះថ្នាក់តែប៉ុណ្ណោះ។ ដោយឡែកវត្ថុដែលមានគ្រោះថ្នាក់ដល់ បុគ្គល ឬទ្រព្យសម្បត្តិជាអាវុធជាតិផ្ទុះ ព្រមទាំងអាវុធដែលកាន់កាប់ដោយមិនស្របច្បាប់។ មិនអាចត្រូវប្រគល់សង ឲ្យសាមីខ្លួនបានទេវត្ថុទាំងនេះត្រូវរឹបអូសជាទ្រព្យសម្បត្តិរបស់រដ្ឋ។[101]

[98] មាត្រា១៤០ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[99] មាត្រា១៤០ កថាខណ្ឌទី៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[100] មាត្រា១៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[101] មាត្រា១៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

នៅក្នុងដីកាដំណោះស្រាយចៅក្រមស៊ើបសួរ សម្រេចអំពីការប្រគល់សងទៅឲ្យម្ចាស់ដើមវិញនូវវត្ថុដែលចាប់យក បទប្បញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ១១៩ ( អាជ្ញាធរមានសមត្ថកិច្ចបង្គាប់ឲ្យប្រគល់វត្ថុជូនម្ចាស់ដើមវិញ) នៃក្រមនីតិវិធីព្រហ្មទណ្ឌក៏ត្រូវយកមកអនុវត្តដែរ ។[102]

### ២.៣.៦. ដីកាសម្រេចបដិសេធពាក្យសុំឲ្យធ្វើកោសលវិច័យ

ដើមបណ្តឹងរដ្ឋប្បវេណី អាចស្នើសុំឲ្យចៅក្រមស៊ើបសួរ ធ្វើកោសល្យវិច័យតាមពាក្យសុំ នៅក្នុងករណីដែលមានបញ្ហាចោទសួរកើតឡើង។ កាលណាចៅក្រមស៊ើបសួរ បដិសេធមិនព្រមធ្វើតាមពាក្យសុំកោសលវិច័យ ចៅក្រមស៊ើបសួរត្រូវសម្រេចតាមដីកាដែលមានសំអាងហេតុ។ ដីកាត្រូវសម្រេចក្នុងរយៈពេល៥ ( ប្រាំ) ថ្ងៃ ប្រសិនបើពាក្យសុំចេញមកពីព្រះរាជអាជ្ញា និង ១ ( មួយ) ខែ ប្រសិនបើពាក្យសុំចេញពីជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី។ ដីកាសម្រេចនេះត្រូវជូនដំណឹងដល់អ្នកប្តឹងសុំជាបន្ទាន់។[103]

### ២.៣.៧. ដីកាសម្រេចបដិសេធពាក្យសុំឲ្យធ្វើកោសលវិច័យបន្ថែម ឬពាក្យសុំឲ្យធ្វើប្រតិកោសលវិច័យ

កាលណាចៅក្រមស៊ើបសួរ មិនព្រមធ្វើតាមពាក្យសុំធ្វើកោសលវិច័យបន្ថែម ឬប្រតិកោសលវិច័យទេ ចៅក្រមស៊ើបសួរត្រូវសម្រេចតាមដីកាដោយមានសំអាងហេតុ។ ដីកាត្រូវសម្រេចក្នុងរយៈពេល ៥ ( ប្រាំ ) ថ្ងៃប្រសិនបើពាក្យសុំចេញមកពីព្រះរាជអាជ្ញា និង ១ ( មួយ ) ខែ ប្រសិនបើពាក្យនេះចេញ ត្រូវចោទឬដើមបណ្តឹងរដ្ឋប្បវេណី ដីកាត្រូវឲ្យដំណឹងជាបន្ទាន់ដល់អ្នកប្តឹងសុំ។[104]

### ២.៣.៨. ដីកាដំណោះស្រាយ

ដីកាដំណោះស្រាយនេះអាចប៉ះពាល់ខ្លាំងដល់សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដោយសារដីកាដំណោះស្រាយនេះអាចជាដីកាសម្រេចបិទការស៊ើបសួរតាមរយៈការលើកលែងចោទប្រកាន់ ឬក៏តាមរយៈការបញ្ជូនរឿងទៅជំនុំជម្រះ។ កាលណាចៅក្រមស៊ើបសួរបិទការស៊ើបសួរ ដោយការលើកលែងការចោទប្រកាន់វាច្បាស់ជាប៉ះពាល់ដល់សិទ្ធិរបស់ជនរងគ្រោះ ឬ អ្នកដែលតាំងខ្លួនដើមបណ្តឹងរដ្ឋប្បវេណី ដោយហេតុថាការលើកលែងចោទប្រកាន់នឹងធ្វើឲ្យដើមបណ្តឹងរដ្ឋប្បវេណី មិនបានទទួលសំណង ដូច្នេះដើមបណ្តឹងរដ្ឋប្បវេណី មានសិទ្ធិប្តឹងទៅសភាស៊ើបសួរ។ ហើយមួយទៀតគឺទាក់ទងនឹងដីកាបញ្ជូនទៅជំនុំជម្រះដែលជាផ្នែកមួយនៃដីកាដោះស្រាយ កាលណាជនរងគ្រោះយល់ឃើញថាជនដែលត្រូវចោទ ហើយដែលក្លាយជាជនជាប់ចោទក្នុងដីកាបញ្ជូនទៅជម្រះ មិនមែនជាជនល្មើសពិតប្រាកដ ហើយការធ្វើការស៊ើបសួរនេះ ឬការចោទប្រកាន់នេះ ធ្វើឲ្យជនល្មើសរួចខ្លួន ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិ

[102] មាត្រា២៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[103] មាត្រា១៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[104] មាត្រា១៧០ កថាខណ្ឌទី៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

ប្តឹងទៅសភាស៊ើបសួរដើម្បីសើរើវិសាលភាពនៃដីកានេះដើម្បីពន្លាតទៅលើបុគ្គលដែលពាក់ព័ន្ធពិតប្រាកដ។ ដីកាដំណោះស្រាយត្រូវជូនដំណឹងក្នុងរយៈពេលខ្លីបំផុត ដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។[105]

## កថាខណ្ឌទី៣៖ លំហូរនៃការធ្វើពាក្យបណ្តឹងឧទ្ធរណ៍ទៅសភាស៊ើបសួរ

### ៣.១. ការដាក់ពាក្យបណ្តឹង

បណ្តឹងឧទ្ធរណ៍ត្រូវធ្វើតាមប្រកាសប្តឹង នៅក្រឡាបញ្ជីនៃតុលាការជាន់ដំបូង។ បណ្តឹងឧទ្ធរណ៍ត្រូវចុះក្នុងបញ្ជីនៃបណ្តឹងឧទ្ធរណ៍របស់តុលាការ។ បណ្តឹងឧទ្ធរណ៍អាចត្រូវធ្វើឡើងដោយមេធាវីរបស់ជនត្រូវចោទរបស់ ដើមបណ្តឹងរដ្ឋប្បវេណី ឬរបស់បុគ្គលដែលមានចែងនៅក្នុងមាត្រា ២៦៩ ( បណ្តឹងឧទ្ធរណ៍ចំពោះដីកាបដិសេធមិនព្រមប្រគល់វត្ថុដែលរឹបអូសទៅម្ចាស់ដើមវិញ) នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ បណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទត្រូវបានឃុំខ្លួនត្រូវធ្វើឡើងតាមការប្រកាសប្តឹងទៅមុខប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន។ ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនត្រូវប្រគល់ភ្លាមនូវលិខិតប្តឹងឧទ្ធរណ៍មួយច្បាប់ ជូនទៅក្រឡាបញ្ជីនៅតុលាការជាន់ដំបូង។ លិខិតត្រូវបញ្ចូលទៅក្នុងបញ្ជីបណ្តឹងឧទ្ធរណ៍។

កាលណាទទួលបណ្តឹងឧទ្ធរណ៍ ក្រឡាបញ្ជីនៅតុលាការជាន់ដំបូងជូនដំណឹងភ្លាមទៅដល់ចៅក្រមស៊ើបសួរ។ ក្រឡាបញ្ជីនៃចៅក្រមស៊ើបសួរ រៀបចំនិងបញ្ជូនសំណុំរឿងទៅសភាស៊ើបសួរ ដោយមានសេចក្តីចម្លងនៃលិខិតប្តឹងឧទ្ធរណ៍ភ្ជាប់ជាមួយផង។ សេចក្តីចម្លង ត្រូវធ្វើឡើងដោយក្រឡាបញ្ជីនៃតុលាការជាន់ដំបូងក្រោយពីបានឃើញនិទ្ទេសដែលចុះក្នុងបញ្ជីបណ្តឹងឧទ្ធរណ៍។ សំណុំរឿងនេះត្រូវបញ្ជូនទៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរនៅក្នុងរយៈពេល ៥ ( ប្រាំ ) ថ្ងៃ បន្ទាប់ពីមានបណ្តឹងឧទ្ធរណ៍។ លើកលែងថាក្នុងកាលៈទេសៈមិនអាចជម្នះបាន។

### ៣.២. រយៈពេលនៃបណ្តឹងឧទ្ធរណ៍

បណ្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ត្រូវធ្វើឡើងក្នុងរយៈពេល ១ ( មួយ) ខែ យ៉ាងយូរគិតពីពេលប្រកាសដីកា។ បណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា ត្រូវធ្វើឡើងក្នុងរយៈពេល ៥ ( ប្រាំ) ថ្ងៃចាប់ពីថ្ងៃជូនដំណឹងអំពីដីកានេះ។ បណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងរបស់បុគ្គលដែលមានចែងក្នុងមាត្រា ២៦៩ ( បណ្តឹងឧទ្ធរណ៍ដែលបដិសេធមិនព្រមប្រគល់វត្ថុដែលរឹបអូសទៅម្ចាស់ដើមវិញ ) នៃក្រមនីតិវិធីព្រហ្មទណ្ឌត្រូវធ្វើឡើងក្នុងរយៈវេលា ៥ (ប្រាំ) ថ្ងៃ គិតពីការជូនដំណឹងដីកា។ ប្រសិនបើការជូនដំណឹងធ្វើឡើងដោយការប្រគល់សេចក្តីចម្លងនៃដីកាដោយមានចំណារទទួលនោះ រយៈពេលបណ្តឹងឧទ្ធរណ៍ ផ្តើមគិតពីកាលបរិច្ឆេទនៃចំណារទទួលនោះ។

### ៣.៣. អានុភាពនៃបណ្តឹងឧទ្ធរណ៍

ក្នុងករណីមានបណ្តឹងឧទ្ធរណ៍ចំពោះដីកាណាមួយ ក្រៅពីដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរអាចបន្តការស៊ើបសួររបស់ខ្លួនបាន លើកលែងតែមានសេចក្តីសម្រេចផ្ទុយរបស់ប្រធានសភាស៊ើបសួរ។ សេចក្តីសម្រេចនេះមិន

[105] មាត្រា២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

អាចតវ៉ាបានឡើយ។[106] កាលណាចៅក្រមស៊ើបសួរសម្រេចឲ្យដោះលែងជនត្រូវចោទ ដែលជាប់ឃុំបណ្ដោះអាសន្ន ជនត្រូវចោទនោះ ត្រូវបានរក្សាទុកនៅក្នុងពន្ធនាគារ រហូតដល់ផុតរយៈពេលសម្រាប់បណ្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា លើកលែងតែព្រះរាជអាជ្ញាយល់ស្របឲ្យដោះលែងជនត្រូវចោទនោះភ្លាម។ សេចក្ដីសម្រេចជាលាយលក្ខណ៍អក្សររបស់ព្រះរាជអាជ្ញា ត្រូវដាក់បញ្ចូលសំណុំរឿងនៃនីតិវិធី។ ត្រូវធ្វើដូចគ្នានេះដែរ ចំពោះដីកាលើកលែងចោទប្រកាន់ កាលណាដីកានេះមានអានុភាពនាំឲ្យដោះលែងជនត្រូវចោទដែលជាប់ឃុំ។ ក្នុងករណីបណ្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា អំពីដីកាដោះលែងឲ្យនៅក្រៅឃុំ ឬ លើកលែងចោទប្រកាន់នោះ ជនត្រូវចោទដែលជាប់ឃុំ ត្រូវបានរក្សាទុកក្នុងពន្ធនាគារ រហូតទាល់តែសភាស៊ើបសួរ បានសម្រេចអំពីបណ្ដឹងឧទ្ធរណ៍។[107]

កាលណាទទួលបណ្ដឹងឧទ្ធរណ៍ចំពោះដីកាលើកលែងចោទប្រកាន់សភាស៊ើបសួរសម្រេចតាមបទប្បញ្ញត្តិដូចដែលបានចែងនៅក្នុងចំណុចទី ៣ មាត្រា ២៨១ ( ផលវិបាកនៃមោឃៈកម្ម ) នៃក្រមនីតិវិធីព្រហ្មទណ្ឌ។[108]

[106] មាត្រា២៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[107] មាត្រា២៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[108] មាត្រា២៧៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

# ជំពូកទី៣
# សមាសើបស្នូរនៃសាលាឧទ្ធរណ៍

# ជំពូកទី៣
# សភាស៊ើបសួរនៃសាលាឧទ្ធរណ៍

## ផ្នែកទី១៖ សញ្ញាណទូទៅនៃសភាស៊ើបសួរ

### កថាខណ្ឌទី១៖ សមត្ថកិច្ចរបស់សភាស៊ើបសួរ

នៅក្នុងសាលាឧទ្ធរណ៍មានសភាពិសេសមួយដែលមានឈ្មោះថា សភាស៊ើបសួរ។ សភានេះមានសមត្ថកិច្ចជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ ដែលធ្វើឡើងប្រឆាំងនឹងសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរ នឹងរឿងក្តីផ្សេងទៀតដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីព្រហ្មទណ្ឌជាធរមាន។ សេចក្តីសម្រេចរបស់សភាស៊ើបសួរត្រូវធ្វើឡើងដោយចៅក្រម ០៣ ( បី ) រូបដែល ០១ ( មួយ) រូបជាប្រធាន។[109] សមាជិកនៅសភាស៊ើបសួរពុំអាចចូលរួមក្នុងការជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌ ដែលខ្លួនបានចាត់ការក្នុងឋានៈចៅក្រមស៊ើបសួរបានទេ បើមិនដូច្នោះទេ សាលដីកានោះត្រូវចាត់ទុកជាមោឃៈ។

#### ១.១. ការត្រួតពិនិត្យនិយ័តភាពនៃកិច្ចស៊ើបសួររបស់មន្ទីរស៊ើបសួរ

នៅរាល់ពេលដែលទទួលបានបណ្តឹងសភាស៊ើបសួរពិនិត្យមើលនិយ័តភាព នៃនីតិវិធីនិងការប្រព្រឹត្តិទៅនៃនីតិវិធីនេះ។[110] ជាគោលការណ៍ដើម្បីអនុវត្តនូវសិទ្ធិអំណាចមួយនេះ សភាស៊ើបសួរត្រូវទទួលពាក្យបណ្តឹងពីអ្នកដែលមានសិទ្ធិប្តឹង មិនអាចធ្វើការត្រួតពិនិត្យដោយឯកឯងបានទេ។ ការអនុវត្តអំណាចក្នុងការត្រួតពិនិត្យអំពីនិយ័តភាព ដោយការដាក់ពាក្យប្តឹងសុំមោឃភាព ដែលអាចធ្វើបានដោយ ព្រះរាជអាជ្ញា ជនត្រូវចោទដើមបណ្តឹងរដ្ឋប្បវេណី កាលណាយល់ឃើញថា កិច្ចណាមួយនៃនីតិវិធីមានភាពមិនប្រក្រតី អនុវត្តខុសនឹងក្រមនីតិវិធីព្រហ្មទណ្ឌ ធ្វើឲ្យប៉ះពាល់ផលប្រយោជន៍របស់ភាគី។[111] ម្យ៉ាងវិញទៀតសភាស៊ើបសួរ អាចធ្វើការពិនិត្យនិយ័តភាពនៃកិច្ចស៊ើបសួរ ប៉ុន្តែមិនមែនក្នុងក្របខណ្ឌនៃបណ្តឹងសុំមោឃភាពនោះទេ អាចទទួលបណ្តឹងផ្សេងទៀតដែលអនុញ្ញាតឲ្យសភាស៊ើបសួរ មានសមត្ថកិច្ចយកសំណុំរឿងនីតិវិធីមកពិនិត្យ។ កាលណាពិនិត្យឃើញមូលហេតុនៃមោឃភាព សភាស៊ើបសួរអាចចាត់ទុកជាមោឃៈដោយឯកឯងនូវនីតិវិធីទាំងមូល ឬផ្នែកណាមួយ។[112]

#### ១.២. កិច្ចស៊ើបសួរបន្ថែម

សភាស៊ើបសួរអាចបង្គាប់ឲ្យធ្វើកិច្ចស៊ើបសួរបំពេញបន្ថែម តាមដែលខ្លួនយល់ឃើញថាមានប្រយោជន៍។ សភាស៊ើបសួរអាចដកសមត្ថកិច្ចចៅក្រមស៊ើបសួរ ហើយបន្តការស៊ើបសួរដោយផ្ទាល់។ ម្យ៉ាងវិញទៀតសភាស៊ើបសួរក៏អាចចាត់តាំងសមាជិកម្នាក់របស់សភាស៊ើបសួរ ឬ ក៏ចៅក្រមស៊ើបសួរណាម្នាក់ដែលខ្លួនប្រគល់អំណាចឲ្យ ដើម្បីបំពេញកិច្ចនេះ។ ចៅក្រមស៊ើបសួរដែលទទួលភារកិច្ចស៊ើបសួរនោះ អាចប្រើប្រាស់សិទ្ធិអំណាចទាំងអស់របស់

[109] មាត្រា៤៥ នៃច្បាប់ស្តីពីការរៀបចំអង្គតុលាការព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៤

[110] មាត្រា២៦១ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[111] មាត្រា២៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[112] មាត្រា២៦១ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

ចៅក្រមស៊ើបសួរនៅក្នុងព្រំដែនកំណត់នៃសភាស៊ើបសួរ។ ចៅក្រមស៊ើបសួរដែលត្រូវបានចាត់តាំងដោយសភាស៊ើបសួរមិនអាចធ្វើការបិទសំណុំរឿងដោយចេញដីកាដំណោះស្រាយបានទេ មានតែសភាស៊ើបសួរប៉ុណ្ណោះដែលមានអំណាចនៃការបិទការស៊ើបសួរដោយដីកាដំណោះស្រាយ ដែលសាលដីកានេះអាចជាសាលដីកាបញ្ជូនទៅជំនុំជម្រះ ឬ សាលដីកាលើកលែងចោទប្រកាន់។ កាលណាកិច្ចស៊ើបសួរត្រូវបានបំពេញរួចហើយសំណុំរឿងនៃនីតិវិធីត្រូវយកមកតម្កល់ទុកនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ។ ប្រធានសភាស៊ើបសួរកំណត់កាលបរិច្ឆេទនៃសវនាការថ្មី បទបញ្ញត្តិនៃមាត្រា ២៥៩ ( ការពិគ្រោះសំណុំរឿង និងសារណា) នៃក្រមនីតិវិធីព្រហ្មទណ្ឌមកអនុវត្ត។[113]

### ១.៣. ការពន្លាតការចោទប្រកាន់ទៅលើបទល្មើសផ្សេងទៀត

សភាស៊ើបសួរ ដោយឯកឯង ឬ តាមសេចក្តីសន្និដ្ឋានរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អាចបង្គាប់ឲ្យពន្លាតការដាក់ឲ្យស្ថិតក្រោមការពិនិត្យដល់បទល្មើសដែលទាក់ទងគ្នា នឹងបទល្មើសដែលចង្អុលដៃចៅក្រមស៊ើបសួរ។ កាលណាបទ ពេលសំណុំរឿងនៃនីតិវិធី។ បទល្មើសដែលទាក់ទងគ្នាគឺៈ

- កាលណាបទល្មើសបានប្រព្រឹត្តក្នុងពេលជាមួយគ្នាដោយបុគ្គលច្រើនរួមគ្នា
- កាលណាបទល្មើសបានប្រព្រឹត្ត ដោយបុគ្គលផ្សេងគ្នា បន្ទាប់ពីមានការព្រមព្រៀងគ្នា ទោះបីជាការប្រព្រឹត្តនៅក្នុងពេល ឬ ធ្វើនៅទីកន្លែងផ្សេងគ្នាក៏ដោយ ឬ
- ការណោវត្ថុដែលលួច គៃបំបាត់ ឬបានមកពីបទល្មើសណាមួយនោះ ត្រូវបានលាក់បាំងដោយបុគ្គលផ្សេងទៀត។[114]

សភាស៊ើបសួរអាចបង្គាប់ឲ្យចោទប្រកាន់បុគ្គលផ្សេងក្រៅពីបុគ្គល ដែលចែងដោយចៅក្រមស៊ើបសួរ ឬលើកលែងតែបទបញ្ញត្តិនៃមាត្រា១២ អាជ្ញាអស់ជំនុំនៃក្រមនីតិវិធីព្រហ្មទណ្ឌ។[115] ក្រោយពេលដែលដីការបស់ចៅក្រមស៊ើបសួរ ឬសាលដីកា របស់សភាស៊ើបសួរ ដែលលើកលែងចោទប្រកាន់បានចូលជាស្ថាពរហើយមានលេចឡើងនូវបន្ទប់ថ្មី ការស៊ើបសួរអាចត្រូវបានបើកឡើងវិញតាមគំនិតផ្តើមរបស់ព្រះរាជអាជ្ញា។ [116]

### ១.៤. ការពិនិត្យមោឃភាពកិច្ចស៊ើបសួរ

ការពិនិត្យមោឃភាពនៃកិច្ចស៊ើបសួរ គឺជាសមត្ថកិច្ចផ្តាច់មុខរបស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍។ កាលណាសភាស៊ើបសួរបានទទួលពាក្យបណ្តឹងសុំមោឃៈភាពចំពោះកិច្ច ឬលិខិតណាមួយនៃនីតិវិធី ប្រសិនបើសភាស៊ើបសួរយល់ព្រមតាមពាក្យប្តឹងសុំនេះ (មាត្រា២៨០កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ) សភាស៊ើបសួរ

[113] មាត្រា២៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[114] មាត្រា២៦៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[115] មាត្រា២៦៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[116] មាត្រា២៦៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

សាលាឧទ្ធរណ៍នឹងពិនិត្យមើលមូលហេតុនៃមោឃៈភាពតាមពាក្យសុំនោះ ហើយសភាស៊ើបសួរអាចចាត់ទុកជាមោឃៈភាពដោយឯកឯងនូវនីតិវិធីទាំងមូល ឬផ្នែកណាមួយ។[117]

សភាស៊ើបសួរនឹងសម្រេចថា តើមោឃភាពនេះត្រូវធ្វើទៅលើកិច្ច ឬលិខិតផ្សេងទៀតដែរឬទេ បើសភាស៊ើបសួរសម្រេចមោឃៈភាពលើកិច្ច ឬលិខិតណាមួយហើយ លិខិត ឬកិច្ចនោះ ត្រូវដកចេញពីសំណុំរឿង ហើយតម្កល់ទុកនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ។[118]

នៅពេលដែលសភាស៊ើបសួរសម្រេចអំពីមោឃៈភាពរួចហើយ សភាស៊ើបសួសាលាឧទ្ធរណ៍អាចៈ

- បង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញ
- ដកសមត្ថកិច្ចចៅក្រមស៊ើបសួរ ហើយបញ្ជូនសំណុំរឿងនេះទៅចៅក្រមស៊ើបសួរម្នាក់ផ្សេងទៀត ឬ
- បន្តការស៊ើបសួរដោយខ្លួនឯងលើសំណុំរឿងនោះ ។[119]

### ១.៤.១ មោឃភាពកិច្ចនីតិវិធីដោយការមិនគោរពវិធាន

មូលហេតុដែលនាំឲ្យមានការមោឃភាពនីតិវិធី ដោយសារតែចៅក្រមស៊ើបសួរមិនបានបំពេញវិធាននោះឲ្យត្រឹមត្រូវទៅតាមច្បាប់ដែលបានកំណត់ ហើយធ្វើឲ្យមានប៉ះពាល់ ឬខាតបង់ទៅដល់ផលប្រយោជន៍របស់បុគ្គល ឬស្ថាប័នដែលពាក់ព័ន្ធនៅក្នុងសំណុំរឿងនេះ។

វិធាន និងទម្រង់ខាងក្រោមនេះ នៃនីតិវិធីស៊ើបសួរនេះមានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើពុំដូច្នេះទេនឹងនាំឲ្យមានការមោឃភាពនៃនីតិវិធី បទប្បញ្ញត្តិទូទៅនៃនីតិវិធីស៊ើបសួរដែលត្រូវគោរពមានដូចជា៖

- ការបើកការស៊ើបសួរ
- សមត្ថកិច្ចដែនដី
- ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ
- វិសាលភាពនៃបណ្តឹង
- ជំនួយរបស់ក្រឡាបញ្ជី

នឹងនាំឲ្យមានការមោឃភាពផងដែរ កាលណាមានការបំពានវិធាន ឬទម្រង់ការសំខាន់ណាមួយដែលមានចែងក្នុងក្រមនេះ ឬបទប្បញ្ញត្តិទាំងឡាយស្តីពីនីតិវិធីព្រហ្មទណ្ឌដែលធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ភាគីដែលទទួលរងការបំពាននេះ។ វិធាន និងទម្រង់ការដែលមានលក្ខណៈសំខាន់នោះមានជាអាទិ៍ គឺវិធានទម្រង់ការដែលមានបំណងធានាការគោរពសិទ្ធិការពារខ្លួន។[120] តុលាការចាំបាច់ណាស់ គឺត្រូវមានកាតព្វកិច្ចធានាការពារ

[117] មាត្រា២៦១ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧
[118] មាត្រា២៨០ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧
[119] មាត្រា២៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧
[120] មាត្រា២៥២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

ទៅដល់ភាពត្រឹមត្រូវនៃកិច្ចដំណើរការនៃនីតិវិធី ហើយតុលាការដាច់ខាត មិនត្រូវអនុវត្តដោយបំពាននីតិវិធីណាមួយដែលចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនេះនោះទេ។

### ១.៤.២. មោឃភាពកិច្ចនីតិវិធីដោយការប្តឹងទៅសភាស៊ើបសួរ

ការប្តឹងទៅសភាស៊ើបសួរ អាចត្រូវបានធ្វើឡើងដោយៈ

- ចៅក្រមស៊ើបសួរ: ប្រសិនបើចៅក្រមសើបសួរយល់ឃើញថា លិខិតណាមួយនៃនីតិវិធីមានមោឃភាព ចៅក្រមស៊ើបសួរនេះ ប្តឹងទៅសភាស៊ើបសួរ តាមដីកាដោយមានសំអាងហេតុ និងជូនព័ត៌មានដល់ព្រះរាជអាជ្ញា ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។[121]
- ព្រះរាជអាជ្ញា: ប្រសិនបើព្រះរាជអាជ្ញា យល់ឃើញថា លិខិតណាមួយនៃនីតិវិធីមានមោឃភាព ព្រះរាជអាជ្ញាធ្វើពាក្យសុំដោយមានសំអាងហេតុ បញ្ជូនទៅសភាស៊ើបសួរ និងជូនព័ត៌មានដល់ចៅក្រមស៊ើបសួរ ។[122]
- ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី: ប្រសិនបើជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីយល់ឃើញថា លិខិតណាមួយនៃនីតិវិធីមានមោឃភាព សាមីជនធ្វើពាក្យសុំដោយមានសំអាងហេតុជូនទៅសភាស៊ើបសួរ និងជូនព័ត៌មានដល់ចៅក្រមស៊ើបសួរ។ ពាក្យសុំអាចធ្វើដោយមេធាវីរបស់ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី។

## កថាខណ្ឌទី២៖ អំណាចផ្ទាល់ខ្លួនរបស់ប្រធានសភាស៊ើបសួរ

### ២.១. ការធានានូវរដ្ឋបាលយុត្តិធម៌ល្អនៃមន្ទីរស៊ើបសួរ

ប្រធានសភាស៊ើបសួរ ធានារ៉ាប់រងលើការប្រព្រឹត្តទៅដ៏ល្អនៃមន្ទីរស៊ើបសួរនៃចៅក្រមស៊ើបសួរ។ ប្រធានសភាស៊ើបសួរផ្ទៀងផ្ទាត់មើលជាអាទិ៍ លក្ខខណ្ឌនៃការអនុវត្តបទបញ្ញត្តិស្តីពីការឃុំខ្លួនបណ្តោះអាសន្ន ដីកាតុលាផ្សេងៗដីកាចាត់ឲ្យស៊ើបសួរជំនួស និងកោសលវិច័យ។ ប្រធានសភាស៊ើបសួរ រ៉ាប់រងកុំឲ្យនីតិវិធីទាំងឡាយមានការយឺតយ៉ាវដោយមិនសមហេតុសមផល។[123]

### ២.២. អធិការកិច្ចមន្ទីស៊ើបសួរ

ប្រធានសភាស៊ើបសួរអាចចុះទៅធ្វើអធិបញ្ញានៅក្នុងមន្ទីរស៊ើបសួរ។[124] គ្រប់អធិការកិច្ច ឬធ្វើការត្រួតពិនិត្យលទ្ធផលនៃការបំពេញការងារនៃមន្ទីរស៊ើបសួរដោយប្រធានសភាស៊ើបសួរ ត្រូវតែធ្វើរបាយការណ៍ផ្ញើរទៅប្រធានសភាសាលាឧទ្ធរណ៍។[125]

[121] មាត្រា២៥៣ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[122] មាត្រា២៥៣ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[123] មាត្រា២៨៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[124] មាត្រា២៨៣ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[125] មាត្រា២៨៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

### ២.៣. ការធ្វើអធិបញ្ញាឲ្យសម្រេចលើបណ្ដឹងសុំបិទសំណុំរឿង

ពេលផុតចិរវេលា ១ ( មួយ) ឆ្នាំ គិតពីថ្ងៃចោទប្រកាន់ ជនត្រូវចោទអាចសុំឲ្យចៅក្រមស៊ើបសួរបិទការស៊ើបសួរ។ ក្នុងរយៈពេល ១ (មួយ) ខែគិតចាប់ពីថ្ងៃទទួលពាក្យសុំនេះ ចៅក្រមស៊ើបសួរត្រូវតែសម្រេច។ ប្រសិនបើចៅក្រមស៊ើបសួរមិនសម្រេចនៅក្នុងរយៈពេលនេះទេ ជនត្រូវចោទអាចប្ដឹងទៅប្រធានសភាស៊ើបសួរ ដែលធ្វើអធិបញ្ញាដល់ចៅក្រមសួរឲ្យសម្រេច។ លុះផុតចិរវេលា ១ ( មួយ ) ឆ្នាំ គិតពីថ្ងៃតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី អាចសុំឲ្យចៅក្រមស៊ើបសួរ បិទការស៊ើបសួរ។ ក្នុងរយៈពេល ១ ( មួយ) ខែគិតពីការទទួលពាក្យប្ដឹងសុំចៅក្រមស៊ើបសួរត្រូវតែសម្រេច។ ប្រសិនបើចៅក្រមស៊ើបសួរមិនសម្រេចក្នុងរយៈពេលនេះទេ ដើមបណ្ដឹងរដ្ឋប្បវេណីអាចប្ដឹងទៅប្រធានសភាស៊ើបសួរ ដែលធ្វើអធិបញ្ញាឲ្យចៅក្រមស៊ើបសួរសម្រេច។ អំណាចបានទទួលស្គាល់ដោយមាត្រា២៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌនេះដល់ ជនត្រូវចោទ និងដល់ដើមបណ្ដឹងរដ្ឋប្បវេណី អាចត្រូវបានប្រើប្រាស់បានដោយមេធាវី។[126]

## ផ្នែកទី៣៖ ដំណើរការសវនាការបស់សភាស៊ើបសួរ

### កថាខណ្ឌទី១៖នីតិវិធីមុនពេលសវនាការ

### ១.១. ការទទួល និងពិនិត្យសំណុំរឿង

ត្រូវបើកឲ្យមានកាន់បញ្ជីបណ្ដឹងឧទ្ធរណ៍ និងពាក្យសុំមួយនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ។ បន្ទាប់ពីបានទទួលពាក្យប្ដឹង ក្រឡាបញ្ជីនៃសភាស៊ើបសួរត្រូវតែឱ្យដំណឹងភ្លាមទៅចៅក្រមស៊ើបសួរ។ កាលណាសភាស៊ើបសួរត្រូវបានប្ដឹងដោយផ្ទាល់តាមរយៈពាក្យសុំ ក្រឡាបញ្ជីនៃសភាស៊ើបសួរ ផ្ញើមកឱ្យខ្លួននូវសំណុំរឿងនៃនីតិវិធី ឬសំណុំរឿងបង្ការទុក។[127]

### ១.២. ការកំណត់កាលបរិច្ឆេទសវនាការ

ក្រោយពីទទួលបានពាក្យបណ្ដឹងឧទ្ធរណ៍លើដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ ប្រធានសភាស៊ើបសួរពិនិត្យ និងផ្ទៀងផ្ទាត់មើលថា ចំពោះបណ្ដឹងឧទ្ធរណ៍លើដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ច្បាប់ និងគតិច្បាប់ ដែលអាចឲ្យសភាស៊ើបសួរលើកយកសំណុំរឿងនេះមកជំនុំជម្រះបានដែរឬទេ រួចហើយសភាស៊ើបសួរនឹងកំណត់អំពីកាលបរិច្ឆេទសវនាការ។ ប្រធានសភាស៊ើបសួរនឹងជូនដំណឹងដោយផ្ទាល់មាត់ ឬតាមលិខិតរដ្ឋបាល អំពីថ្ងៃកំណត់កាលបរិច្ឆេទសវនាការ ទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ បន្ទាប់មកអគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ត្រូវជូនដំណឹងអំពីសវនាការនេះទៅដល់គូភាគី ព្រមទាំងមេធាវីឲ្យបានជ្រាបអំពីកាលបរិច្ឆេទសវនាការ។ ក្នុងករណីដែលជនត្រូវចោទត្រូវបានកំពុងនឹងឃុំខ្លួននៅក្នុងពន្ធនាគារ ការជូនដំណឹងត្រូវធ្វើឡើងដោយផ្ទាល់មាត់តាមរយៈប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន។ ការជូនដំណឹងទៅដល់មេធាវី ដល់ជនត្រូវចោទ ដល់ដើមបណ្ដឹងរដ្ឋប្បវេណីអាចធ្វើឡើងដោយផ្ទាល់មាត់ តាមផ្លូវរដ្ឋបាល ឬតាមរយៈអង្គភាពនគរបាល ឬកងរាជ

[126] មាត្រា២៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[127] មាត្រា២៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

អាវុធហត្ថ ។ ប្រសិនបើការជូនដំណឹងដោយផ្ទាល់មាត់ ក្រឡាបញ្ជីត្រូវចុះនិទ្ទេសអំពីកាលបរិច្ឆេទអំពីការជូនដំណឹងនៅរឹមទំព័រនៃដីកា។ ចំណែកជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី ឬមេធាវីត្រូវចុះហត្ថលេខារបស់ខ្លួន ឬក៏ការជូនដំណឹងត្រូវធ្វើដោយការប្រគល់សេចក្តីចម្លងដីការដោយមានចំណារទទួល។

### ១.៣. ការពិគ្រោះសំណុំរឿង និងពិនិត្យសារណា

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និង មេធាវី អាចពិនិត្យមើលសំណុំរឿងរហូតដល់ពេលបើកសវនាការ។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និង មេធាវី ត្រូវប្រគល់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរដល់ក្រឡាបញ្ជីយ៉ាងយូរ ១ ( មួយ ) ថ្ងៃ មុនសវនាការ។ គូភាគី និង មេធាវីអាចប្រគល់សារណាដល់ក្រឡាបញ្ជី។ សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និង សារណាត្រូវចុះទិដ្ឋាការដោយក្រឡាបញ្ជី ដែលមានកាលបរិច្ឆេទ និងត្រូវបញ្ចូលនៅក្នុងសំណុំរឿងភ្លាមៗ គូភាគី និងមេធាវីត្រូវបានអនុញ្ញាតឲ្យជូនសារណាដល់ពេលចាប់ផ្តើមសវនាការ។[128]

## កថាខណ្ឌទី២៖ នីតិវិធីពេលសវនាការ

### ២.១. កិច្ចពិភាក្សាដេញដោល

ការពិភាក្សាដេញដោលត្រូវប្រព្រឹត្តទៅក្នុងបន្ទប់ពិភាក្សា។[129] ក្រោយពីរបាយការណ៍របស់ប្រធានសភាស៊ើបសួរ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និង មេធាវី របស់គូភាគី ធ្វើការកត់សម្គាល់របស់ខ្លួនដោយសង្ខេប។[130] សភាស៊ើបសួរអាចបង្គាប់ឲ្យគូភាគី ព្រមទាំងជនត្រូវចោទជាប់ឃុំ ចូលមកបង្ហាញខ្លួនដោយផ្ទាល់ហើយនឹងផ្តល់វត្ថុតាង។[131] កាលណាការពិភាក្សាដេញដោលបានបញ្ចប់ សភាស៊ើបសួរធ្វើការពិគ្រោះសម្រេចដោយគ្មានវត្តមានរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ គូភាគី និង មេធាវីឡើយ។[132]

### ២.២. ការប្រកាសសាលដីកា

សាលដីកាត្រូវបានប្រកាសនៅពេលសវនាការអសាធារណៈនៅថ្ងៃនោះ ឬក៏នៅពេលសវនាការលើកក្រោយ។ សាលដីកាត្រូវតែមានសំអាងហេតុ ហើយត្រូវតែមានធាតុដែលចាំបាច់ដល់ការត្រួតពិនិត្យរបស់តុលាការកំពូល។ សាលដីកាត្រូវចុះហត្ថលេខាដោយប្រធានសភាស៊ើបសួរ។ សាលដីកាត្រូវជូនដំណឹងដោយផ្ទាល់មាត់ក្នុងរយៈពេលខ្លីបំផុត ដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ ក្រឡាបញ្ជីចុះនិទ្ទេសអំពីកាលបរិច្ឆេទនៃការជូនដំណឹងនៅរឹមទំព័រនៃសាលដីកា។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ចុះហត្ថលេខាថាបានទទួល។ សាលដីកាត្រូវជូនដំណឹងដល់គូភាគី និងមេធាវី ដូចដែលមានចែងនៅក្នុងមាត្រា ២៣៨ ( ការជូនដំណឹងអំពីដីកាសម្រេចដល់ជនត្រូវចោទ) នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ សាលដីការបស់សភាស៊ើបសួរត្រូវបានធ្វើឡើងក្រោមរូបភាពជាការតម្កល់ដីកាសម្រេចរបស់

---

[128] មាត្រា២៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[129] មាត្រា២៦០ កថាខណ្ឌទី ១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[130] មាត្រ២៦០ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[131] មាត្រា២៦០ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[132] មាត្រា២៦០ កថាខណ្ឌទី៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

ចៅក្រមស៊ើបសួរ ឬបដិសេធដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ ឬអាចជាសាលដីកាសម្រេចអំពីបណ្តឹងមិនអាចទទួលយកបាន។

**កថាខណ្ឌទី៣៖ នីតិវិធីក្រោយពេលសវនាការ**

សាលដីការបស់សភាស៊ើបសួរត្រូវបានធ្វើឡើងក្រោមរូបភាពជា ការតម្កល់ដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ បដិសេធដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ និងអាចជាសាលដីកាសម្រេចអំពីបណ្តឹងមិនអាចទទួលយកបាន។

**៣.១. សាលដីកាសម្រេចតម្កល់ដីការបស់ចៅក្រមស៊ើបសួរ**

ចំពោះការតម្កល់ដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ ឬ ការតម្កល់សាលដីកាសម្រេចលើការឃុំខ្លួនបណ្តោះអាសន្ននេះ សភាស៊ើបសួរត្រូវសម្រេចចេញ នៅក្នុងរយៈពេល ១៥ថ្ងៃ បន្ទាប់ពីទទួលសំណុំរឿងនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ។ បើផុតរយៈពេលនេះ ជនត្រូវចោទត្រូវបានដោះលែងឱ្យនៅក្រៅឃុំ លើកលែងតែក្នុងករណីដែលមានចេញបង្គាប់ឲ្យធ្វើការផ្ទៀងផ្ទាត់ ឬក្នុងករណីមានកាលៈទេសៈដែលមិនអាចមើលឃើញជាមុន ឬមិនអាចជំនះបាននោះ បង្កជាឧបសគ្គមិនឲ្យប្រកាសសាលដីកាបាននៅក្នុងរយៈពេលនេះ។ កាលណាសភាស៊ើបសួរបង្គាប់ឲ្យឃុំខ្លួនជាបណ្តោះអាសន្ន សភាស៊ើបសួរត្រូវមានសំអាងហេតុនៅក្នុងសាលដីការបស់ខ្លួនដោយយោងទៅតាមបញ្ញត្តិនៃមាត្រា ២០៥ (មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន)។ ប្រធានសភាស៊ើបសួរចេញដីកាបង្គាប់ឲ្យឃុំខ្លួន។ សំណុំរឿង ត្រូវបង្វិលជាបន្ទាន់ទៅចៅក្រមស៊ើបសួរវិញ ក្រោយពីបានអនុវត្តសាលដីការួច។[133]

**៣.២. សាលដីកាសម្រេចបដិសេធដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ**

ចំពោះការបដិសេធដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ សភាស៊ើបសួរទទួលបានបណ្តឹងពីព្រះរាជអាជ្ញា ឬជនត្រូវចោទដែលជាពាក្យប្តឹងសុំឲ្យសភាស៊ើបសួរសម្រេចជំនួសចៅក្រមស៊ើបសួរ សភាស៊ើបសួរអាចសម្រេចមិនឃុំខ្លួនបណ្តោះអាសន្នដាក់ជនត្រូវចោទ ឬ សម្រេចដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំ។ បើទោះបីជាសភាស៊ើបសួរសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន ឬ សម្រេចដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំក៏ដោយសភាស៊ើបសួរអាចប្រើប្រាស់នូវនីតិវិធីមួយផ្សេងទៀតដោយដាក់ជននេះឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដោយត្រូវឲ្យជនត្រូវចោទគោរពនូវកាតព្វកិច្ចមួយ ឬច្រើន។ សភាស៊ើបសួរអាចសម្រេចដាក់ជនត្រូវចោទឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលាប្រសិនបើជនត្រូវចោទនោះត្រូវបានចោទប្រកាន់អំពីបទល្មើស ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ។[134] ការត្រួតពិនិត្យតាមផ្លូវតុលាការ មានអានុភាពបង្គាប់ជនត្រូវចោទដែលនៅក្រៅឃុំឲ្យគោរពកាតព្វកិច្ចមួយ ឬច្រើនដូចខាងក្រោមៈ

១-មិនត្រូវចេញក្រៅព្រំប្រទល់ដែនដីកំណត់ដោយចៅក្រមស៊ើបសួរ។

២-មិនត្រូវផ្លាស់ប្តូរលំនៅឋានដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។

---

[133] មាត្រា២៧៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[134] មាត្រា២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

៣-មិនត្រូវទៅកាន់ទីកន្លែងខ្លះដែលកំណត់ដោយចៅក្រមស៊ើបសួរ។

៤-ត្រូវចូលបង្ហាញខ្លួនតាមការកំណត់នៅអង្គភាពនគរបាល ឬកងរាជអាវុធហត្ថដែលចាត់តាំងដោយចៅក្រមស៊ើបសួរ។

៥-ត្រូវឆ្លើយតបនឹងការកោះហៅពីគ្រប់បុគ្គលដែលចាត់តាំងដោយចៅក្រមស៊ើបសួរ។

៦-ប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជីគ្រប់ឯកសារបញ្ជាក់អំពីអត្តសញ្ញាណ។

៧-មិនត្រូវបើកបររថយន្ត។

៨-មិនត្រូវទទួល ឬជួបបុគ្គលមួយចំនួនដែលចង្អុលបង្ហាញដោយចៅក្រមស៊ើបសួរ។

៩-ដាក់ប្រាក់ធានា ដែលចំនួនប្រាក់ធានា និងថិរវេលាបង់ប្រាក់នេះ ត្រូវបានកំណត់ដោយចៅក្រមស៊ើសួរដោយផ្អែកទៅលើធនធានរបស់ជនត្រូវចោទ។

១០-មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ។ ត្រូវប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជីនូវអាវុធដែជនត្រូវចោទកាន់កាប់។

១១-ត្រូវប្រគល់ខ្លួនឱ្យពេទ្យពិនិត្យព្យាបាល និងជាយថាហេតុ ដាក់ឱ្យស្ថិតនៅក្រោមរបបព្យាបាលរោគក្នុងមន្ទីរពេទ្យ។

១២-មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈខ្លះ។

### ៣.៣. សាលដីកាសម្រេចអំពីភាពមិនអាចទទួលបាននៃពាក្យសុំមោឃភាព

សភារស៊ើបសួរអាចប្រកាសមិនទទួលពាក្យបណ្ដឹងសុំឱ្យមោឃកម្មនៅក្នុងករណីដូចតទៅៈ

- ពាក្យប្ដឹងសុំគ្មានសំអាងហេតុ
- ពាក្យប្ដឹងសុំទាក់ទងនឹងដីកាដែលអាចប្ដឹងឧទ្ធរណ៍បាន
- ពាក្យប្ដឹងសុំគ្មានមូលកភាពយ៉ាងជាក់ស្ដែង

សេចក្ដីសម្រេចរបស់សភាស៊ើបសួរមិនអាចតវ៉ាបានទេ

កាលណាពាក្យប្ដឹងសុំត្រូវបានប្រកាសមិនអាចទទួលបានទេ សំណុំរឿងត្រូវបង្វិលភ្លាមទៅចៅក្រមស៊ើបសួរ។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ការសិក្សាស្រាវជ្រាវស្តីពី " **បណ្តឹងឧទ្ធរណ៍នឹងសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរនៅសភាស៊ើបសួរសាលាឧទ្ធរណ៍** " បានបង្ហាញឲ្យឃើញថា បើទោះបីស្ថាប័នស៊ើបសួរ ជាស្ថាប័នមួយមានដែលសមត្ថកិច្ចជាន់គ្នាជាមួយ និងនិតិវិធីនៃការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលមានការដឹកនាំដោយព្រះរាជអាជ្ញាយ៉ាងណាក្តី ក៏ស្ថាប័នស៊ើបសួរត្រូវចាំបាច់រក្សាទុក ដោយហេតុថាដំណាក់កាលនៃនីតិវិធីស៊ើបសួរជាដំណាក់កាលមួយដែលមានលក្ខណៈស្មុគស្មាញ និងជាដំណាក់កាលនៃការស្វែងរកការពិត ស្វែងរកភស្តុតាងដើម្បីដាក់បន្ទុក ដោះបន្ទុក ក៏ដូចជាធានាអោយបាននូវការអនុវត្តច្បាប់ដោយមានប្រសិទ្ធិភាព មិនលំអៀង និងយុត្តិធម៌ជូនដល់គីភាគី។ ការបើកការស៊ើបសួររបស់ចៅក្រមស៊ើបអាចធ្វើទៅបានលុះត្រាតែទទួលបានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរពីព្រះរាជអាជ្ញា ដែលជាដំណាក់កាលដំបូងនៃការចាប់ផ្តើមបើកការស៊ើបសួរ។ យ៉ាងណាមិញក្រមនីតិវិធីព្រហ្មទណ្ឌបានប្រគល់នូវសិទ្ធិអំណាចជាច្រើនដល់ចៅក្រមស៊ើបសួរ ដែលនាំឲ្យការស្រាវជ្រាវប្រព្រឹត្តិទៅបានដោយរលូន ល្អិតល្អន់ ឈានទៅដល់ការរកឃើញជនល្មើសពិតប្រាកដ។ ម្យ៉ាងវិញទៀតក្រោយពីចៅក្រមស៊ើបសួរបានបញ្ចប់នូវវិធានការស្រាវជ្រាវរបស់ខ្លួន ចៅក្រមស៊ើបសួរត្រូវបិទការស៊ើបសួរដោយចេញសេចក្តីសម្រេចដែលសេចក្តីសម្រេចនេះស្តែងចេញតាមរយៈដីកា គឺដីកាដំណោះស្រាយ ដីកានេះអាចជាដីកាលើកលែងចោទប្រកាន់ ឬ ដីកាបញ្ជូនទៅជំនុំជម្រះ ។

ពិសេសជាងនេះទៅទៀតដំណាក់កាលស៊ើបសួរ គូភាគីអាចធ្វើប្តឹងទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍កាលណាមិនសុខចិត្ត ឬ យល់ឃើញថាដំណាក់កាលណាមួយនៃការស៊ើបសួរមានភាពមិនប្រក្រតី ឬកិច្ចដែលចៅក្រមស៊ើបសួរ ធ្វើការស៊ើបសួរមានលក្ខណៈមិនគោរពវិធានបញ្ញត្តិ ដែលធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធរដល់ផលប្រយោជន៍ខ្លួន។ គោលបំណងនៃការបើកឲ្យមានការប្តឹងតវ៉ានេះ គឺការពារនៃការផ្តល់យុត្តិធម៌ឲ្យបានជាអតិបរិមាចៀសវាសការភាន់ច្រឡំ និងបង្កើនការការពារនូវសិទ្ធិសេរីភាពបុគ្គលពាក់ព័ន្ធឲ្យបានកាន់តែខ្លាំង និងសុក្រឹត។ ដំណាក់កាលស៊ើបសួរការប្តឹងតវ៉ាអាចបែងចែកជាពីរ ការប្តឹងតវ៉ាទីមួយ ភាគីអាចប្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរដែលស្តែងចេញតាមរយៈដីកា និងការប្តឹងតវ៉ាទីពីរ ជាការប្តឹងតវ៉ាចំពោះកិច្ចនីតិវិធីសំដៅដល់ការប្រព្រឹត្តិខុសកិច្ចនីតិវីធី ( ការប្តឹងនិយ័តភាពនៃកិច្ចនីតិវិធី ) ត្រង់ចំណុចនេះមិនត្រឹមតែភាគីទេដែលអាចមានសិទ្ធិប្តឹងសុំឲ្យសភាស៊ើបសួរធ្វើការពិនិត្យនិយ័តភាព ចៅក្រមស៊ើបសួរផ្ទាល់ក៏មានសិទ្ធិក្នុងការប្តឹងទៅសភាស៊ើបសួរដូចគ្នា។ កាលណាចៅក្រមស៊ើបសួរខ្លួនឯងបានពិនិត្យឃើញមាននីតិវិធីត្រង់ចំណុចណាប្រព្រឹត្តិទៅផ្ទុយនឹងវិធានច្បាប់ ហើយបើច្បាប់បានចង្អុលបង្ហាញថាប្រព្រឹត្តិខុសនឹងនាំឲ្យមានមោឃភាព នោះចៅក្រមស៊ើបសួរមានសិទ្ធិប្តឹងទៅសភាស៊ើបសួរ។

ចំណែកឯសភាស៊ើបសួរវិញមានអំណាចត្រួតពិនិត្យកិច្ចស៊ើបសួរ ដែលមានលក្ខណៈជាសេចក្តីសម្រេចហើយជាគោលការណ៍ ដើម្បីអនុវត្តនូវសិទ្ធិអំណាចនេះសភាស៊ើបសួរ ត្រូវទទួលបានពាក្យបណ្តឹងពីភាគីមិនអាចយក

សំណុំរឿងមកពិនិត្យដោយឯកឯងបានទេ។ ម្យ៉ាងវិញទៀត សភាស៊ើបសួរក៏មានអំណាចពិនិត្យអំពីនិយ័តភាពនៃកិច្ចស៊ើបសួរផងដែរ ប៉ុន្តែដើម្បីធ្វើការពិនិត្យបាន គឺត្រូវមានអ្នកដាក់ពាក្យប្ដឹងសុំមោឃភាព ដែលអាចធ្វើឡើងដោយចៅក្រមស៊ើបសួរ ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្ដឹងរដ្ឋប្បវេណី។ ក្រោយពីទទួលបាន បណ្ដឹងពីភាគី សភាស៊ើបសួរយកសំណុំរឿងនីតិវិធីមកពិនិត្យ ក្នុងករណីពិនិត្យទៅសភាស៊ើបសួរមើលឃើញថា មានចំណុចត្រង់ណាមានកំហុស ឬកិច្ចដែលចៅក្រមស៊ើបសួរប្រព្រឹត្តទៅមិនត្រឹមត្រូវ តាមនីតិវិធីដែលច្បាប់កំណត់ សភាស៊ើបសួរមានសិទ្ធិចេញសាលដីកាសម្រេចធ្វើមោឃកម្មកិច្ចនីតិវិធីមួយ ឬទាំងមូល។ សភាស៊ើបសួរក៏អាចដកសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរហើយបន្តការស៊ើបសួរដោយឯងផ្ទាល់ ឬដកសមត្ថកិច្ចចៅក្រមស៊ើបសួរប្រគល់ឲ្យទៅចៅក្រមស៊ើបសួរមួយផ្សេងទៀត នេះជាមូលហេតុដែលធ្វើឲ្យសភាស៊ើបសួរក្លាយជាយុត្តាធិការស៊ើបសួរពិតប្រាកដ។ លើសពីនេះនៅក្នុងសំណុំរឿងនីតិវិធីបើមានអង្គហេតុដទៃផ្សេងទៀត ដែលមានពាក់ព័ន្ធនឹងបទល្មើសដើម ហើយចៅក្រមស៊ើបសួរមិនបានធ្វើការចោទប្រកាន់ សភាស៊ើបសួរអាចពន្លាតការចោទប្រកាន់ទៅរកបទល្មើសដទៃផ្សេងទៀត។

ការបង្កើតសភាស៊ើបសួរក្នុងគោលបំណងពិនិត្យនិយ័តភាព នៃនីតិវិធីស៊ើបសួររបស់មន្ទីរស៊ើបសួរ ដើម្បីធានាការប្រព្រឹត្តិទៅរបស់មន្ទីរស៊ើបសួរប្រកបដោយត្រឹមត្រូវគោរពវិធានច្បាប់ ធានាការអនុវត្តរបស់ចៅក្រមស៊ើបសួរឲ្យកាន់តែមានប្រសិទ្ធិភាព យុត្តិធម៌ និងសុក្រឹត ដោយហេតុថាដំណាក់កាលស៊ើបសួរជាដំណាក់កាលដែលសំខាន់នៅក្នុងការស្វែងរកការពិត ហើយការស្វែងការការពិតនេះរមែកមានការប៉ះពាល់ដល់សិទ្ធិបុគ្គល ដូច្នេះហើយ ទើបក្រមនីតិវិធីព្រហ្មទណ្ឌបញ្ញត្តិអំពីគោលការណ៍ ដើម្បីធានាដល់ការអនុវត្តដោយមានសុពលភាពជូនជនរួមជាតិ។

សរុមមក បណ្ដឹងឧទ្ធរណ៍នឹងដីកាសម្រេចរបស់ចៅក្រមស៊ើបសួរទៅសភាស៊ើបសួរសាលាឧទ្ធរណ៍ ពិតជាមានសារៈសំខាន់ណាស់ចំពោះគូភាគីក្នុងរឿងក្ដីព្រហ្មទណ្ឌ។ ក្រមនីតិវិធីព្រហ្មទណ្ឌ បានកំណត់នូវសិទ្ធិអំណាចរបស់ចៅក្រមស៊ើបសួរដែលមាន តួនាទីចម្បងក្នុងការស្វែងរកការពិត និងកំណត់បទល្មើស។ ចំពោះសិទ្ធិអំណាចរបស់ចៅក្រមស៊ើបសួរត្រូវអនុវត្តប្រកបដោយប្រសិទ្ធិភាព តម្លាភាព យុត្តិធម៌ មិនលំអៀង និងគោរពវិធានបញ្ញត្តិ ព្រមទាំងគោរពនូវសិទ្ធិសេរីភាពបុគ្គល។ ដើម្បីឲ្យការប្រព្រឹត្តិទៅរបស់មន្ទីរស៊ើបសួរកាន់ល្អ និងសុក្រឹត ក្រមនីតិវិធីព្រហ្មទណ្ឌបានផ្ដល់សិទ្ធិ ដល់ភាគីក្នុងការធ្វើបណ្ដឹងឧទ្ធរណ៍ទៅសភាស៊ើបសួរផងដែរ។ ការបង្កើតឲ្យមានសភាស៊ើបសួរសាលាឧទ្ធរណ៍ និងការបើកសិទ្ធិឲ្យធ្វើបណ្ដឹងតវ៉ា បានសបញ្ជាក់យ៉ាងច្បាស់ថា ក្រមនីតិវិធីព្រហ្មទណ្ឌបានធានាដល់ការអនុវត្តច្បាប់ឲ្យកាន់តែមានប្រសិទ្ធិភាព ព្រមទាំងគោរពនូវសិទ្ធិសេរីភាពបុគ្គលស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានឆ្លងកាត់ការស្រាវជ្រាវ និងបានបកស្រាវនូវចំណុចជាច្រើនពាក់ព័ន្ធអំពីនីតិវិធីនៃបណ្តឹងឧទ្ធរណ៍នឹងដីកាសម្រេចរបស់ចៅក្រមស៊ើបសួរទៅសភាស៊ើបសួរសាលាឧទ្ធរណ៍ក្នុងរឿងក្តីព្រហ្មទណ្ឌ យើងសង្កេតឃើញថា នីតិវិធីនៃការធ្វើបណ្តឹងឧទ្ធរណ៍នឹងដីកាសម្រេចរបស់ចៅក្រមស៊ើបសួរទៅសភាស៊ើបសួរសាលាឧទ្ធរណ៍ បានផ្តល់នូវភាពយុត្តិធម៌ជាអតិបរិមាជូនដល់ភាគីគួរឲ្យកត់សម្គាល់។ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងបញ្ជាក់យ៉ាងច្បាស់លាស់ និង ល្អិតល្អន់ ចំពោះការបើកសិទ្ធិឲ្យប្តឹងទៅលើដីកាសម្រេចរបស់ចៅក្រមស៊ើបសួរទៅសភាស៊ើបសួរសាលាឧទ្ធរណ៍ ទាំងនេះបានសបញ្ជាក់ឲ្យឃើញថាប្រព័ន្ធយុត្តិធម៌នៅក្នុងព្រះរាជាណាចក្រកម្ពុជា បានការពារនូវរាល់សិទ្ធិ និងផលប្រយោជន៍ទាំងឡាយមិនថាសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ដើមបណ្តឹង របស់ជនត្រូវចោទ ឬរបស់បុគ្គលដែលពាក់ព័ន្ធនៅក្នុងសំណុំរឿង។ យ៉ាងណាមិញនៅក្នុងដំណាក់កាលស៊ើបសួរ រាល់ដីកាសម្រេចដែលចេញដោយចៅក្រមស៊ើបសួរ ដីកាខ្លះធ្វើឲ្យប៉ះពាល់ទៅដល់សិទ្ធិ និងផលប្រយោជន៍របស់ជនត្រូវចោទ ដើមបណ្តឹង និងភាគីពាក់ព័ន្ធ ដែលតម្រូវឲ្យចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានី-ខេត្តត្រូវតែអនុវត្តទៅតាមបទបញ្ញត្តិនៃច្បាប់ដែលបានចែងជាធរមាន ការស៊ើបសួរត្រូវប្រព្រឹត្តទៅដោយស្មើរភាព សុក្រឹត និងយុត្តិធម៌ ធ្វើការសម្រេចណាមួយត្រូវតែសំអាងទៅលើអង្គហេតុ និងអង្គច្បាប់ដែលមាននៅក្នុងបទបញ្ញត្តិច្បាប់ជាធរមាន។ នៅក្នុងដំណាក់កាលស៊ើបសួរ ចៅក្រមស៊ើបសួរមិនត្រូវសម្រេចដោយមើលឃើញផលប្រយោជន៍របស់ភាគីណាម្ខាងនោះទេ ដែលវាធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំង ព្រមទាំងបាត់បង់នូវភាពត្រឹមត្រូវ យុត្តិធម៌ មនសិការ និងស្មារតីនៃច្បាប់។

ប៉ុន្តែទន្ទឹមនឹងនេះក៏បានលេញឡើងនូវបញ្ហាមួយចំនួនធ្វើឲ្យមានការកកស្ទះនៃសំណុំរឿង គឺការបង្កើតប្រព្រឹត្តខុសកិច្ចនីតិវិធីនៅក្នុងដំណាក់កាលស៊ើបសួរ ជាហេតុនាំឲ្យមានការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សិទ្ធិរបស់ភាគី និងធ្វើអោយមានការយឺតយ៉ាវក្នុងការផ្តល់យុត្តិធម៌ជូនជនរងគ្រោះ។ សំណុំរឿងព្រហ្មទណ្ឌអាចឈាន ដល់ការរឹតត្បិតនូវសិទ្ធិសេរីភាពរបស់ជនត្រូវចោទមួយចំនួន ក្នុងរយៈពេលណាមួយដែលបានចែងកំណត់នៅក្នុងច្បាប់ គឺនេះហើយជាការប៉ះពាល់ដល់សិទ្ធិជាសារវន្តរបស់ជនត្រូវចោទនោះ មិនត្រឹមតែអាចមានការប៉ះពាល់ទៅសិទ្ធិរបស់ជនត្រូវចោទនោះទេ ពេលខ្លះទៀតក៏អាចធ្វើឲ្យប៉ះពាល់ទៅដល់សិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ដើមបណ្តឹងទៀតផង ដែលកើតចេញពីការប្រព្រឹត្រខុសកិច្ចនីតិវិធីរបស់ចៅក្រមស៊ើបសួរ ប្រព្រឹត្តទៅមិនគោរពវិធានច្បាប់ ស្មារតី និងមនសិការនៃច្បាប់។ កាលណាចៅក្រមស៊ើបសួរប្រព្រឹត្តខុសកិច្ចនីតិវិធី នោះភាគី មានសិទ្ធិប្តឹងតវ៉ាទៅស្ថាប័នមានសមត្ថកិច្ចជាន់ខ្ពស់ គឺសភាស៊ើបសួរសាលាឧទ្ធរណ៍ដើម្បីឲ្យសភាស៊ើបសួរពិនិត្យនិយ័តភាពនៃកិច្ចនីតិវិធីរបស់ចៅក្រមស៊ើបសួរ។ បន្ទាប់ពីទទួលបានពាក្យប្តឹងតវ៉ាចំពោះកិច្ចនីតិវិធី ច្បាស់ណាស់សភាស៊ើបសួរនឹងពិនិត្យអំពីនិយ័តភាពនៃកិច្ចនីតិវិធីរបស់ចៅក្រមស៊ើបសួរ។ កាលណាសភាស៊ើបសួរពិនិត្យឃើញថាកិច្ចនីតិវិធីរបស់ចៅក្រមស៊ើបសួរមានភាពត្រឹមត្រូវទៅតាមទិដ្ឋភាពផ្លូវច្បាប់ដោយផ្អែកទៅអង្គហេតុ អង្គច្បាប់ និងភស្តុតាង សភាស៊ើបសួរនឹងសម្រេចតម្កល់សេចក្តីរបស់ចៅក្រមស៊ើបសួរ ប៉ុន្តែបើពិនិត្យឃើញមានមោឃភាព ឬមានការប្រព្រឹត្តខុសកិច្ចនីតិវិធី និងមិនគួរយកមកធ្វើជាមូលដ្ឋានក្នុងការផ្តន្ទាទោសនោះទេ សភាស៊ើបសួរនឹងសម្រេចមោឃកម្មកិច្ចនោះ ហើយការសម្រេចមោឃភាពកិច្ចនេះមិនមែនមោឃភាពត្រឹមតែកិច្ចដែលគេប្តឹងមកនោះទេ គឺនឹងមោឃភាពរាល់កិច្ចដែលពាក់ព័ន្ធនឹងសំណុំរឿង កត្តានេះហើយដែលធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់ភាគី។ ការសម្រេចធ្វើមោឃភាពនេះគឺដើម្បីធ្វើយ៉ាងណាអោយភាគីទទួលបាននូវយុត្តិធម៌ពិតប្រាកដ ជាការពិតណាស់កាលណាសភាស៊ើបសួរសម្រេចមោឃ

ភាពនូវកិច្ចនីតិវិធីនេះនឹងរឹតតែធ្វើឲ្យដំណើរការនៃសំណុំរឿងកាន់តែយឺតយ៉ាវមួយកម្រិតទៀត ព្រោះថាសំណុំរឿងមួយដែលមានភាពយូរ គឺស្មើនឹងអយុត្តិធម៌បាត់ទៅហើយ។

ដូច្នេះ យើងមើលឃើញថា ទ្រឹស្តីច្បាប់ គឺភាពត្រឹមត្រូវ សុក្រឹត្យ និងយុត្តិធម៌ចំពោះភាគីណាមួយនៅក្នុងសំណុំរឿងមិនថាទាំងភាគីជនត្រូវចោទ ព្រមទាំងភាគីដើមបណ្តឹង មិនមានចន្លោះណាមួយនៃច្បាប់មានភាពមន្ទិលសង្ស័យ ឬភាពមិនច្បាស់លាស់កន្លែងណាមួយនោះទេ ហើយការអនុវត្តជាក់ស្តែងវិញចូរជៀសវាងកុំឲ្យមានការអនុវត្តផ្ទុយពីច្បាប់ ព្រោះថាបើរឿងនេះមានការកើតឡើងមែន នោះនឹងបង្កឲ្យមានការបាត់បង់ទំនុកចិត្តពី ប្រជាពលរដ្ឋក៏ដូចជាអាចបណ្តាលឲ្យសង្គមមួយឈានទៅរកភាពអសន្តិសុខ និងបាត់បងនីតិរដ្ឋ។

ហេតុដូចនេះ យើងខ្ញុំសូមសំណូមពរទៅដល់ស្ថាប័នតុលាការ ជាពិសេស សភាស៊ើបសួរ និង ចៅក្រមស៊ើបសួរត្រូវតែបំពេញកិច្ចរបស់ទៅតាមបទបញ្ញត្តិច្បាប់ឲ្យបានម៉ឺងម៉ាត់ជាទីបំផុត មិនត្រូវអនុវត្តឲ្យខុសពីស្មារតីនៃច្បាប់ព្យាយាមកាត់បន្ថយកំហុសចេតនាក្តី ឬ អចេតនាក្តី ដើម្បីផ្តល់ភាពយិត្តធ៌មដល់ភាគីអោយបានឆាប់រហ័ស និងសុក្រឹតជាអតិបរិមា។

# ឯកសារយោង

# ឯកសារយោង

- **ច្បាប់ជាតិ**
  - ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា
  - ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤
  - រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ នៃព្រះរាជាណាចក្រកម្ពុជា
- **ច្បាប់អន្តរជាតិ**
  - សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស អនុម័ត និង ប្រកាសឲដោយសេចក្តីសម្រេចចិត្តនៃ លេខ ២១៧ **A ( III )** មហាសន្និបាតថ្ងៃ ១០ធ្នូ ឆ្នាំ ១៩៤៨
- **សៀវភៅមេរៀន និងឯកសារផ្សេងៗ**
  - នីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយ លោកស្រី **ឌី លីឡា** និងលោក **ខាន់ សុខា**
  - សេចក្តីពន្យល់នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា អ វ ត ក និងអន្តរជាតិសម្រាំង  បោះពុម្ពផ្សាយលើក ទី១នៅខែមិថុនា ឆ្នាំ ២០១៤

# ឧបសម្ព័ន្ធ

# បញ្ជីរាយនាមឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១ គម្រូកំណត់ហេតុទទួលវត្ថុចាប់យក
ឧបសម្ព័ន្ធទី២ គម្រូដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ
ឧបសម្ព័ន្ធទី៣ គម្រូកំណត់ហេតុស្តីពីការសួរចម្លើយជនត្រូវចោទ
ឧបសម្ព័ន្ធទី៤ គម្រូកំណត់ហេតុស្តីពីការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
ឧបសម្ព័ន្ធទី៥ គ្រមូកំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សី
ឧបសម្ព័ន្ធទី៦ គម្រូដីកាចាត់តាំងអ្នកជំនាញ
ឧបសម្ព័ន្ធទី៧ គម្រូដីកាចាត់ឲ្យស៊ើបសួរជំនួស
ឧបសម្ព័ន្ធទី៨ គម្រូដីកាបង្គាប់ឲ្យចូលខ្លួន
ឧបសម្ព័ន្ធទី៩ គម្រូដីកាបង្គាប់ឲ្យនាំខ្លួន
ឧបសម្ព័ន្ធទី១០ គម្រូដីកាបង្គាប់ឲ្យចាប់ខ្លួន
ឧបសម្ព័ន្ធទី១១ គម្រូដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្ន
ឧបសម្ព័ន្ធទី១២ គម្រូដីកាបង្គាប់ឲ្យឃុំខ្លួន
ឧបសម្ព័ន្ធទី១៣ គម្រូដីកាសម្រេចដោះលែងឲ្យនៅក្រៅឃុំ
ឧបសម្ព័ន្ធទី១៤ គម្រូដីកាបង្គាប់ឲ្យដោះលែង
ឧបសម្ព័ន្ធទី១៥ គម្រូដីកាសម្រេចដាក់ជនត្រូវចោទឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ
ឧបសម្ព័ន្ធទី១៦ គម្រូលិខិតជូនព័ត៌មានស្តីពីការបញ្ចប់ការស៊ើបសួរ
ឧបសម្ព័ន្ធទី១៧ គម្រូដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា
ឧបសម្ព័ន្ធទី១៨ គម្រូដីកាដោះស្រាយ
ឧបសម្ព័ន្ធទី១៩ ដីកាលើកលែងចោទប្រកាន់
ឧបសម្ព័ន្ធទី២០ ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ
ឧបសម្ព័ន្ធទី២១ ដីកាសម្រេចប្រគល់វត្ថុចាប់យកឲ្យទៅម្ចាស់ដើម
ឧបសម្ព័ន្ធទី២២ ដីកាចាត់ឲ្យបំពេញកិច្ចស៊ើបសួរបន្ថែម
ឧបសម្ព័ន្ធទី២៣ ដីកាសម្រេចបដិសេធការស្នើសុំឲ្យបំពេញកិច្ច

ឧបសម្ព័ន្ធទី១

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូង និង អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌលេខ [redacted]
ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០២២
លេខ: [redacted]

**កំណត់ហេតុទទួលវត្ថុចាប់យក(១)**

ឆ្នាំពីរពាន់ម្ភៃពីរ ខែមករា ថ្ងៃទីសាមសិប វេលាម៉ោង បី និងហាសិប នាទីដប់ នៅលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងរាជធានីភ្នំពេញ។

យើង [redacted] ជាក្រឡាបញ្ជីទទួលបន្ទុកឃ្លាំងវត្ថុចាប់យក ជាអ្នកទទួល ។

លោក [redacted] ជាមន្ត្រីកងរាជអាវុធហត្ថ នៃការិយាល័យព្រហ្មទណ្ឌ កងរាជអាវុធហត្ថរាជធានីភ្នំពេញ ជា អ្នកប្រគល់ ។

ដោយមានការចូលរួមពីជនស[redacted] ភេទប្រុស ឆ្នាំកំណើត១៩៨៤ ជនជាតិខ្មែរ និងឈ្មោះ[redacted] ភេទ ប្រុស ឆ្នាំកំណើត១៩៨០ ជនជាតិខ្មែរ ពាក់ព័ន្ធនឹងករណី រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១។

យើងបានពិនិត្យផ្ទៀងផ្ទាត់វត្ថុចាប់យករបាយការណ៍សរុប លេខ [redacted] ចុះថ្ងៃទី[redacted] ខែ[redacted] ឆ្នាំ ២០២២, កំណត់ហេតុចាប់យកវត្ថុតាង ដកហ[redacted]រ សុខគេង ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២, កំណត់ហេតុចាប់យកវត្ថុតាង ដកហូតពីឈ្មោះ: [redacted] ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២ របស់ការិយាល័យព្រហ្មទណ្ឌ កងរាជអាវុធហត្ថរាជធានីភ្នំពេញ ដែលទាក់ទងនឹងសំណុំរឿងព្រហ្មទណ្ឌលេខ [redacted] ចុះថ្ងៃទី[redacted] ខែ[redacted] ឆ្នាំ[redacted] ឃើញដូចខាងក្រោម ៖

| | | | | |
|---|---|---|---|---|
| ☐ អចលនវត្ថុ | ☐ ប្រាក់ | ☐ គ្រឿងញៀន | ☐ អាវុធ/គ្រឿងផ្ទុះ | |
| ☐ រថយន្ត | ☐ ម៉ូតូ | ☐ កុំព្យូទ័រ/ទូរទស្សន៍ | ☐ ទូរស័ព្ទ | ☐ ផ្សេងៗ |

**វត្ថុតាងដកហូតពីជនសង្ស័យឈ្មោះ[redacted]មាន៖**

១-រថយន្តម៉ាក LEXUS RX300 ពណ៌ស្ករ ពាក់ផ្លាកលេខ ភ្នំពេញ 2P-5077 ចំនួន ០១ គ្រឿង (មិនប្រក្រតី)។
២-កាបូបដៃពណ៌ខ្មៅ ចំនួន ០១។
៣-ប្រាក់ដុល្លារ ចំនួន ១០០ (មួយរយ) ដុល្លារអាមេរិក។
៤-ទូរស័ព្ទដៃម៉ាក VIVO ពណ៌ទឹកសមុទ្រ (បែកអេក្រង់) ចំនួន ០១ គ្រឿង (មិនដំណើរការ)។
៥-បណ្ណចាក់វ៉ាក់សាំងកូវីដ-១៩ ចំនួន ០១។
៦-បណ្ណសម្គាល់យានយន្ត (ម៉ូតូ) ផ្លាកលេខ សៀមរាប 1R-9177 ចំនួន ០១។
៧-បណ្ណសម្គាល់យានយន្ត (រថយន្ត) ផ្លាកលេខ បាត់ដំបង 2A-2315 ចំនួន ០១។
៨-បណ្ណសម្គាល់យានយន្ត (រថយន្ត) ផ្លាកលេខ ឆ-៩៨១១ ភព២ ចំនួន ០១។
៩-កាតធនាគារ (VISA) J-Trust Royal ចំនួន ០១។
១០-កាតធនាគារ (VISA) ABA ចំនួន ០១។
១១-អត្តសញ្ញាណបណ្ណសញ្ញាតិខ្មែរ លេខ[redacted] របស់ឈ្មោះ:[redacted]បី ចំនួន ០១ (មិនប្រក្រតី)។
១២-កាតផ្សេងៗ មួយចំនួនទៀត។

បញ្ជាក់៖ វត្ថុតាងពីលេខរៀង ទី២ ដល់ទី១២ ដាក់ក្នុងស្រោមសំបុត្រពណ៌សបិទផិតចំនួន ០១ ដែលមានស្នាមមេដៃរបស់ជនសង្ស័យឈ្មោះ[redacted]បី ហត្ថលេខាមន្ត្រីនគរបាលយុត្តិធម៌ និងក្រឡាបញ្ជី។

**វត្ថុតាងដកហូតពីជនសង្ស័យឈ្មោះ[redacted] រួមមាន៖**

១-ទូរស័ព្ទម៉ាក REALME ពណ៌ខៀវ (បែកអេក្រង់) ចំនួន ០១ គ្រឿង (មិនដំណើរការ)
២-ទូរស័ព្ទម៉ាក NOKIA ពណ៌ខ្មៅ ចំនួន ០១ គ្រឿង (មិនដំណើរការ)
៣-អត្តសញ្ញាណបណ្ណសញ្ញាតិខ្មែរ លេខ ០២០[illegible] ឈ្មោះ:[redacted] ចំនួន ០២។
៤-បណ្ណសម្គាល់យានយន្ត (ម៉ូតូ) ផ្លាកលេខ [illegible] ០១។

## ឧបសម្ព័ន្ធទី២

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**

**សាលាដំបូងរាជធានីភ្នំពេញ**

សំណុំរឿងព្រហ្មទណ្ឌលេខ

ចុះថ្ងៃទី ខែ ឆ្នាំ

លេខ៖ ................ អ.យ.គ

**<u>ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ</u>**

**យើង ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ**

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ៖ ចុះថ្ងៃទី ខែ ឆ្នាំ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ ពាក្យបណ្តឹង ចុះថ្ងៃទី ខែ ឆ្នាំ របស់ឈ្មោះ ភេទប្រុស អាយុ ឆ្នាំ បានប្តឹងឈ្មោះ ភេទប្រុស អាយុ ឆ្នាំ និងឈ្មោះ ភេទស្រី អាយុ ឆ្នាំ ពីបទ រំលោភលើទំនុកចិត្ត និងឆបោកប្រាក់។

**ក្រោយពីបានពិនិត្យឯកសារខាងលើ**

យល់ឃើញថា មានតម្រុយសន្និដ្ឋានថា

១-នាម-គោត្តនាម ភេទប្រុស អាយុ ឆ្នាំ មានអាស័យដ្ឋាននៅ ឃុំ ស្រុក ខេត្ត ។ (ក្រៅឃុំ)

២-នាម-គោត្តនាម ភេទស្រី អាយុ ឆ្នាំ មានអាស័យដ្ឋាននៅ ឃុំ ស្រុក ខេត្ត ។ (ក្រៅឃុំ)

បានប្រព្រឹត្តអំពើដូចតទៅ៖ កាលពីអំឡុងឆ្នាំ ឈ្មោះ និង បាន ចូលហ៊ុនរកស៊ីទិញលក់ដើមកៅស៊ូនៅខេត្ត ជាមួយ មានឈ្មោះ ជា ហើយបានព្រមព្រៀងគ្នាដោយភាគីឈ្មោះ ទទួលបាន % ចំណែកឯឈ្មោះ និង ទទួលបាន % ការរកស៊ីទិញលក់ដើមកៅស៊ូខាងលើនេះឈ្មោះ និង ជាអ្នកចំណាយប្រាក់ទាំងអស់ រីឯឈ្មោះ គ្រាន់តែឈរឈ្មោះតែប៉ុណ្ណោះ។ បន្ទាប់ពីមានការព្រមព្រៀងគ្នារួចហើយ ឈ្មោះ និង បាន ផ្ញើប្រាក់អោយទៅ តាមរយៈធនាគារ ដែលមានឈ្មោះ , ឈ្មោះ និងឈ្មោះ ជាអ្នកទទួលសាច់ប្រាក់ដោយផ្ទាល់សរុបចំនួន ដុល្លាអាមេរិក។ ក្រោយពីទទួលប្រាក់រួចហើយឈ្មោះ បាន ធ្វើការកាប់ដើមកៅស៊ូយកទៅលក់ជាបន្តបន្ទាប់ ប៉ុន្តែមិនបានបង្វិលប្រាក់ដើម និងប្រាក់ចំណេញមកអោយឈ្មោះ ឡើយ។ ហើយពួកគេបានគេចវេស និងគេចខ្លួនរហូត ទើបឈ្មោះ សម្រេចចិត្តដាក់ពាក្យបណ្តឹងមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញដើម្បីចាត់ការតាមនីតិវិធី។

អំពើខាងលើជាបទល្មើស ៖ ឆបោក ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីឆ្នាំ តាមបញ្ញត្តិមាត្រា ៣៧៧ និង ៣៧៨ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

បានឃើញមាត្រា ៨៨ និងមាត្រា ១២៨ ក្រមនីតិវិធីព្រហ្មទណ្ឌ។

**សម្រេច៖**

បើកការស៊ើបសួរលើអង្គហេតុខាងលើ និង

☑ដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ៖

-ឈ្មោះ ភេទប្រុស អាយុ ឆ្នាំ (ក្រៅឃុំ)

-ឈ្មោះ ភេទស្រី អាយុ ឆ្នាំ (ក្រៅឃុំ)

ពីបទ ៖ **ឆបោក** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីឆ្នាំ តាមបញ្ញត្តិមាត្រា ៣៧៧ និង ៣៧៨ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

☑ដាក់ឲ្យស្ថិតនៅក្រោមការឃុំខ្លួនបណ្ដោះអាសន្ន លើឈ្មោះខាងលើ ដើម្បីបង្ការ ឬបញ្ចប់បទល្មើសកុំឲ្យកើតឡើងជាថ្មី និងធានាឲ្យជនត្រូវចោទមុខជូនតុលាការជាក់ជាតាមនីតិវិធី។

ថ្ងៃទី សុក្រ...០១កើត ខែ...កត្តិក...ឆ្នាំ...ព្រះពុទ្ធសករាជ ២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ... ខែ វិច្ឆិកា ឆ្នាំ ...

ចៅក្រមស៊ើបសួរ

**ព្រះរាជអាជ្ញារង**

# ឧបសម្ព័ន្ធទី៣

ឧបសម្ព័ន្ធទី៥

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្តាល**

**មន្ទីរស៊ើបសួរអក្សរ ...**
**សំណុំរឿងលេខ......អ.ក**
**ចុះថ្ងៃទី......................**

**កំណត់ហេតុស្តីពីការសួរចម្លើយជនត្រូវចោទ**
(មាត្រា ១៤៥ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិព្រហ្មទណ្ឌ)

ឆ្នាំពីរពាន់ដប់...............ខែ...............ថ្ងៃទី...............វេលាម៉ោង...............ព្រឹក/រសៀល ។

យើង............................ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល អមដោយលោក/លោកស្រី........ ........................ជាក្រឡាបញ្ជី ។

បុគ្គលដែលនៅចំពោះមុខយើង បានផ្តល់នូវព័ត៌មានអំពីអត្តសញ្ញាណដូចខាងក្រោម៖

| |
|---|
| នាមត្រកូល:..........................................នាមខ្លួន.................................................... |
| ថ្ងៃ ខែ ឆ្នាំកំណើត:........................................................................................ |
| សញ្ជាតិ:.................................................................................................. |
| ទីកន្លែងកំណើត:.......................................................................................... |
| ............................................................................................................ |
| ទីលំនៅបច្ចុប្បន្ន:.......................................................................................... |
| ............................................................................................................ |
| មុខរបរ:.................................................................................................... |
| នៅលីវ ☐ រៀបការ ☐ ប្តី/ប្រពន្ធ ឈ្មោះ:........................................................... |
| ឪពុក ឈ្មោះ: ...................................(រ/ស) ម្តាយឈ្មោះ:.......................................(រ/ស) |
| នីតិជន ☐ ឬអនីតិជន ☐ |
| ☐ ជននេះបានប្រកាសប្រាប់ថា: ខ្លួនមានអំណាចមេបាលើក្មេងអាយុក្រោម ១០ឆ្នាំ ដែលកំពង់ស្ថិតនៅឋានបច្ចុប្បន្ន ។ |

| | | | |
|---|---|---|---|
| -ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ:.................................................................. | | | |
| ............................................................................................................ | | | |
| ☐ ជននេះ: | ☐ចេះនិយាយ | ☐ចេះសរសេរ | ☐ចេះអក្សរសរសេរអក្សរខ្មែរ |
| ☐ ជននេះ: | ☐មិនចេះនិយាយ | ☐មិនចេះអាន | ☐ចេះសរសេរអក្សរខ្មែរ |

អាជ្ញាធរបានមកប្តឹងយើង តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ...................ដក.សស ចុះថ្ងៃទី.......ខែ............ឆ្នាំ២០....ដែលជាហេតុនាំជននេះ ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ និងការឃុំខ្លួនជាបណ្តោះអាសន្ន តាមដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្នលេខ:..............ដក.ស.បឃខ/ ................ចុះថ្ងៃទី.............................។

ជនត្រូវចោទ អមដោយលោក/លោកស្រី.......................................................................ជាមេធាវី។

យើងបានសួរចម្លើយឈ្មោះនេះហើយឈ្មោះនេះបានឆ្លើយប្រាប់យើងថា៖

................................................................................................................................

..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................

☐យើងបានឱ្យជនត្រូវចោទ អានឡើងវិញនូវសេចក្តីប្រកាសរបស់ខ្លួន ដែលយើងបានកត់ត្រាចម្លងក្នុងកំណត់ហេតុនេះ ហើយបើមិនមានការបដិសេធត្រង់ចំណុចណាទេ ឱ្យចុះហត្ថលេខា ឬស្នាមម្រាមដៃលើកំណត់ហេតុនេះ ។

☐បានអានគ្រប់ចប់សព្វ ហើយជនត្រូវចោទមិនមានការបដិសេធត្រង់ចំណុចណាទេ និងបានចុះហត្ថលេខា ឬផ្តិតមេដៃជាមួយយើង និងក្រឡាបញ្ជី ។

☐បានអានចប់សព្វគ្រប់ដោយអ្នកបកប្រែ ហើយជនត្រូវចោទមិនមានបដិសេធត្រង់ចំណុចណាទេ និងបានចុះហត្ថលេខា ឬផ្តិតម្រាមដៃជាមួយយើង,ក្រឡាបញ្ជី និងអ្នកបកប្រែ ។

**ជនត្រូវចោទ អ្នកបកប្រែ មេធាវី ក្រឡាបញ្ជី ចៅក្រមស៊ើបសួរ**

ឧបសម្ព័ន្ធទី៤

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូង**

**..........................**

**មន្ទីរស៊ើបសួរ**

សំណុំរឿងលេខ:....................................

លេខស៊ើបសួរ:.......................................

**កំណត់ហេតុស្តីពីការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី**

(មាត្រា ១៥០ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

ឆ្នាំពីរពាន់............. ខែ............ ថ្ងៃទី................ វេលាម៉ោង.................................

យើង............................................................ ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្ត ........................... អមដោយលោក/លោកស្រី........................................ ជាក្រឡាបញ្ជី ។

និងដោយមានវត្តមានលោក/លោកស្រី....................................... ជាអ្នកបកប្រែ ។

បានមកបង្ហាញខ្លួនក្នុងនាមជា ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងដំណាក់កាលស៊ើបសួរ នៅចំពោះមុខយើង ជនដែលមានអត្តសញ្ញាណដូចខាងក្រោម៖

នាមត្រកូល ៖........................... នាមខ្លួន ៖..........................................

កើតថ្ងៃទី ៖..........................................................................

ទីកន្លែងកំណើត ៖..........................................................................

អាសយដ្ឋាន ៖..........................................................................

មុខរបរ ៖..........................................................................

នៅលីវ ☐ ឬរៀបការ ☐ ឈ្មោះប្តី ឬប្រពន្ធ ៖............................ មានកូន.........

សញ្ជាតិ ៖..........................................................................

ឪពុកឈ្មោះ:................................ រ-ស- ម្តាយឈ្មោះ:................................ រ-ស-អនីតិជន ☐ ឬនីតិជន ☐

☐ជននេះ: ៖ ☐ចេះនិយាយ ☐ ចេះអាន ☐ចេះសរសេរអក្សរខ្មែរ

☐ជននេះ:[1] ៖ ☐មិនចេះនិយាយ ☐មិនចេះអាន ☐មិនចេះសរសេរអក្សរខ្មែរ

---

[1]ក្នុងករណីដែលជននេះមិនចេះភាសាខ្មែរ ត្រូវសរសេរអត្តសញ្ញាណរបស់អ្នកបកប្រែចូលក្នុងកំណត់ហេតុ

| |
|---|
| លោក/លោកស្រី........................................................................ ជាមេធាវី |

បន្ទាប់ពីបានផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ជននេះ យើងបានប្រាប់ដល់ជននេះ ឲ្យដឹងយ៉ាងច្បាស់អំពីរឿងក្តី ដែលព្រះរាជអាជ្ញាបានប្តឹងមកយើងតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ.............. ចុះថ្ងៃទី........... ខែ.......... ឆ្នាំ ..................... ។

យើងបានសួរ និងស្តាប់ចម្លើយឈ្មោះនេះដូចខាងក្រោមថា ៖

សួរ:..........................................................................................................

..................................................................................................................

..................................................................................................................

ឆ្លើយ:........................................................................................................

..................................................................................................................

..................................................................................................................

..................................................................................................................

..................................................................................................................

□យើងបានឲ្យដើមបណ្តឹងរដ្ឋប្បវេណី អានឡើងវិញនូវចម្លើយទាំងអស់របស់ខ្លួនដែលយើងបានកត់ចម្លងចូលក្នុងកំណត់ហេតុនេះ ហើយបើមិនបដិសេធគ្រង់ចំណុចណាទេ ឲ្យចុះហត្ថលេខាលើកំណត់ហេតុនេះ ។

□បានអានចប់សព្វគ្រប់ ហើយដើមបណ្តឹងរដ្ឋប្បវេណីមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខាជាមួយយើង និងក្រឡាបញ្ជី ។

□បានអានចប់សព្វគ្រប់ដោយអ្នកបកប្រែ ហើយដើមបណ្តឹងរដ្ឋប្បវេណីមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខាជាមួយយើង, ក្រឡាបញ្ជី និងអ្នកបកប្រែ ។[2]

**អ្នកបកប្រែ ដើមបណ្តឹងរដ្ឋប្បវេណី មេធាវី ក្រឡាបញ្ជី ចៅក្រមស៊ើបសួរ**

[2] គ្រប់ទំព័រត្រូវអនុលោមតាមមាត្រា ២៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ឧបសម្ព័ន្ធទី៥

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូង

..........................

**មន្ទីរស៊ើបសួរ**

សំណុំរឿងលេខ:.....................................

លេខស៊ើបសួរ:.......................................

**កំណត់ហេតុស្ដីពីការស្ដាប់ចម្លើយសាក្សី**

(មាត្រា ១៥៣ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

ឆ្នាំពីរពាន់............. ខែ............. ថ្ងៃទី............... វេលាម៉ោង.................................

យើង........................................................... ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្ត

........................... អមដោយលោក/លោកស្រី........................................ ជាក្រឡាបញ្ជី ។

និងដោយមានវត្តមានលោក/លោកស្រី........................................ ជាអ្នកបកប្រែ ។

បានមកបង្ហាញខ្លួនក្នុងនាមជាសាក្សី នៅក្នុងដំណាក់កាលស៊ើបសួរ នៅចំពោះមុខយើង ជនដែលមានអត្តសញ្ញាណដូចខាងក្រោម៖

នាមត្រកូល ៖........................... នាមខ្លួន ៖.......................................

កើតថ្ងៃទី ៖...................................................................

ទីកន្លែងកំណើត ៖...................................................................

អាសយដ្ឋាន ៖...................................................................

មុខរបរ ៖...................................................................

នៅលីវ ☐ ឬរៀបការ ☐ ឈ្មោះប្ដី ឬប្រពន្ធ ៖............................ មានកូន........

សញ្ជាតិ ៖...................................................................

ឪពុកឈ្មោះ:............................ ។-ស៊ ម្ដាយឈ្មោះ:............................ ។-ស៊អនីតិជន ☐ ឬនីតិជន ☐

☐ជននេះ: ៖ ☐ចេះនិយាយ ☐ ចេះអាន ☐ចេះសរសេរអក្សរខ្មែរ

□ជននេះ[1] ៖ □មិនចេះនិយាយ □មិនចេះអាន □មិនចេះសរសេរអក្សរខ្មែរ

បន្ទាប់ពីបានផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ជននេះ យើងបានប្រាប់ដល់ជននេះ ឲ្យដឹងយ៉ាងច្បាស់អំពីរឿងរ៉ាវ ដែលព្រះរាជអាជ្ញាបានប្ដឹងមកយើងតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ.............. ចុះថ្ងៃទី........... ខែ.......... ឆ្នាំ ..................... ។

□ជននេះបានស្បថរួចហើយ

□ជននេះមិនព្រមស្បថ

□សាក្សីត្រូវបានអនុញ្ញាតឲ្យរួចពីសម្បថ

យើងបានសួរ និងស្ដាប់ចម្លើយឈ្មោះនេះដូចខាងក្រោមថា ៖

សួរ:..........................................................................................................

..........................................................................................................

..........................................................................................................

ឆ្លើយ:..........................................................................................................

..........................................................................................................

..........................................................................................................

□យើងបានឲ្យសាក្សីអានឡើងវិញនូវចម្លើយទាំងអស់របស់ខ្លួន ដែលយើងបានកត់ចម្លងចូលក្នុងកំណត់ហេតុនេះ ហើយបើមិនបដិសេធគ្រង់ចំណុចណាទេ ឲ្យចុះហត្ថលេខាលើកំណត់ហេតុនេះ ។

□បានអានចប់សព្វគ្រប់ ហើយសាក្សីមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខាជាមួយយើង និងក្រឡាបញ្ជី ។

□បានអានចប់សព្វគ្រប់ដោយអ្នកបកប្រែ ហើយសាក្សីមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខាជាមួយយើង, ក្រឡាបញ្ជី និងអ្នកបកប្រែ ។[2]

**អ្នកបកប្រែ សាក្សី មេធាវី ក្រឡាបញ្ជី ចៅក្រមស៊ើបសួរ**

[1]ក្នុងករណីដែលជននេះមិនចេះភាសាខ្មែរ ត្រូវសរសេរអត្តសញ្ញាណរបស់អ្នកបកប្រែចូលក្នុងកំណត់ហេតុ
[2] គ្រប់ទំព័រត្រូវអនុលោមតាមមាត្រា ២៤២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ឧបសម្ព័ន្ធទី៦

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

**ដីកាចាត់តាំងអ្នកជំនាញ**

បន្ទប់ស៊ើបសួរ "ភ" យើង ក ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

លេខ.............. តព្រ

បានឃើញមាត្រា១២៦ មាត្រា១៦៣ មាត្រា១៦៥ និងមាត្រាពាក់ព័ន្ធនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

បានឃើញសេចក្ដីសម្រេចស្ដីពី ការទទួលស្គាល់មន្ត្រីជំនាញក្នុងការធ្វើកោសលវិច័យគ្រឿងញៀន និងសារធាតុញៀនលេខ ......................... ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១១ របស់ទីស្ដីការក្រសួងយុត្តិធម៌ ។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ.............. ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១១ ។

បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ.................... ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១១។

បានឃើញសំណុំរឿងស៊ើបសួរលេខ.......... ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ។ ដែលមានជនត្រូវចោទ ៖

ឈ្មោះ ............... ហៅ អ៊ា ភេទប្រុស អាយុ ២២ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ លក់ចេកអាំង ទីកន្លែងកំណើតនៅ ឃុំវាលធំ ស្រុកវាលធំ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ទីលំនៅបច្ចុប្បន្ន ផ្ទះជួល ម្ដុំទួលគោក ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

ត្រូវចោទពីបទ: ជួញដូរគ្រឿងញៀនខុសច្បាប់ ប្រព្រឹត្តនៅចំណុចមុខពេទ្យបេះដូង មន្ទីរពេទ្យកាល់ម៉ែត្រ ផ្លូវលេខ៨០ ភូមិទី៧ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមមាត្រា ៣៣ថ្មី នៃច្បាប់វិសោធនកម្មច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

**សំអាងហេតុ**

១. វត្ថុចាប់យកដូចមាននៅក្នុងកំណត់ហេតុដកសំណាកយកទៅធ្វើកោសលវិច័យ តុលាការពុំអាចវាយតម្លៃសន្និដ្ឋានដោយខ្លួនឯងបាន។

២. ដើម្បីឲ្យតុលាការរកយុត្តិធម៌បានត្រឹមត្រូវ គប្បីសម្រេចចាត់តាំងអ្នកជំនាញឲ្យពិនិត្យ សន្និដ្ឋាន និងវាយតម្លៃឲ្យបានច្បាស់ជាមុនសិន ។

ឧបសម្ព័ន្ធទី៧

ឧបសម្ព័ន្ធទី៨

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

មន្ទីរស៊ើបសួរ

លេខ ............. បត.០៩/២០

**ដីកាបង្គាប់ឲ្យចូលខ្លួន**

យើង......................... ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល ។

- បានឃើញមាត្រា១៨៦ និង មាត្រា១៨៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ។
- បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខៈ............ អក ចុះថ្ងៃទី...... ខែ....... ឆ្នាំ២០២០ ។
